ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jun-2013, 10:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី១៩៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ដាវ អានសាន

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ
*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផនៈ**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការៈ**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ច័ន្ទ តារាវស្មី | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡេង ឈឿង (TCW-384) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឡេង ឈឿង** (TCW-384)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី....................ទំព័រ ៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ៣៧
សួរដោយលោក ច័ន្ទ តារារស្មី ផ្ដើមពី ....................ទំព័រ ៤០
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ....................ទំព័រ ៥៩
សួរដោយលោក ពេជ អង្គ ផ្ដើមពី ....................ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:២២]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ តាមកាលវិភាគបានគ្រោងទុក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-384។

លោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គ-ជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរព ជម្រាបលោកប្រធាន នៅក្នុងសវនាការថ្ងៃនេះ គ្រប់ភាគីនៃរឿងក្តីមានវត្តមាន។ ដោយឡែកជនជាប់ចោទ លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមានបញ្ហាសុខភាព។

សវនាការនៅថ្ងៃនេះនឹងស្តាប់សក្ខីកម្មរបស់សាក្សីដែលមានរហស្សនាម TCW-384។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកនៃ អ.វ.ត.ក កាលពីព្រឹកមិញនេះ។ និងបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿងនេះទេ។

សាក្សីរូបនេះមានមេធាវីប្រឹក្សាយោបល់លោក មឿន សុវណ្ណ។ ហើយសាក្សីថ្ងៃនេះអត់មាន -- សវនាការនៅថ្ងៃនេះមិនមានសាក្សីបម្រុងទេ។

សូមចប់សេចក្តីរាយការណ៍។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-384 រួមទាំងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[០៩:០៧:៤៥]

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:២៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្ដី លោកសាក្សី! តើលោកឈ្មោះអី?

**លោក ឡុង ឈឿង៖**

**ឆ៖** ខ្ញុំបាទឈ្មោះ ឡុង ឈឿង។

**ស៖** អរគុណលោក ឡុង ឈឿង។ តើលោកមានអាយុប៉ុន្មាន?

**ឆ៖** អាយុខ្ញុំ ៥០ឆ្នាំ។

**ស៖** អរគុណ ហើយទីលំនៅបច្ចុប្បន្នហ្នឹង លោកនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទនៅស្រុកសំពៅលូន ខេត្តបាត់ដំបង។

**ស៖** អរគុណ ហើយឪពុកបង្កើតរបស់លោកគាត់ឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ឆេង ឌួង។ ម្ដាយខ្ញុំឈ្មោះ អ៊ុន អន។

**ស៖** ចុះប្រពន្ធរបស់លោកគាត់ឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ ហួត ទ្រី មានកូនបីនាក់។

**ស៖** អរគុណលោក ឡុង ឈឿង។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា តាមសមត្ថភាពដែលលោកអាចដឹងគឺលោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវទទួលយកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ ហើយក៏មិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ដែរ។ ហើយថាលោកបានស្បថនៅចំពោះមុខអ្នកតាដំបងដែកនៅអ.វ.ត.ក នេះរួចហើយ មុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនេះ។ តើពិតមែនដែរទេ?

[០៩:១១:១៥]

**ឆ៖** បាទ ពិត ខ្ញុំស្បថមែន។

**ស៖** តទៅនេះអង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះ មុខអង្គជំនុំជម្រះនាពេលនេះ។ លោក ឡេង ឈឿង ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពេលនេះលោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរណាមួយ ឬច្រើន ឬក៏ការសុំឱ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយដោយសារការអនុវត្តសិទ្ធិនេះគឺអង្គជំនុំជម្រះរួមជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានសម្របសម្រួលផ្តល់នូវមេធាវីផ្តល់ប្រឹក្សាសាក្សីដែលអង្គុយនៅជិតលោកនេះ ដើម្បីពិភាក្សាចំពោះសំណួរទាំងឡាយណាដែលទំនងជាចម្លើយ ឬបទអត្ថាធិប្បាយរបស់លោកតបទៅនឹងសំណួរ ឬក៏សុំឱ្យធ្វើអត្ថាធិប្បាយនោះដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្រោយពីពិភាក្សាគឺលោកអាច ឆ្លើយ ឬក៏មិនឆ្លើយតប។

[០៩:១២:២៧]

ករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ លោកមានករណីយកិច្ចត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលសួរចំពោះលោក។ លើកលែងតែករណីសំណួរ ឬអត្ថាធិប្បាយ បទអត្ថាធិប្បាយណាដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

ហើយទន្ទឹមនឹងនេះលោកក៏មានភារកិច្ចឆ្លើយតបនូវអ្វីដែលជាការពិត ដែលលោកបានចងចាំ បានដឹង បានឮ បានមានបទពិសោធន៍ផ្ទាល់ ឬក៏បានធ្វើការសង្កេតពាក់ព័ន្ធផ្ទាល់ទៅនឹងសំណួរ ឬព្រឹត្តិហេតុទាំងឡាយដែលភាគី ឬអង្គចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

លោក ឡេង ឈឿង តាម -- តើលោកធ្លាប់ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ?

**ឆ៖** បាទ ខ្ញុំធ្លាប់ នៅឆ្នាំ២០០៩ គាត់ទៅសម្ភាសខ្ញុំដល់ផ្ទះខ្ញុំ។

**ស៖** ធ្វើប៉ុន្មានដងលោកចងចាំទេ?

**ឆ៖** ម្តង។

**ស៖** អរគុណ ហើយចុះមុនពេលលោកចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ

នេះ លោកបានអាន ឬក៏បានពិនិត្យឡើងវិញនូវកិច្ចសម្ភាសន៍ដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើប-អង្កេតកន្លងមកនេះដែរឬទេ ដើម្បីរំឭកការចងចាំ?

[០៩:១៤:៥៣]

**ឆ៖** ខ្ញុំអត់បានអានផង មើលដើមៗខ្លះ។

**ស៖** អ៊ីចឹងលោកបានពិនិត្យខ្លះដែរ? ហើយតាមការសង្កេតរបស់លោក តើលោកពិនិត្យទៅឃើញថាខ្លឹមសារនៃកិច្ចសម្ភាសន៍ដែលលោកបានធ្វើចំពោះអ្នកស៊ើបអង្កេតនៅកាលពីឆ្នាំ២០០៩ នៅផ្ទះរបស់លោក ហើយនិងខ្លឹមសារដែលលោកផ្ដល់ឱ្យនៅពេលនោះ វាមានខ្លឹមសារស្របគ្នាដែរឬទេ?

**ឆ៖** ពាក្យខ្លះក៏ស្រប ពាក្យខ្លះក៏មិនស្រប មូលហេតុដែលខ្ញុំចាំមិនសូវបាន ហើយភ្លេចភ្លាំងខ្លះ។

**ស៖** បាទ អរគុណ លោក ឡេង ឈឿង។

**ប្រធានអង្គជំនុំ៖**

នៅក្នុងការស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសាក្សី ខៀវ សំផន រួមនិងសាក្សី នួន ជា មានរយៈពេលកន្លះថ្ងៃក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:១៦:១០]

**កញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន ជម្រាបសួរអង្គជំនុំជម្រះ ជម្រាបសួរភាគី។ យោងតាមអនុស្សរណៈ E288 គឺសហព្រះរាជអាជ្ញាជាអ្នកចាប់ផ្ដើមសួរមុនសំណួរសាក្សីនេះមុនលោកប្រធាន។ គឺថាយោងតាមកថាខណ្ឌ៦ នៃអនុស្សរណៈនេះ គឺជា នេះគឺជាកម្មវិធីនៃការសួរសំណួរសាក្សី។ ដូច្នេះនេះជាការពិនិត្យមើលទៅលើអនុស្សរណៈនេះហើយលោកប្រធាន គឺថាសហព្រះរាជអាជ្ញាត្រូវជាអ្នកតាំងសំណួរមុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ម៉េចទៅសហព្រះរាជអាជ្ញា?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន ខ្ញុំអត់មានអនុស្សរណៈដែលមេធាវីការពារក្ដីលើកឡើងអម្បាញ់មិញនេះទេ ក៏ប៉ុន្ដែជាទូទៅ គឺថាជាធម្មតានៅពេលដែលសាក្សីណាមួយដែលភាគីខាងមេធាវីការពារក្ដីអ្នកហៅ អ៊ីចឹងគាត់ជាអ្នកចាប់ផ្ដើម ហើយយើងបន្ដបន្ទាប់ពីពួកគាត់ ហើយជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ នេះជាទស្សនៈរបស់យើងខ្ញុំ ប៉ុន្ដែនេះ -- អ្វីៗគឺអាស្រ័យទៅលើការសម្រេចរបស់លោកប្រធាន។

[០៩:១៧:២៣]

**កញ្ញា អង់តា ហ្គីសសេ៖**

ពិតណាស់ គឺថាជាអ្នកបញ្ជាក់ថាយើងជាអ្នកស្នើសុំកោះហៅសាក្សីរូបនេះមែន ក៏ប៉ុន្ដែខ្ញុំសូមរំឭកផងដែរថា សាក្សីនេះក៏ស្ថិតនៅ -- ចម្លើយរបស់សាក្សីនេះគឺស្ថិតនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាដែលគាត់ស្នើសុំយកចម្លើយជាលាយលក្ខណ៍អក្សរ។ ដូច្នេះសហព្រះរាជអាជ្ញាគាត់បញ្ជាក់ថាចម្លើយរបស់សាក្សីនេះគឺថាមិនពាក់ព័ន្ធទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះទេ។ ដូច្នេះខ្ញុំគិតថាយើងគួរតែនៅអនុវត្តវិធានជាទូទៅៗគឺថាឲ្យសហព្រះរាជអាជ្ញាជាអ្នកសួរមុន ហើយនៅក្នុងអនុស្សរណៈ E288 នៅកថាខណ្ឌ៦, ERN ជាភាសាបារាំងគឺ 00917754 បានកំណត់យ៉ាងច្បាស់ថា ដើមបណ្ដឹងរដ្ឋ -- សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកសួរមុន ហើយមេធាវីការពារក្ដីគឺសួរក្រោយ។ ដូច្នេះខ្ញុំនៅតែរក្សាការស្នើសុំខ្ញុំដដែល គឺឲ្យសហព្រះរាជអាជ្ញាជាអ្នកសួរមុន។

[០៩:១៨:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៨:៥២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវអង្គជំនុំជម្រះសម្រេចផ្ដល់ឱកាសជូនទៅក្រុមមេធាវីការពារក្ដី ខៀវ សំផន តាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី ដោយសារមូលហេតុមេធាវីការពារក្ដីខៀវ សំផន ជាអ្នកម្ចាស់សំណើសុំ ជាអ្នកសំណើសុំឲ្យស្ដាប់សក្ខីកម្មសាក្សីរូបនេះ។ អាចមានបញ្ហាកំហុសបន្ដិចបន្តួចនៅក្នុងអនុស្សរណៈអ៊ីចឹងមែន ប៉ុន្ដែគោលការណ៍ទូទៅគឺអ្នកភាគីដែលស្នើសុំគឺត្រូវមានសិទ្ធិក្នុងការតាំងសំណួរដេញដោលមុនភាគីដទៃទៀតនៃរឿងក្ដី។

[០៩:១៩:៣២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ មិនអីទេ យើងខ្ញុំចាប់ផ្ដើមមុនក៏បាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមជម្រាបសួរលោក ឡេង ឈឿង។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ហើយខ្ញុំចង់សួរសំណួរលោកមួយចំនួនពាក់ព័ន្ធទៅនឹងអង្គហេតុដែលលោកបានជួបប្រទះនៅក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩។ ក្នុងករណីដែលខ្ញុំសួរទៅមានលក្ខណៈមិនច្បាស់លាស់ សូមលោកមេត្តាស្នើសុំឱ្យខ្ញុំសួរសំណួរឡើងវិញ។

ចំណុចទី១ ខ្ញុំចង់ឱ្យលោកជម្រាបអង្គជំនុំជម្រះថា តើលោកចូលបដិវត្តន៍នៅឆ្នាំណា បើតាមលោកចាំនោះ?

**លោក ឡេង ឈឿន៖**

**ឆ៖** ខ្ញុំចូលបដិវត្តន៍ឆ្នាំ -- ចុងឆ្នាំ១៩៧៣។

**ស៖** នៅពេលនុ៎ងលោកនៅតំបន់ណាដែរ?

**ឆ៖** ខាង ខ្ញុំនៅខាងខេត្តតាកែវ។

[០៩:២១:០៥]

**ស៖** តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកនៅតាកែវរហូត ឬក៏មានពេលណាមួយនោះលោកចាកចេញពីតាកែវ?

**ឆ៖** ខ្ញុំ ក្រោយមកឆ្នាំ១៩៧៦ ខ្ញុំបានគេបញ្ជូនមកភ្នំពេញ។

**ស៖** នៅពេលលោកមកដល់ភ្នំពេញនៅឆ្នាំ១៩៧៦ហ្នឹង គេចាត់តាំងឱ្យលោកធ្វើការនៅកន្លែងណាដែរ? ហើយអ្នកណាជាអ្នកចាត់តាំងលោក?

**ឆ៖** ខ្ញុំមកដល់ដំបូង គេឱ្យសម្រាកនៅសាលាបច្ចេកទេសខ្មែរ-សូវៀត ហើយក្រោយមកគេបែងចែកជាពីរ គឺទី១ បែងចែកមនុស្សតូច និងមនុស្សធំ។ មនុស្សតូចទៅរោងចក្រ មនុស្សធំទៅរៀនបើកបរឡាន។

**ស៖** ចុះលោកផ្ទាល់ លោកស្ថិតនៅក្នុងក្រុមណាដែរ?

**ឆ៖** ខ្ញុំបាទស្ថិតនៅក្នុងក្រុមមនុស្សធំ។

**ស៖** បើសិនជាខ្ញុំស្ដាប់មិនច្រឡំទេ គឺថាគេចាត់តាំងលោកឲ្យធ្វើជាអ្នកបើកបរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ចាត់តាំងឲ្យខ្ញុំទៅខាងមនុស្សធំ ខាងបើកបរ។

**ស៖** តើលោកចាំឈ្មោះមន្ទីរដែលលោកធ្វើការទេ?

**ឆ៖** បាទចាំ នៅមន្ទីរក-១២។

[០៩:២៣:៣០]

**ស៖** តើលោកចាប់ផ្ដើមការងារជាអ្នកបើកបរភ្លាមបន្ទាប់ពីលោកទៅដល់ភ្នំពេញ ឬក៏មានសកម្មភាពអីផ្សេងមុននឹងធ្វើជាអ្នកបើកបរនេះ?

**ឆ៖** មុននឹងបើកបរ គេឲ្យនៅបោសសម្អាតក្រុងដែរជំនាន់ហ្នឹងនៅក្មេងៗ កើបសំរាមកើបអីចោលដឹកឡានទៅចោលនៅស្ទឹងមានជ័យ។

**ស៖** អ្នកណាជាអ្នកទទួលខុសត្រូវនៅក-១២ នៅពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** ឈ្មោះ មៀល។

**ស៖** តើលោកនៅក-២ ជាអ្នកបើកបរហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** រយៈពេលជាប់២ឆ្នាំ។

**ស៖** លោកបានឆ្លើយថា នៅឆ្នាំ១៩៧៦ លោកចាប់ផ្ដើមធ្វើជាអ្នកបើកបរ។ ដូច្នេះខ្ញុំអាចនិយាយបានថា លោកនៅកន្លែងហ្នឹងរហូតដល់ឆ្នាំ១៩៧៨។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយបន្ទាប់មកហ្នឹងគឺនៅឆ្នាំ៧៨ហ្នឹងមក បន្ទាប់ពីធ្វើអ្នកបើកបរហ្នឹងមក តើលោកធ្វើអីទៀត?

**ឆ៖** បន្ទាប់មកទៀត គេជ្រើសខ្ញុំឲ្យមកបើកបរឡានឲ្យលោក ខៀវ សំផន។

**ស៖** តើលោកចាំទេ ថាលោកចាប់ផ្ដើមការងារជាអ្នកបើកបរឲ្យលោក ខៀវ សំផន ហ្នឹងនៅពីខែណាដែរក្នុងឆ្នាំ១៩៧៨ ហ្នឹង?

[០៩:២៦:០២]

**ឆ៖** ខ្ញុំចាំមិនសូវច្បាស់ ប៉ុន្តែរវាងខែ៨, ខែ៩ហ្នឹងហើយ ខែ៩។ ខែ៨, ខែ៩ បើមិនខែ៨, ខែ៩,

ខែ១០។ ៣ខែហ្នឹង ខ្ញុំចាំអត់ច្បាស់។

**ស៖** លោកធ្វើការជាអ្នកបើកបរឲ្យលោក ខៀវ សំផន រហូតដល់ពេលណាដែរ?

**ឆ៖** រហូតដល់ឆ្នាំ១៩៧៩។

**ស៖** តើលោកអាចបញ្ជាក់ឲ្យច្បាស់ទេ ឆ្នាំ១៩៧៩ហ្នឹង គឺនៅពេលណា រហូតដល់ពេលណា? ពេលណាឲ្យប្រាកដដែលឈប់ធ្វើការងារជាអ្នកបើកបរឲ្យលោក ខៀវ សំផន នោះ?

**ឆ៖** តាំងពីឆ្នាំ១៩៧៨ ខែ ថាខែ៨, ខែ៩ចុះ រហូតដល់៧៩ហ្នឹង ខ្ញុំឈប់បើកបរឲ្យគាត់ បែកពីគាត់។

**ស៖** ខ្ញុំចង់ដឹងឲ្យច្បាស់ថា ឆ្នាំ៧៩ហ្នឹងៗនៅថ្ងៃណា? ខែណាដែរ? ឬក៏មានព្រឹត្តិការណ៍ណាមួយឲ្យលោកចាំទេ ថាលោកបញ្ឈប់ លោកឈប់ធ្វើការហ្នឹងនៅពេលណា?

**ឆ៖** ឈប់ពេលដែលរត់ឡើងភ្នំ ពេលហ្នឹងរត់ឡើងភ្នំ។

[០៩:២៨:០៩]

**ស៖** នៅពេលដែលលោកនិយាយថា រត់ឡើងភ្នំហ្នឹង មានន័យថាម៉េច? មានន័យថារត់ពេលវៀតណាមវ៉ៃចូល ឬក៏យ៉ាងម៉េច?

**ឆ៖** រត់ឡើងភ្នំហ្នឹង គឺដែលឆ្នាំ -- ដូចជាវៀតណាមវ៉ៃចូលហ្នឹងឯង ឡើងភ្នំ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយឲ្យច្បាស់អំពីមុខងាររបស់លោក។ តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ ថាលោកបើកបរហ្នឹង បើកបររថយន្តប្រភេទណាដែរ ឲ្យលោក ខៀវ សំផន នោះ?

**ឆ៖** បើកបរឡាំប្រឺតាតូចៗ ឡានតូចៗ។

**ស៖** ក្នុងពេលដែលលោកធ្វើការជូនលោក ខៀវ សំផន តើលោកស្នាក់នៅឯណាដែរ?

**ឆ៖** ខ្ញុំបាទស្នាក់នៅខាងក្រៅផ្ទះគាត់។

**ស៖** ក្រៅ ឥឡូវសូមសួរលោកអ៊ីចេះសិន លោកបញ្ជាក់បន្តិចមើល តើផ្ទះលោក ខៀវ សំផន នៅឯណាដែរនៅក្នុងសម័យនោះ?

**ឆ៖** ផ្ទះលោក ខៀវ សំផន នៅ -- ខ្ញុំអត់ -- ឥឡូវនេះ វាដឹងកន្លែងគេហៅស្ទី ប៉ុន្តែកាលសម័យហ្នឹង គេហៅមន្ទីរ ក-៣។ ហើយខ្ញុំនៅផ្ទះគាត់ ផ្ទះមួយហើយ ខ្ញុំនៅផ្ទះមួយឆ្ងាយពីផ្ទះគាត់ប្រហែលជាបួនដប់ម៉ែត្រហ្នឹង វាឆ្ងាយផ្ទះគាត់។

[០៩:២៨:៤៩]

**សៈ** លោកនិយាយថាមន្ទីរ ក-៣។ ដូច្នេះលោកអាចរៀបរាប់បន្តិចបានទេ ថាមន្ទីរ ក-៣ ហ្នឹងមានលក្ខណៈយ៉ាងម៉េច? ថាមានវិសាលភាពប៉ុនណា? ហើយនៅក្នុងនុំងមានអគារប៉ុន្មានអីប៉ុន្មានលោកនៅចាំទេ?

[០៩:៣០:៣៧]

**ផៈ** កាលសម័យហ្នឹង ដូចមិនមានអគារអីទេ មានតែផ្ទះបិទផ្លូវបីល្វែង។ ខ្ញុំដឹងថាបិទផ្លូវបីល្វែង បើកបរឡានបានបីល្វែង បីផ្លូវបាទ ផ្លូវកាត់ទទឹងពីផ្សារអូរឫស្សីទៅខាងកើតផ្លូវផ្សារអូរឫស្សីទៅមុខវាំង ផ្លូវបិទៗស័ង្កសីទេ មិនមែនជានេះទេ។

**សៈ** ក្នុងការបកប្រែជាភាសាបារាំងអំមិញនេះ ខ្ញុំឮថាមានផ្ទះបីល្វែង។ ដូច្នេះមានន័យថាមានផ្ទះមួយមានបីជាន់ ឬក៏យ៉ាងម៉េច?

**ផៈ** បីផ្លូវ មិនមែនបីល្វែងទេ បីផ្លូវហ្នឹងបានន័យថាបិទផ្លូវបី។ បិទផ្លូវដែលផ្ទះជុំវិញ។ ផ្លូវបិទៗស័ង្កសី សម័យនោះបិទស័ង្កសី។ ផ្លូវបីមិនអាចមនុស្សចូលបានទេ ចូលបានតែផ្លូវមួយ។

**សៈ** ខ្ញុំយល់ថានៅក្នុងមន្ទីរនោះមានផ្លូវបី ដូច្នេះសូមឲ្យលោករៀបរាប់ឲ្យបានច្បាស់បន្តិចថានៅក្នុងផ្លូវទាំងបីហ្នឹងមានអ្វីខ្លះ? តើមានការរៀបចំចាត់ចែងផ្ទះ ឬក៏មន្ទីរហ្នឹងយ៉ាងម៉េចដែរ នៅក្នុងក-៣ ហ្នឹង?

**ផៈ** បានន័យថាកន្លែងនៅហ្នឹងគឺមិនមែននៅគ្រប់ផ្ទះទាំងអស់ទេ ព្រោះផ្ទះសម័យហ្នឹងគឺផ្ទះកំពឹកកំពក។ ផ្ទះណាដែលល្អទៅរើស ជ្រើសរើសបោសសម្អាតនៅទៅ ផ្ទះ ណាអាក្រក់ក៏បិទទ្វារចោលទៅនៅក្នុងផ្ទះបីជួរ បីផ្លូវហ្នឹង។

[០៩:៣៣:០១]

**សៈ** តាមចម្លើយរបស់លោកហ្នឹងគឺថានៅក្នុងក-៣ មានផ្ទះជាច្រើន។ ហើយផ្ទះខ្លះមានមនុស្សនៅផ្សេង។ អ៊ីចឹងតើលោកចាំទេថា ចំនួនផ្ទះចំនួនប៉ុន្មានដែរនៅក្នុងក-៣ ហ្នឹង ទោះបីជាមិនមានមនុស្សរស់នៅ ឬក៏មានក៏ដោយ?

**ផៈ** ខ្ញុំអត់ចាំផ្ទះទេ មិនបានរាប់ផ្ទះទេបាទ។

**សៈ** យើងអាចព្យាយាមប៉ាន់ស្មានមើល ព្រោះថាខ្ញុំដឹងហើយ អង្គហេតុហ្នឹងរឿងហេតុហ្នឹងវាកើតឡើងយូរណាស់មកហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើ ឧទាហរណ៍ថាអាចមានលើសពីប្រាំផ្ទះទេ នៅក-៣ នោះ?

**ឆ៖** មាន ២០, ៣០ផ្ទះក៏មិនដឹង ព្រោះបី ខ្ញុំចង់បកស្រាយរឿងហ្នឹងចង់និយាយថា ដែលផ្លូវបី ហើយផ្ទះសងខាង ហើយគិតមើលផ្លូវបីផ្ទះសងខាង បណ្ដោយប្រហែលជាពីរទៅបីរយម៉ែត្រ។ គិតមើលផ្ទះច្រើនដែរនុ៎ង ប៉ុន្តែផ្ទះវាមានល្អមានអាក្រក់។ ប៉ុន្តែផ្ទះមិនមានមនុស្សនៅទាំងអស់ទេ គឺអត់មនុស្សនៅ មានមនុស្សនៅតិចដែរ។

[០៩:៣៤:៣៦]

**ស៖** ដូច្នេះខ្ញុំមកនិយាយអំពីផ្ទះដែលមានមនុស្សនៅ។ លោកនិយាយថាផ្ទះរបស់លោក ខៀវ សំផន ហ្នឹងគឺថាមានចម្ងាយប្រហែលជាប្ដូនដប់ម៉ែត្រពីផ្ទះរបស់លោក។ អ៊ីចឹងលោករស់នៅជាមួយអ្នកផ្សេងទេ នៅផ្ទះរបស់លោកហ្នឹង? បើអ្នកផ្សេងហ្នឹង តើមានអ្នកណាខ្លះដែរ?

**ឆ៖** បាទ ខ្ញុំរស់នៅតែម្នាក់ឯងទេ ពីព្រោះកន្លែងនោះ ខ្ញុំសម្រាកតែម្នាក់អត់មាន --

**ស៖** ចុះផ្ទះដែលលោក ខៀវ សំផន គាត់រស់នៅ តើគាត់រស់នៅតែម្នាក់ឯង ឬក៏មានអ្នកផ្សេងរស់នៅជាមួយគាត់?

**ឆ៖** គាត់រស់នៅម្នាក់គាត់ដែរ ខ្ញុំឃើញ។

**ស៖** នៅក្នុងមន្ទីរក-៣ តើលោកចាំទេថាអ្នកណាខ្លះផ្សេងទៀតដែលរស់នៅក-៣ នុ៎ង?

**ឆ៖** បាទ ខ្ញុំមិនចាំឈ្មោះអត់ទេ ប៉ុន្តែគឺនៅច្រើនគ្នាដែរហ្នឹង ប្រហែលជាប្ដូនដប់ម្ភៃនាក់ដឹង ប៉ុន្តែតែពេលដែលជួបជុំគ្នា ស្គាល់គ្នា តែពេលហូបបាយទេ។

[០៩:៣៦:២៥]

**ស៖** តើលោកចាំឈ្មោះមនុស្សមួយចំនួនទេ ប្រសិនបើថាមិនចាំមិនអស់ តែសុំចាំអ្នកខ្លះមកថាៗដែលលោកធ្លាប់ជួប ធ្លាប់ឃើញនៅពេលដែលរស់នៅក-៣ ជាមួយគ្នានោះ។

**ឆ៖** ខ្ញុំមិនបាន -- ឥឡូវនេះវាភ្លេចឈ្មោះអស់ បើគិតទៅយូរឆ្នាំហើយ ដក់អ៊ីចឹងភ្លេចឈ្មោះអត់ ប៉ុន្តែគ្រាន់ឃើញមុខគ្នាស្គាល់ ហើយរំឭកគ្នាទៅ។

**ស៖** មុននឹងបន្តពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់មួយថា តើលោកអាចរៀបរាប់អំពីផ្ទះដែលលោក ខៀវ សំផន រស់នៅបានទេ?

**ឆ៖** អត់បានទេ ព្រោះខ្ញុំអត់បានចូលទៅក្នុងផ្ទះគាត់ផង។

**ស៖** អម្បាញ់មិញនេះ នៅពេលដែលឆ្លើយទៅនឹងសំណួររបស់លោកប្រធាននោះ លោកបានបញ្ជាក់ថា លោកចាំថាលោកបានឆ្លើយទៅនឹងសំណួររបស់អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត

នៅឆ្នាំ២០០៩។ ដូច្នេះដើម្បីរំឭកការចងចាំរបស់លោកនោះ ខ្ញុំសូមអានចម្លើយរបស់លោក ដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគឺលេខ E3/385។ ឃ្លាដែលខ្ញុំចង់អាននោះគឺនៅ ERN ជាភាសាបារាំងគឺ 00702543, ERN ជាភាសាខ្មែរ 00357210 ហើយបន្តទៅដល់ទំព័រ 11, ជាភាសាអង់គ្លេស 00360127។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបញ្ចាំងឯកសារជាភាសាខ្មែរនៅលើអេក្រង់ ដើម្បីឲ្យសាក្សីគាត់អាចពិនិត្តមើល។

[០៩:៣៩:១០]

ឃ្លាដែលខ្ញុំចង់អាននោះគឺស្ថិតនៅចុងទំព័រជាភាសាបារាំង គឺសំណួរចុងក្រោយនៅក្នុងទំព័រនោះ គឺនៅពេលនោះ អ្នកស៊ើបអង្កេតសួរលោកថា “តើមន្ទីរធ្វើការរបស់លោក ខៀវ សំផន នៅឯណា?” លោកឆ្លើយដូចតទៅ “មន្ទីរធ្វើការរបស់ ខៀវ សំផន មិនមានច្បាស់លាស់ទេ ប៉ុន្តែគាត់ផ្ទះរបស់គាត់នៅក-៣។ ពេលមានការងារ គាត់ចេញទៅធ្វើការទៅ ក្រោយពីចប់ការងារគាត់មកសម្រាកនៅមន្ទីរក-៣ វិញ។ ខ្ញុំឧស្សាហ៍បើកឡានជូន ខៀវ សំផន ទៅផ្ទះម្ដាយរបស់គាត់នៅម្ដុំបឹងកេងកង។ ផ្ទះគាត់មិនមានជាកន្លែងសម្រាប់ធ្វើការទេ គឺឃើញមានតែតុ សាឡុង និងកៅអីសម្រាប់ទទួលភ្ញៀវ ហើយនិងមានអង្រឹងសម្រាប់គាត់សម្រាក។ គាត់មិនមានលេខាផ្ទាល់ និងមានអ្នកកាន់ទូរស័ព្ទទេ ប៉ុន្តែនៅក្នុងផ្ទះទូរស័ព្ទខ្សែមួយសម្រាប់គាត់ប្រើ។ ពេលដែលគាត់ចេញទៅធ្វើការនៅខាងក្រៅ គាត់ចាក់សោផ្ទះ”។ ចប់ការដកស្រង់។

លោកសាក្សី តើការអានចម្លើយរបស់លោកនេះ ធ្វើឲ្យលោកចងចាំឡើងវិញទេ? គឺថាលោករៀបរាប់នៅក្នុងឃ្លាហ្នឹង គឺថាពិតទេជាផ្ទះរបស់លោក ខៀវ សំផន នៅក-៣ នោះ?

**ឆ៖** បាទ ពិត អាហ្នឹងពិត។

[០៩:៤១:០៨]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ចំណុចមួយទៀតដែលខ្ញុំចង់ពិភាក្សាជាមួយលោក។និយាយអំពីក-៣ ហើយយើងនឹងត្រឡប់មកនិយាយអំពីក-៣ នេះនៅពេលបន្តិចទៀតក៏ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរលោកសិនថា តើលោកស្គាល់មន្ទីរក-១ ដែរឬទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកអាចជម្រាបជូនបានទេថា មន្ទីរក-១ នេះនៅចម្ងាយប៉ុន្មានពីមន្ទីរក-៣ ដែរ?

**ឆ៖** មិនប៉ាន់ ខ្ញុំប៉ាន់មិនត្រូវទេ ប្រហែលជាបីបួនគីឡូចុះពី -- បួនគីឡូពីក-៣។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយជាលម្អិតអំពីមន្ទីរក-៣ ដែលលោកបាននិយាយថា ផ្ទះដែលលោកទទួលកាន់កាប់នោះមានចម្ងាយប្រហែលជាជាង១០ម៉ែត្រពីផ្ទះលោករបស់លោក ខៀវ សំផន។ តើក្រៅពីលោក ខៀវ សំផន លោកមានស្គាល់មេដឹកនាំផ្សេងទៀតទេ? អ៊ីចឹងសំណួរចង់សួរថាតើលោកស្គាល់លោក នួន ជា ទេ? ជាសំណួរទី១។

[០៩:៤២:៤៥]

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកបានជួបគាត់នៅកន្លែងណា? ហើយពេលណាដែរ?

**ឆ៖** ជួបម្តងៗពេលដែលគាត់ហាត់ប្រាណហាត់អីហ្នឹងឃើញគាត់ ជួប។

**ស៖** ហើយលោកបានឃើញគាត់នៅកន្លែងណាដែរឲ្យពិតប្រាកដជាក់ស្តែង?

**ឆ៖** ឃើញគាត់នៅមន្ទីរក-៣ ហ្នឹងហាត់ប្រាណពេលល្ងាចៗ។

**ស៖** តើលោកដឹងទេថា គាត់មានផ្ទះមួយនៅមន្ទីរក-៣ ដែរឬទេ? ហើយផ្ទះគាត់ហ្នឹងនៅចម្ងាយពីផ្ទះលោកហ្នឹងប៉ុន្មានដែរ ហើយធៀបនឹងផ្ទះលោក ខៀវ សំផន ហ្នឹងចម្ងាយប៉ុន្មានដែរ?

**ឆ៖** មួយផ្លូវម្នាក់។ គាត់ផ្លូវមួយ ដែលផ្ទះលោក ខៀវ សំផន ផ្លូវមួយ។ ផ្ទះលោក នួន ជា ផ្លូវមួយ។

**ស៖** តើលោកស្គាល់លោក អៀង សារី ដែរឬទេ?

**ឆ៖** ស្គាល់ៗម៉ាឃើញៗគាត់ ស្គាល់។

**ស៖** តើលោកបានឃើញគាត់នៅមន្ទីរក-៣ ដែរឬទេ?

**ឆ៖** បាទ ឃើញនៅមន្ទីរក-៣។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាពីផ្ទះគាត់ទៅមន្ទីរក-៣ ហើយនិងទៅផ្ទះលោកហ្នឹង មានចម្ងាយប៉ុន្មានដែរ លោក ខៀវ សំផន ទៀតនោះ?

**ឆ៖** សំណួរនេះ ខ្ញុំអត់យល់ទេ។ គាត់សួរថាផ្ទះលោកយ៉ាងម៉េច។ ខ្ញុំអត់យល់ទេ។

[០៩:៤៥:៣៣]

**ស៖** លោកបាននិយាយថា លោកបានឃើញ អៀង សារី នៅមន្ទីរក-៣។ អ៊ីចឹងខ្ញុំមិនដឹងថាចង់សួរថា តើគាត់មានផ្ទះនៅមន្ទីរក-៣ ដែរឬក៏អត់ បើតាមលោកចាំនោះ?

**ឆ៖** គាត់មាន ប៉ុន្តែផ្ទះនៅផ្លូវ។ ផ្ទះគាត់ដូចខ្ញុំចាំ ដូចជានៅផ្លូវជាមួយផ្ទះលោក អៀង សារី និង ផ្ទះលោក នួន ជា នៅផ្លូវជាមួយគ្នា។

**ស៖** អ៊ីចឹងបានន័យថា នៅម្ខាងផ្លូវពីផ្ទះលោក ខៀវ សំផន។ អានេះបើតាមការពិពណ៌នារបស់លោកអម្បាញ់មិញ។ អ៊ីចឹងបានន័យថា អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកស្គាល់លោកស្រី អៀង ធីរិទ្ធ ដែលជាភរិយារបស់លោក អៀង សារី ដែរឬទេ? តើគាត់នៅមន្ទីរក-៣ ដែរឬទេ?

[០៩:៤៦:៤៥]

**ឆ៖** គាត់ៗ ខ្ញុំអត់ស្គាល់គាត់ទេ ប៉ុន្តែគាត់អត់នៅមន្ទីរក-៣ ទេ។

**ស៖** តើលោកចាំថា ធ្លាប់បានឃើញ នួន ជា ឬក៏ អៀង សារី រាល់ថ្ងៃ នៅពេលដែលលោកធ្វើការនៅមន្ទីរក-៣ ដែរឬទេ?

**ឆ៖** មិនបានឃើញរាល់ថ្ងៃទេ គឺការងាររៀងៗខ្លួន។

**ស៖** តើលោកដឹងថា តើគាត់នៅមន្ទីរក-៣ ហ្នឹងជាមួយក្រុមគ្រួសាររបស់គាត់។ លោកទើបតែបាននិយាយអម្បាញ់មិញថា អៀង ធីរិទ្ធ មិននៅមន្ទីរក-៣ ទេ។ អ៊ីចឹងសួរថាតើលោកដឹងថាតើ អៀង សារី ឬក៏ នួន ជា នេះអាចទៅកន្លែងផ្សេងទៀត ក្រៅពីមន្ទីរក-៣ ដែរឬទេ? បើនេះបើសិនជាលោកដឹង បើលោកមិនដឹង លោកមិនបាច់ឆ្លើយព្រាវទេ។

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយជាលម្អិតអំពីបញ្ហាស្រស់ស្រូបអាហារ។ លោកនិយាយអម្បាញ់មិញថា នៅមន្ទីរក-៣ នោះ យើងបានជួបជុំគ្នានៅពេលបាយ។ អ៊ីចឹងខ្ញុំចង់ដឹង ថាតើកន្លែងស្រស់ស្រូបអាហារនេះ នៅកន្លែងណាដែរ?

[០៩:៤៨:៤៣]

**ឆ៖** នៅផ្ទះបាយមន្ទីរក-៣ ហ្នឹង។

**ស៖** ហើយអ្នកណាអ្នកដែលមកហូបបាយនៅចង្ក្រានបាយនៃមន្ទីរក-៣ នេះ? តើមនុស្សទាំងអស់គ្នា គឺដូចជាលោក ខៀវ សំផន ហើយរូបលោកផងដែរ ឬក៏មនុស្សទាំងអស់គ្នានោះ ហូបខុសគ្នាកន្លែងខុសគ្នាទៅតាមឋានន្តរសក្តិរបស់ខ្លួន?

**ធ៖** ហូបខុសគ្នា គាត់ផ្ទះបាយផ្សេង ខ្ញុំផ្ទះបាយផ្សេង។ ពួកខ្ញុំខាង --

**ស៖** តើលោកស្គាល់ប្រពន្ធរបស់លោក ខៀវ សំផន ដែរឬទេ? ហើយតើលោកធ្លាប់បានឃើញគាត់នៅមន្ទីរក-៣ ដែរឬទេ នៅសម័យនោះ?

**ធ៖** បាទ ស្គាល់ ឃើញគាត់។

[០៩:៥០:០៧]

**ស៖** ហើយនៅមន្ទីរក-៣ ហ្នឹងប្រពន្ធលោក ខៀវ សំផន ហ្នឹងមានមុខងារអ្វីដែរ?

**ធ៖** គាត់ធ្វើចុងភៅដាំបាយឲ្យ។

**ស៖** តើនៅក្នុងចង្ក្រានបាយគាត់នេះហើយ ដែលលោកហូបបាយនៅសម័យនុ៎ង?

**ធ៖** ទេ អត់នៅហ្នឹង។

**ស៖** ហើយនៅសម័យនោះ លោកហូបបាយជាមួយអ្នកណាដែរ?

**ធ៖** ចង្ក្រានបាយផ្សេងជាមួយមនុស្សច្រើន ចង់និយាយថាគ្នាប្អូនដប់ម្ភៃនាក់ហ្នឹងមកហូបជុំគ្នាខាងគ្នាច្រើន។

**ស៖** លោកហូបជាមួយគ្នាជុំគ្នា ហើយនិងផ្តាច់ពីគ្នាផង។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា លោកនិយាយអំបាញមិញថា ដប់ម្ភៃនាក់នេះលោកហូបបាយជាមួយគ្នាហ្នឹង លោកអាចបញ្ជាក់ពីមុខងាររបស់មនុស្សទាំងដប់ម្ភៃនាក់ហ្នឹងបានទេ?

**ធ៖** អត់បានទេ ខ្ញុំអត់សូវស្គាល់គេទេ ប៉ុន្តែដឹងថាគេធ្វើការផ្សេងៗអត់ដឹងដែរ។

**ស៖** តើលោក ខៀវ សំផន ហូបបាយនៅកន្លែងណាដែរបើតាមលោកចាំ?

[០៩:៥២:០៥]

**ធ៖** បាទ គាត់ផ្ទះបាយមួយដោយឡែកគ្នាអ្នកដឹកនាំរបស់ --

**ស៖** ចាស ឥឡូវខ្ញុំសូមអានសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារE3/385, ERN ជាភាសាបារាំងគឺ 00702544, ជាភាសាខ្មែរគឺ 00357211, ERN ជាភាសាអង់គ្លេស 00360128។ បាទ ខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកនេះ ហើយខ្ញុំចង់បញ្ជាក់ថាតើយើងនិយាយដូចគ្នាឬក៏អត់? សំណួរសួរដោយសហចៅក្រមស៊ើបអង្កេតនៅពេលនោះគឺសំណួរចុងក្រោយបន្ទាប់ចុងក្រោយជាភាសាបារាំង។ “មន្ទីរក-៣ ជាកន្លែងសម្រាប់អ្នកដឹកនាំ។ តើកន្លែងនោះមានបន្ទប់ប្រជុំដែរឬទេ?” ចម្លើយរបស់លោកដូចតទៅនេះ “នៅទីនេះពុំមានសាលប្រជុំរួម

ទេ ហើយខ្ញុំមិនដែលឃើញមេៗទាំងអស់នោះប្រជុំគ្នាដែរ ប៉ុន្តែមានកន្លែងហូបបាយរួមគ្នានៅក្រោមផ្ទះដ៏ធំមួយ ហើយមានតុវែងមួយ"។

សំណួរខ្ញុំដូចតទៅនេះ តើកន្លែងនេះដែលលោកបានពណ៌នានៅក្នុងចម្លើយរបស់លោកនោះ។ តើកន្លែងហ្នឹងហើយដែលលោក ខៀវ សំផន ហូបបាយទឹកនៅសម័យខ្មែរក្រហមហ្នឹង?

[០៩:៥៣:៥៩]

**ផ៖** បាទ។

**ស៖** បាទ ទាក់ទងនឹងមន្ទីរក-៣ ដដែលលោកបានឆ្លើយថា មានបុគ្គលផ្សេងទៀតដែលលោកមិនចាំឈ្មោះទេ គាត់ក៏ធ្វើការនៅមន្ទីរក-៣ ដែរអ្នកទាំងអស់ហ្នឹង។ បើតាមការពិពណ៌នាស្រពេចស្រពិលរបស់លោកនោះ តើលោកចាំថាអ្នកណាជាប្រធានមន្ទីរក-៣ ដែរឬទេ?

**ផ៖** បាទ ចាំ។

**ស៖** លោកអាចប្រាប់ឈ្មោះគាត់បានទេ?

**ផ៖** បាទបាន ឈ្មោះ សាមី។

**ស៖** ក្នុងឋានៈជាប្រធានមន្ទីរនេះៗ តើលោក សាមី នេះជាប្រធានរបស់លោកនៅមន្ទីរក-៣ ហ្នឹង ឬក៏លោកស្ថិតនៅក្រោមឱវាទអ្នកផ្សេងទេ?

**ផ៖** បាទ ខ្ញុំស្ថិតនៅក្រោមឱវាទរបស់លោក សាមី ហ្នឹង។

**ស៖** តើនៅមន្ទីរក-៣ -- អម្បាញ់មិញនេះលោកបានឆ្លើយថា នៅពេលដែលខ្ញុំអានសម្រង់នៃចម្លើយរបស់លោកទាក់ទងនឹងការពិពណ៌នាផ្ទះលោក ខៀវ សំផន នេះ អំមិញនេះលោកបានឆ្លើយថាមិនមែនជាការិយាល័យពិតប្រាកដនោះទេ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចថា ចង់ដឹងថាតើលោកដឹងថាលោក ខៀវ សំផន ហ្នឹងមានមុខងារអ្វីដែរនៅសម័យខ្មែរក្រហមហ្នឹង?

[០៩:៥៦:៤០]

**ផ៖** បាទ ដឹងគេផ្សាយក្នុងវិទ្យុ គឺគាត់ជាប្រមុខរដ្ឋ។

**ស៖** អ៊ីចឹងដោយជាក់លាក់តែម្តង លោកដោយលោកបានធ្វើការបម្រើគាត់រាប់ខែហ្នឹង តើលោកឃើញគាត់ធ្វើអីខ្លះ ហើយមុខងារជាក់លាក់របស់គាត់ហ្នឹងអ្វីដែរ?

**ផ៖** រឿងធ្វើការងារហ្នឹង ខ្ញុំអត់ដឹងទេ ប៉ុន្តែគ្រាន់តែបើកឡានជូនគាត់ ទៅដល់ហ្នឹងគឺគាត់ចូលទៅក្នុងកន្លែងគាត់ធ្វើការផ្សេង ខ្ញុំមិនបានទៅដល់ទេ ព្រោះតែកុងឡាន ហើយនិងអ្នកគាត់ហ្នឹងនៅចម្ងាយ

គ្នាប្រហែលជាពី៥០ម៉ែត្រ ទៅ១០០ម៉ែត្រណោះ ចង់និយាយកន្លែងធ្វើការនីមួយៗនោះ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ តើថាលោក ខៀវ សំផន-- លោកធ្លាប់នាំលោក ខៀវ សំផន ទៅណាខ្លះ? ជូនលោក ខៀវ សំផន ទៅណាខ្លះ? ជាដំបូង ខ្ញុំចាប់អារម្មណ៍ទៅលើការផ្លាស់ទីរបស់គាត់នៅទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំសួរលោកថានៅពេលដែលលោកបើកឡានជូនគាត់នោះ តើលោកមានជូនគាត់ទៅកន្លែងណាច្រើនដែរឬទេ ជូនទៅច្រើនកន្លែងដែរឬទេ?

**ឆ៖** មានតែទៅក-១ ម្ដងៗ និងកន្លែងមុខវាំង កន្លែងសភាចាស់ហ្នឹង។

[០៩:៥៨:៥៥]

**ស៖** ហើយនៅពេលដែលគាត់ទៅមន្ទីរក-១ នោះ តើលោកមានចាំដែរឬទេ ថាគាត់នៅមន្ទីរក-១ ហ្នឹងធ្វើការហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** អត់ដឹងដែរ មិនសូវចាំដែរ ប៉ុន្តែគាត់ទៅៗមួយសន្ទុះមកវិញ ជួនកាល១ម៉ោង ឬកន្លះម៉ោងគឺមិនទៀង។

**ស៖** តើលោកនៅចាំថា តើលោកធ្លាប់បានជូនគាត់ទៅកន្លែងណាក្រៅពីមន្ទីរក-១ ដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំដែរ មិនដឹងទៅណាខ្លះ វាច្រើនឆ្នាំមកហើយ។

**ស៖** តើលោកនៅចាំថា លោកធ្លាប់បាននាំលោក ខៀវ សំផន ឬក៏ជូនលោក ខៀវ សំផន ទៅក្រៅពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ធ្លាប់ម្ដងៗដែរ។

**ស៖** តើលោកនៅចាំទេថា លោកធ្លាប់បានជូនគាត់ទៅក្រៅហ្នឹងប៉ុន្មានដងដែរ?

**ឆ៖** ម្ដង ឬ -- ម្ដងហ្នឹង។

**ស៖** ឥឡូវខ្ញុំសូមដកសម្រង់មួយទៀតនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកដដែលហ្នឹង គឺឯកសារ E3/385 ដដែល, ERN ជាភាសាបារាំងគឺ 00702546, ERN ជាភាសាខ្មែរគឺ 00357212 ហើយបន្តមកទំព័របន្ទាប់ទៀត, ERN ជាភាសាអង់គ្លេសគឺ 00360130។

[១០:០១:៣៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សី។ នេះខ្ញុំគ្រាន់តែសុំជាបង្គ្រប់កិច្ចទេ ពីព្រោះធម្មតាឯកសារដដែលលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ផ្នែកដែលខ្ញុំចង់ពិគ្រោះជាមួយលោកនេះ បាទជាភាសាបារាំងគឺចម្លើយទី៤ សំណួរដែលសួរលោកដូចតទៅនេះ "តើលោក ខៀវ សំផន ធ្វើការអ្វីដែរ?" ចម្លើយរបស់លោក "ខ្ញុំមិនដែលឃើញគាត់ទៅការដ្ឋានការងារដើម្បីត្រួតពិនិត្យទំនប់ ឬក៏ការជីកប្រឡាយអ្វីនោះទេ។ ខៀវ សំផន ទៅខេត្តកណ្ដាលម្ដង ហើយនិងខេត្តតាកែវម្ដង។ ខ្ញុំហាក់ដូចជាឃើញគាត់មិនសូវមានការងារអ្វីច្រើនទេ ប៉ុន្តែដឹងថា គាត់ជាប្រធាន គណៈប្រធានរដ្ឋដោយសារខ្ញុំឮគេប្រកាសតាមវិទ្យុ ហើយនិងតាមមីក្រូ"។

ចាស លោកសាក្សីសំណួរទី១របស់ខ្ញុំទាក់ទងនឹងចម្លើយរបស់លោកនេះ ទាំងពីរដងនេះ ដែលលោកឆ្លើយៗនេះ ថាធ្លាប់នាំគាត់ទៅក្រៅពីរដងនេះ ចង់និយាយថាម្ដងទៅខេត្តកណ្ដាល ម្ដងទៅខេត្តតាកែវហ្នឹងមែនទេលោក?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ មែន។

[១០:០៣:២៩]

**ស៖** ឥឡូវនេះ ខ្ញុំសូមបង្ហាញនៅផ្នែកមួយនៃចម្លើយរបស់លោកដដែល គឺទំព័របន្ទប់ពីហ្នឹង ERN ជាភាសាបារាំងគឺ 00702545, ERN ជាភាសាខ្មែរគឺ 00357212, អង់គ្លេសគឺ 00360129។ ជាភាសាបារាំងនោះ គឺចម្លើយជិតចុងទំព័រ។ សំណួរដែលអ្នកស៊ើបអង្កេតសួរលោកនៅពេលនោះដូចតទៅនេះ។ បន្ទាប់ពីលោកបានពិពណ៌នាអំពីការផ្លាស់ទីរបស់លោក ខៀវ សំផន នៅមន្ទីរក-១ គេសួរលោកថា "តើក្រៅពីហ្នឹងៗ លោកធ្លាប់ជូនគាត់ទៅណាទៀត?" ចម្លើយរបស់លោក "ខ្ញុំបានជូនគាត់ដើរជុំវិញភ្នំពេញ ប៉ុន្តែគាត់មិនដែលបានចូលទៅកន្លែងណាមួយទេ គ្រាន់តែមើលពីខាងក្រៅ រួចក៏ត្រឡប់មកមន្ទីរក-៣ វិញ។ គាត់ធ្លាប់បានឲ្យខ្ញុំជូនទៅខេត្តកណ្ដាលមើលទឹកជំនន់ម្ដង ប៉ុន្តែមិនបានជួបពីណាទេ គឺគ្រាន់តែមកពិនិត្យមើលប៉ុណ្ណោះ។ គាត់ធ្លាប់ឲ្យខ្ញុំបើកឡានជូនទៅមើលទំនប់នៅខេត្តតាកែវម្ដង។ ប៉ុន្តែដោយសារឡានហ្នឹងទៅមុខមិនរួច យើងក៏ត្រឡប់មកក្រោយវិញ មកផ្ទះខ្ញុំវិញនៅតាកែវ។ ក្រៅពីនេះគាត់មិនដែលឲ្យខ្ញុំបើកទៅជូនគាត់ទៅជូនមើលការដ្ឋាន ឬប្រឡាយទំនប់កន្លែងណាទេ សូម្បីតែមន្ទីរសន្តិសុខណាក៏គាត់មិនដែលទៅដែរ។ តើខ្ញុំអាននេះធ្វើឲ្យលោកនឹកឃើញទេ ចាំឡើងវិញទេ គឺថានឹកឃើញថាលោកបានធ្វើការផ្លាស់ទី ឬក៏ជូនគាត់ហ្នឹងតែម្ដងទេ ទៅក្រៅ?

[១០:០៥:៥៦]

**ធ៖** បាទ ដូចជាម្តង ឬពីរដឹងទេ ខ្ញុំចាំមិនច្បាស់ទេ គឺចម្លើយហ្នឹង។ ខ្ញុំមុននឹកឃើញសាឡើងវិញ គឺខ្ញុំអាចជូនគាត់ពីរដងទៅមើលទឹកជំនន់ ដូចគាត់ អ៎! ដូចសំណួរខ្ញុំ ចម្លើយខ្ញុំដែលបានឆ្លើយហ្នឹង។ ទៅខាងតាកែវហ្នឹង ទៅមើល មិនដឹងជាទៅមើលស្អីទេ គឺទៅដើរៗទៅ។ បើកឡានទៅមុខអត់រួចត្រឡប់ក្រោយវិញ ប៉ុណ្ណឹងឯង។

**ស៖** ឥឡូវ ខ្ញុំសូមឲ្យលោកជួយបំភ្លឺមួយ លើឃ្លាលោកដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ លោកនិយាយថា “ខ្ញុំនាំគាត់ទៅមើលជុំវិញភ្នំពេញ”។ កន្លែងនេះលោកចង់និយាយថាលោកនៅក្រៅទីក្រុងភ្នំពេញ ឬក៏នៅក្នុងទីក្រុងភ្នំពញនៅពេលដែលលោកប្រើពាក្យថាទៅជុំវិញភ្នំពេញនេះ។ អានេះជាឃ្លាមួយរបស់លោក ហើយកាលនោះលោកនិយាយថា គាត់គ្រាន់តែមើលទេ ហើយក្រោយមកត្រឡប់មកមន្ទីរក-៣ វិញ។ អត់បានចុះពីលើឡានទេ។ អ៊ីចឹងកន្លែងនេះចង់និយាយថា តើជាការធ្វើទស្សនកិច្ច គឺមើលនៅក្នុងក្រុងភ្នំពេញទេ ឬក៏នៅក្រៅក្រុងភ្នំពេញ?

[១០:០៧:២៤]

**ធ៖** នៅក្នុងក្រុងជិតៗហ្នឹង ប្រហែលជាបួនប្រាំគីឡូ ១០គីឡូអីហ្នឹង មកពីក្រុងភ្នំពេញហ្នឹង។ បួនប្រាំប្រាំមួយគីឡូហ្នឹង គាត់បកមកវិញ។

**ស៖** លោកនិយាយថា គាត់ លោក ខៀវ សំផន ហ្នឹងគាត់នៅក្នុងឡានទេ អ៊ីចឹងមែនទេ?

**ធ៖** បាទ អត់បានចុះទេ នៅក្នុងឡាន។

**ស៖** តើលោកជូនលោក ខៀវ សំផន ទៅមើលជុំវិញភ្នំពេញនេះ ញឹកញាប់ប៉ុនណាដែរ?

**ធ៖** ខ្ញុំយូរៗម្តងទេ មិនមែនញឹកញាប់ទេ។

**ស៖** ឥឡូវខ្ញុំសូមនិយាយអំពីប្រធានបទមួយទៀត គឺទាក់ទងទៅនឹងមុខងាររបស់លោក ខៀវ សំផន នៅសម័យខ្មែរក្រហម។ តើលោកនៅចាំថាលោក ខៀវ សំផន នេះបានទទួលភ្ញៀវបរទេសដែរឬទេ គឺថាក្នុងរយៈពេលដែលលោកធ្វើការជូនគាត់នេះ?

[១០:០៩:០៥]

**ធ៖** ដូចជាខ្ញុំចាំមិនបានទេ កន្លែងហ្នឹងដូចជា អត់ ដូចអត់ដែលទទួលបានភ្ញៀវធំៗទេ។ ព្រោះខ្ញុំនៅតូចដែរ ព្រោះកាលហ្នឹងខ្ញុំអាយុ១៥-១៦ឆ្នាំនោះ ក៏ចាំមិនច្បាស់ដែរ រហូតដល់ឥឡូវនេះ។

**ស៖** លោកសាក្សីដោយសារថា រឿងរ៉ាវទាំងអស់នេះវាកើតឡើងតាំងពីយូរណាស់មកហើយ។ អ៊ីចឹងខ្ញុំចង់រំឭកលោក។ អ៊ីចឹងឯកសារដដែលហ្នឹង គឺថាឯកសារ E3/385, ERN ជាភាសាបារាំងគឺ

0070248 -- 548 ចុងកន្ទុយអម្បាញ់មិញ សូមទោស។ ERN ជាភាសាខ្មែរគឺ 00357215, ERN ជាភាសាអង់គ្លេសគឺ 00360132។ ជាភាសាបារាំង ជាចម្លើយទី៤របស់លោក គេសួរលោកដូចតទៅនេះ ថ្ងៃនោះ “តើអ្នកណាខ្លះមកលេងលោក ខៀវ សំផន មកទស្សនកិច្ច?” ចម្លើយរបស់លោក “គាត់បានទទួលភ្ញៀវប្រហែលជាពីរ ទៅបីដង។ ដូចជាមានភ្ញៀវទូតមកប្រគល់សារតាំង ហើយកន្លែងដែលគាត់ទទួលនោះនៅក្រោយវាំង។ ជំនួបនោះ មានប្រហែលជាកន្លះម៉ោងប៉ុណ្ណោះ”។

សំណួរខ្ញុំដូចតទៅនេះ តើផ្នែកដែលខ្ញុំទើបតែអានជូនអម្បាញ់មិញនេះ ធ្វើឲ្យលោកនឹកឃើញទេ? ហើយនៅចាំថាលោកធ្លាប់បានជូនលោក ខៀវ សំផន ពីបីដងដើម្បីទទួលសារតាំងពីអ្នកការទូតបរទេសដែរឬទេ?

**ឆ៖** បាទ ខ្ញុំនឹកឃើញហើយ ដល់ឆ្លើយ -- គាត់រំឭកនេះ ព្រោះមិនបានមើលឯកសារសាឡើងវិញ ទៅធ្វើឲ្យខ្ញុំភ្លេច។ ដល់អ៊ីចឹងទៅ អាហ្នឹងខ្ញុំបានជូនគាត់ទៅមែន។

[១០:១១:៥៦]

**សៈ** ជាទូទៅ ក្រៅពីការផ្លាស់ទីបន្តិចបន្តួចនេះ ពីរបីដងនៅមន្ទីរ ក-១ ហើយនិងការផ្លាស់ពីរដងនៅខេត្ត គឺខេត្តតាកែវ ហើយនិងខេត្តកណ្ដាលនេះ ហើយនិងទទួលសារតាំង។ តើលោកនៅចាំថាលោក ខៀវ សំផន មានបានធ្វើអ្វីផ្សេងទៀតដែរឬទេ នៅពេលដែលលោកបំពេញការងារឲ្យគាត់នោះ?

**ឆ៖** ដូចជាមិនឃើញគាត់ធ្វើអីដែរ តាមខ្ញុំចាំដូចមិនឃើញធ្វើអី។

**សៈ** ទំព័រដដែលនេះ ខ្ញុំទើបតែដកស្រង់ជូនអម្បាញ់មិញនេះ គឺឯកសារ 00702548, ជាភាសាខ្មែរគឺ 00357214, ជាភាសាអង់គ្លេស 00360132។ លោកឆ្លើយទៅចៅក្រម -- អ្នកស៊ើបអង្កេតដូចតទៅនេះ។ “សំណួរ៖ តើលោកគិតថាលោក ខៀវ សំផន ជាមនុស្សមានអំណាចទេ?” ហើយចម្លើយដូចតទៅនេះ “ខ្ញុំយល់ថា អត់ទេ។ ព្រោះគាត់ហាក់ដូចជាគ្មានការងារធ្វើទេ ច្រើនតែនៅភ្នំពេញ”។ សំណួរខ្ញុំដូចតទៅនេះ តើការចំណាប់អារម្មណ៍របស់លោក ដែលលោកមានចំណាប់អារម្មណ៍ថា លោក ខៀវ សំផន កាលនោះមិនមានការងារអីច្រើនទេ។ អ៊ីចឹងតើលោកនៅចាំអ៊ីចឹងដដែលទេ លោកនឹកឃើញទេ?

[១០:១៤:០៣]

**ឆ៖** បាទៗ នឹកឃើញ។

**សៈ** នៅពេលដែលលោកធ្វើការឲ្យលោក ខៀវ សំផន នោះ។ តើលោកមានចាំថា លោកធ្លាប់បានជូនលោក ខៀវ សំផន ទៅចូលរួមប្រជុំអ្វីទេ? គឺប្រជុំជាសាធារណៈនោះ ប្រជុំជាទ្រង់ទ្រាយធំ?

**ធ៖** ខ្ញុំបានជូនគាត់មក ដូចជាស្តាតម្តង។

**ស៖** អ៊ីចឹងចង់និយាយថាកិច្ចប្រជុំហ្នឹងបានប្រព្រឹត្តឡើងនៅស្តាតអូឡាំពិក នៅភ្នំពេញមែនទេ?

**ធ៖** បាទ ។

**ស៖** តើលោកនៅចាំថាកិច្ចប្រជុំនោះបានប្រព្រឹត្តទៅនៅថ្ងៃណាទេ? ហើយកម្មវត្ថុនៃកិច្ចប្រជុំហ្នឹងអ្វីដែល?

**ធ៖** បាទ ខ្ញុំអត់ចាំទេ ព្រោះប្រជុំរឿងខ្លឹមសារអ្វីក៏អត់ដឹងដែរ ព្រោះខ្ញុំនៅខាងក្រៅឆ្ងាយ។

**ស៖** អ៊ីចឹងតើខ្ញុំត្រូវសន្និដ្ឋានថាលោកមិនបានចូលរួមក្នុងកិច្ចប្រជុំនេះទេ។ អ៊ីចឹងខ្ញុំអាចសន្និដ្ឋានអ៊ីចឹងមែនទេ?

[១០:១៦:១២]

**ធ៖** បាទ ខ្ញុំតែកុងឡានរឿងអីមានសិទ្ធិទៅប្រជុំ។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវផ្នែកមួយទៀតនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ ឯកសារ 00 -- ឯកសារដដែលគឺ E3/385, ERN ជាភាសាបារាំងគឺ 00702545, ERN ជាភាសាខ្មែរ គឺ 00357211, ហើយបន្តមកទំព័របន្ទាប់ទៀតគឺ ERN ជាភាសាអង់គ្លេសគឺ 00360129។ សំណួរដែលគេសួរលោកនៅពេលនោះគឺ "នៅពេលដែលលោកក្លាយជាអ្នកបើកបរឲ្យ ខៀវ សំផន នោះ លោកធ្លាប់ជូនគាត់ទៅកន្លែងណាខ្លះ? ចម្លើយរបស់លោក "គឺនៅឆ្នាំ១៩៧៨ ខ្ញុំបានជូនលោក ខៀវ សំផន ទៅស្តាតអូឡាំពិកដើម្បីចូលរួមមីទិ្ទងមួយ ដែលមានកម្មាភិបាលនិងកម្មកររាប់ពាន់នាក់។ ថ្នាក់ដឹកនាំទាំងអស់បានចូលរួមគឺមាន ខៀវ សំផន, នួន ជា, ប៉ុល ពត ប៉ុន្តែខ្ញុំមិនបានឃើញ សុន សេន នោះទេ។

សំណួរខ្ញុំដូចតទៅនេះ តាមរយៈចម្លើយរបស់លោកនេះ យើងហាក់ដូចជាយល់ឃើញថាលោកបានចូលរួមកិច្ចប្រជុំនេះដែរ មីទិ្ទងនេះដែរ ដោយ -- អ៊ីចឹង ដោយសារលោកហ្នឹងមិនបានចូលរួមពេញលេញនោះទេ។ អ៊ីចឹងសួរថា តើលោកបានឃើញថ្នាក់ដឹកនាំនៅក្នុងមីទិ្ទងហ្នឹងយ៉ាងម៉េចទៅ?

[១០:១៨:១០]

**ធ៖** បាទ ឃើញនោះឃើញអើតមើលពីក្រៅទៅ ហើយឮតែសំឡេងនៅខាងក្រៅទេ ព្រោះតែកុងឡានបើកឡានហើយទៅឈប់នៅខាងក្រៅ នៅចាំឡានខាងក្រៅ។

**ស៖** តើគេប្រកាសឈ្មោះពួកគាត់ទាំងអស់គ្នាហ្នឹងតាមមីក្រូ? តើលោកដឹងទេ ថាតើថ្ងៃនោះសួរថាតើលោក ខៀវ សំផន មានបាននិយាយអ្វីទេ ថ្លែងសុន្ទរកថាអ្វីទេ?

**ផ៖** ដូចអត់មានឮសួរសំឡេងគាត់ផង អត់មានឮនិយាយ។

**ស៖** តើលោកនៅចាំទេ ថាអ្នកណាជាអ្នកសម្របសម្រួលមីទិ្ទងហ្នឹង អ្នកឡើងនិយាយនៅពេលហ្នឹងណ៎ា អ្នកដឹកនាំណាខ្លះឡើងនិយាយ?

**ផ៖** កាលហ្នឹងដូចជា ប៉ុន ពត។

**ស៖** ខ្ញុំសូមអរគុណដែលបានបំភ្លឺ។ ក្រៅពីមីទិ្ទងនៅស្តាតអូឡាំពិកនេះ តើលោកមានបានចាំថាធ្លាប់បានជូនគាត់ទៅចូលរួមកិច្ចប្រជុំអីផ្សេងទៀតទេ?

[១០:២០:១០]

**ផ៖** ដូចខ្ញុំចាំមិនអស់ទេ អាចចម្លើយខ្ញុំហ្នឹងគឺខ្ញុំមិនចាំផង ឆ្លើយអាជំនាន់ហ្នឹងក៏ភ្លេចភ្លាំងខ្លះដែរជួនកាលក៏ខ្ញុំអត់ចាំដែរ ចម្លើយហ្នឹងឆ្លើយខ្លះក៏លើសទៅ អត់ចាំ។

**ស៖** ខ្ញុំយល់លោកសាក្សីដោយសាររឿងរ៉ាវទាំងឡាយនេះ វាកើតឡើងតាំងពីយូរណាស់មកហើយ។ អ៊ីចឹងខ្ញុំសូមរំឭកលោកបន្តិចគឺថាអានផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារដដែល ឯកសារ E3/385 ដដែល, ERN ជាភាសាបារាំងគឺ 00702546, ERN ជាភាសាខ្មែរគឺ 00357213, ERN ជាភាសាអង់គ្លេសគឺ 00360130។

ជាភាសាបារាំង គឺនៅសំណួរចម្លើយទី៣ បន្ទាប់ពីជើងទំព័រទៅ។ សំណួរដែលសួរលោកថ្ងៃនោះដូចតទៅនេះ “តើលោកបាននាំលោក -- ជូនលោក ខៀវ សំផន ទៅប្រជុំកន្លែងណាខ្លះ?” ហើយចម្លើយរបស់លោកនៅឆ្នាំ២០០៩នោះ លោកឆ្លើយថា “ខ្ញុំបានជូនលោក ខៀវ សំផន ទៅកិច្ចប្រជុំធំៗចំនួនពីរដងគឺនៅស្តាតអូឡាំពិកម្តង ហើយមួយទៀតនៅសភាចាស់ម្តង។ នៅប្រជុំកន្លែងនោះ ខ្ញុំបានឃើញកម្មាភិបាលមកពីភូមិភាគជាច្រើន និងតំបន់ចូលរួមច្រើន។ ខ្ញុំដឹងដោយសារឃើញខ្លះ ឮតាមរយៈអ្នកបើកបរហើយនិងកងការពារកម្មាភិបាលទាំងនោះនិយាយ”។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកចាំថាមានចាំពីកិច្ចប្រជុំហ្នឹងដែរឬទេ ហើយលោកបានទៅចូលរួមកិច្ចប្រជុំហ្នឹងដែរឬទេ?

[១០:២២:១៣]

**ផ៖** បាទសំណួរនេះគាត់សួរដូចជាដដែលៗ គឺថាខ្ញុំអ្នកបើកឡាន ខ្ញុំមិនបានចូលរួមនៅក្នុងប្រជុំហ្នឹងទេ ទោះបីប្រជុំអីក៏ដោយ តូចធំយ៉ាងណា គឺខ្ញុំអត់បានចូលរួមទេ ទាំងអស់។

**ស៖** ជួនកាលសំណួររបស់ខ្ញុំនឹងអាចច្រំដែលក៏ប៉ុន្តែខ្ញុំសុំឲ្យលោកជួយបំភ្លឺដោយសារថា យើងបានទទួលចម្លើយរបស់លោកមុនពេលដែលលោកមកឆ្លើយក្នុងសវនាការនេះ។ អ៊ីចឹងខ្ញុំសូមអភ័យទោស

បើសិនជាលោកយល់ឃើញថាខ្ញុំសួរដដែលៗ។ ខ្ញុំសូមបន្តទៀត តើលោកមានដឹង ឬតើលោកស្គាល់មន្ទីរ ៨៧០ ដែរឬទេ?

[១០:២៣:៣០]

**ឆ៖** ឮតែឈ្មោះ ប៉ុន្តែអត់ដឹងនៅកន្លែងណា ខ្ញុំអត់ដឹងដែរ។

**ស៖** ដោយមិនដឹងថា មន្ទីរហ្នឹងនៅកន្លែងណានោះ តើលោកដឹងថាអ្នកណាជាប្រធានមន្ទីរហ្នឹងទេ?

**ឆ៖** អង្កាល់នោះ ខ្ញុំដូចជាចាំតិចៗដូចជាភ្លេចខ្លះអីខ្លះ ចាំខ្លះ ខ្ញុំថាដូចជាដូច តាប៉ង់ ធ្វើប្រធានមន្ទីរ៨៧០ហ្នឹង។ ឈ្មោះ ប៉ង់។

**ស៖** តើលោកដែរឬទេថា ប៉ង់ នេះបំពេញមុខងាររបស់ខ្លួនដល់ពេលណាដែរ?

**ឆ៖** អត់ដឹងដែរ ព្រោះក្រោយមកគាត់ដូរទៅណា ខ្ញុំអត់ដឹងដែរ ប៉ុន្តែដឹងដែរ ខ្ញុំអត់ដែលបានជួបគាត់ដឹងមុខគាត់ម៉េចផង គ្រាន់ដឹងថាឈ្មោះ ប៉ង់ ព្រោះគេប្រកាសថាប្រធានមន្ទីរ៨៧០ ហ្នឹង ឈ្មោះ ប៉ង់។

[១០:២៥:០០]

**ស៖** តើលោកមានស្គាល់ឈ្មោះ កែន ទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកដឹងថា កែន នេះមានមុខងារអីទេ?

**ឆ៖** ដូចអត់មានដឹងមុខងារអីផង គាត់ដូចជា -- អត់ដឹងទេ ខ្ញុំអត់ដឹងគាត់ដែរ។

**ស៖** ឥឡូវខ្ញុំសូមដកស្រង់ផ្នែកមួយទៀត នៅឯកសារដដែលហ្នឹង E3/885 អ៊ំ! 385។ ERN ជាភាសាបារាំងគឺ 00702547, ERN ជាភាសាខ្មែរគឺ 00357214, ERN ជាភាសាអង់គ្លេសគឺ 00360131។

សំណួរដែលគេសួរលោកនៅពេលនោះ ដែលអ្នកស៊ើបអង្កេតសួរលោកនៅពេលនោះ គឺ "បន្ទាប់ពី ប៉ង់ ត្រូវគេចាប់ តើអ្នកណាជាអ្នកជំនួស?" ចម្លើយលោកដូចតទៅនេះ "ឈ្មោះ កែន មកជំនួស ហើយប្រពន្ធរបស់គាត់នៅរស់ តែមិនដឹងនៅទីណាទេ"។ បាទ សំណួរខ្ញុំដូចតទៅនេះ តើលោក -- ឥឡូវនេះលោកចាំវិញហើយឬនៅ ដែលក្រោយពីការរំឭកនេះ? នៅចាំថា កែន នេះបានមកជំនួស ប៉ង់ លោកនឹកឃើញទេ?

[១០:២៧:០៦]

**ឆ៖** បាទៗខ្ញុំដូចជានឹកឃើញដែរ បានគាត់មកជំនួសហ្នឹង អំមិញខ្ញុំនិយាយទៅភ្លេច ព្រោះយូរឆ្នាំហើយ ខ្ញុំអត់ចាំបានទេ។ ប៉ុន្តែអាហ្នឹង ខ្ញុំមានតែប៉ុណ្ណឹងទេ ចាំឡើងវិញ។

**ស៖** លោកសាក្សី តើលោកមានស្គាល់ តាសុត ទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ? ថាតើ តាសុត នេះមានមុខងារអ្វីដែរ?

**ឆ៖** ខ្ញុំសូមជម្រាបជូនលោកតុលាការថា តាសុត នេះ គឺខ្ញុំអត់ដឹងថា គាត់ធ្វើអីដែរ ប៉ុន្តែគ្រាន់តែបើកឡានទៅ ជួនកាលក៏បើកឡានទៅ ខ្ញុំអត់ដឹងគាត់ធ្វើអីដែរ។ ឲ្យដឹង ខ្ញុំអត់ដឹងទេ គ្រាន់តែស្គាល់ឈ្មោះគាត់ប៉ុណ្ណឹង។ ដឹងគាត់ធ្វើអី គឺអត់ដឹង។

[១០:២៨:៣៤]

**ស៖** តើលោកចាំថា តាសុត នេះធ្លាប់ធ្វើការនៅក-១២ ដូចលោកដែរឬទេ?

**ឆ៖** បាទ តាសុត បាទធ្លាប់ធ្វើក-១២ ជាមួយខ្ញុំហ្នឹង។ ខ្ញុំនៅតូចៗ គាត់នាំខ្ញុំបោសសម្អាតក្រុងសម្អាតអីហ្នឹង គាត់ធ្លាប់ធ្វើបើកឡានហ្នឹង គាត់នៅពេល -- គាត់អ្នកបើកឡានដែរហ្នឹង។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅមន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៩នាទី ដល់ម៉ោង ១០:៥២នាទី)*

[១០:៥២:៣០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសាជាថ្មីម្តងទៀតលោកសាក្សី។ ខ្ញុំសូមបន្តការសួរសំណួរបន្តទៅទៀតនៅព្រឹកនេះ។ មុនពេលឈប់សម្រាក យើងកំពុងតែនិយាយគ្នាអំពី តាសុត។ ដូច្នេះខ្ញុំចង់ត្រឡប់មកនិយាយ ប៉ង់ អំពី ប៉ង់ បន្តិច។ នៅពេលដែលលោកផ្តល់ចម្លើយនៅឆ្នាំ២០០៩ ជូនអ្នកស៊ើបអង្កេតនោះ អ្នកស៊ើបអង្កេតបាននិយាយអំពីការចាប់ខ្លួន ប៉ង់។ ចុះលោកផ្ទាល់នោះ តើលោកដឹងទេថាតើ ប៉ង់ បានបាត់ខ្លួននោះក្នុងលក្ខខណ្ឌបែបណាដែរ?

[១០:៥៤:១៦]

**លោក ឡេង ឈឿង៖**

**ឆ៖** អត់ដឹងទេ ប៉ុន្តែដឹងតែដំណឹងថាតាមតៗគ្នាទៅថា តាប៉ង់ ហ្នឹងយកទៅណាបាត់ អត់ដឹង។ ព្រោះគាត់រឿងចំណាស់ហើយ គេហៅថាតាៗជំនាន់ហ្នឹង។

**ស៖** តើលោកស្គាល់អ្នកបកបររបស់ ប៉ង់ ដែរឬទេ?

**ឆ៖** ប៉ង់ ហ្នឹងខ្ញុំដូចមិនច្បាស់ ដូចមិនមានអ្នកបើកបរទេ ដូចមិនដែលឃើញគាត់មានអ្នកបើកបរ។

**ស៖** ខ្ញុំសួរសំណួរនេះពីព្រោះថា យើងមានចម្លើយនៅក្នុង -- របស់តា សុត នៅក្នុងសំណុំរឿងព្រោះថាលោកបានឆ្លើយថា លោកស្គាល់ តាសុត នៅក-១២។ ដូច្នេះខ្ញុំចង់ដកស្រង់ឃ្លាមួយរបស់តាសុត

គឺឯកសារ E3/464, ERN ជាភាសាបារាំងគឺ 00503947, ERN ជាភាសាខ្មែរគឺ 00357 -- បាទ សូមអភ័យទោសខ្ញុំឱ្យលេខ ERN ខុសហើយគឺ ERN ជាភាសាខ្មែរនោះគឺ 00204741, ERN ជាភាសាអង់គ្លេស 00226109, ជាភាសាបារាំងនោះគឺថានៅចម្លើយទី២របស់ សុត គឺនៅចុងឃ្លា។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ ដើម្បីឱ្យសាក្សីគាត់អាចពិនិត្យមើលបានលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១០:៥៦:៥៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នេះជាចម្លើយរបស់ តាសុត ពាក់ព័ន្ធទៅនឹងការបាត់ខ្លួនរបស់ ប៉ង់។ "ថ្ងៃមួយអ្នកបើកឡានរបស់ ប៉ង់ បានប្រាប់ថា ប៉ង់បានស្លាប់ដោយសារចោរព្រៃបាញ់នៅពេលទៅទទួលទំនិញ មានដូចជា គោយន្តពីកប៉ាល់របស់កូរ៉េនៅកំពង់ផែកំពង់សោម។ គឺគាត់ស្លាប់នៅចន្លោះស្រែអំបិល និងវាលរេញ។ ឆ្នាំ១៩៧៦ កែន ហៅ លីន ជំនួស ប៉ង់"។ សូមបញ្ចប់ការដកស្រង់។

ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ស្ដាប់ឮរឿងរ៉ាវដែលថា ប៉ង់ នោះបានស្លាប់ដោយចោរព្រៃបាញ់នោះ ឬក៏នេះជាលើកដំបូងហើយដែលលោកបានស្ដាប់អំពីហេតុការណ៍នេះ?

**លោក ឡេង ឈឿង៖**

**ឆ៖** នេះជាលើកដំបូងហើយដែលខ្ញុំបានឮនេះ ពីព្រោះពីមុនមកអត់ដឹង គឺថាគាត់ទៅណាបាត់អត់ដឹងទេ។

**ស៖** សូមអរគុណលោកសាក្សីដែលបានឆ្លើយបញ្ជាក់។ ឥឡូវនេះខ្ញុំត្រឡប់មកនិយាយអំពី ក-៣ វិញ ហើយនិងនិយាយអំពីការងាររបស់លោកជូនលោក ខៀវ សំផន។ នៅសម័យនោះតើលោក ខៀវ សំផន គាត់មានកងការពារ ឬក៏អង្គរក្សដែរឬទេ? ហើយប្រសិនបើមានតើលោកមាននៅចាំឈ្មោះអ្នកទាំងអស់នោះទេ?

[១០:៥៨:៣៨]

**ឆ៖** ដូចជាមានម្នាក់ឈ្មោះ សឿន។

**ស៖** តើលោកប្រាកដទេ ថាឈ្មោះ សឿន ឬមួយក៏លោកអាចច្រឡំឈ្មោះនេះទេ?

**ឆ៖** ប្រាកដហើយឈ្មោះ សឿន ហ្នឹង ព្រោះក្រោយមកដឹងដំណឹងថាគាត់ស្លាប់បាត់ហើយ សម័យឆ្នាំ១៩៧៩ គាត់ស្លាប់ហើយ។

**ស៖** សំណួរទី១ ពាក់ព័ន្ធទៅនឹង សឿន នេះតើគាត់នៅជាប់ជាប្រចាំជាមួយលោក ខៀវ សំផន នៅពេលដែលលោក ខៀវ សំផន ធ្វើដំណើរ ឬក៏យ៉ាងណា ព្រោះថាលោកនិយាយថាលោកបានជូនគាត់ទៅក-១ ទៅកណ្ដាល ទៅតាកែវ តើនៅពេលលោកជូនទៅហ្នឹង តើអង្គរក្សគាត់ហ្នឹងទៅតាមគាត់ជាប់រហូតទេ?

**ឆ៖** បាទ ទៅជាប់រហូត។

**ស៖** ជាភាសាបារាំងហ្នឹង ខ្ញុំអត់បានស្ដាប់ឮចម្លើយរបស់លោកទេ លោកសាក្សី។ សុំលោកមេត្តាឆ្លើយចម្លើយនេះម្ដងទៀត។

[១១:០០:៥៥]

**ឆ៖** បាទ ទៅតាមគាត់ជាប់រហូត ឈ្មោះ សឿន ហ្នឹង។

**ស៖** ខ្ញុំចង់បានការបញ្ជាក់តូចមួយពីលោក ពាក់ព័ន្ធទៅនឹងឈ្មោះ សឿន នេះពីព្រោះនៅក្នុងការបកប្រែជាភាសាបារាំងនៃកំណត់ហេតុរបស់លោក មានចំណុចមួយដែលខ្ញុំអត់យល់ បានជាខ្ញុំចង់សុំឲ្យលោកបំភ្លឺគឺ ឯកសារដដែលទេគឺ E3/385, ERN ជាភាសាបារាំង 00702549, ERN ជាភាសាខ្មែរ 00357215, ERN ជាភាសាអង់គ្លេស 00360132។ នេះជាចម្លើយដែលអ្នកស៊ើបអង្កេតបានសួរលោក។ ខ្ញុំសូមអភ័យទោសផង ប្រសិនបើខ្ញុំអានឈ្មោះខ្មែរមិនត្រូវ គឺទំព័រជាភាសាបារាំងគឺចម្លើយ -- សំណួរចម្លើយទី១។

អ្នកស៊ើបអង្កេតបានសួរលោកថា “តើលោកស្គាល់ឈ្មោះ ជួន សាន ជាអង្គរក្សលោក ខៀវ សំផន, សឿន, តន, សារិទ្ធ, ធន, វ៉ាន់ និង ខន?” លោកឆ្លើយថា “ឈុន ខ្ញុំមិនស្គាល់ទេ, សំ ជាកងការពារ ខៀវ សំផន ខ្ញុំមិនស្គាល់ទេ, សិន ខ្ញុំមិនស្គាល់ទេ, តន ស្លាប់ហើយ, សារិទ្ធ ខ្ញុំមិនស្គាល់ទេ”។ ផ្នែកដែលពាក់ព័ន្ធដែលខ្ញុំចង់ដឹងនោះគឺ សឿន -- សឿង ខ្ញុំមិនដឹងថា តើឈ្មោះតែមួយទេ ឬក៏យ៉ាងណា ព្រោះថានៅក្នុងចម្លើយនេះ លោកឆ្លើយថាលោកមិនស្គាល់ សិន។ អ៊ីចឹងតើ សិន ហើយនិង សឿង ហ្នឹង ឬក៏ជាមនុស្សតែមួយ ឬយ៉ាងម៉េច ដែលលោកថាអម្បាញ់មិញថា សឿង ជាកងការពារហ្នឹង? ហើយនៅក្នុងនេះជា សិន អ៊ីចឹងតើជាមនុស្សតែមួយឬ?

[១១:០៣:០៩]

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប!

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងលេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់កាត់មេធាវីការពារក្តីទេ ក៏ប៉ុន្តែនៅក្នុងនេះគឺថាមានបញ្ហាអក្ខរាវិរុទ្ធ។ ក្នុងសំណួរនេះគេសួរអំពីឈ្មោះ ស-ិ និង ន។ ហើយប្រសិនបើយើងពិនិត្យមើលទំព័រទី៤ ជាភាសាបារាំង និងអង់គ្លេស និងជាភាសាខ្មែរនោះ គេនិយាយអំពីឈ្មោះ សឿន។ ដូច្នេះយើងមើលអក្ខរាវិរុទ្ធនោះ គឺខុសគ្នាគឺ ស-ឿ និង ង។ ដូច្នេះសាក្សគាត់នឹងអាចបញ្ជាក់បាន។ ក៏ប៉ុន្តែខ្ញុំពិនិត្យមើលច្បាស់ហើយថា នៅក្នុងការបកប្រែជាភាសាបារាំងនោះក៏មានសរសេរអក្ខរាវិរុទ្ធខុសគ្នាដែរគឺមួយ សិន, មួយ សឿន, មិនមែនជាមនុស្សតែមួយទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ដោយសារតែអ៊ីចឹងហើយ បានជាខ្ញុំសួរសាក្សីដើម្បីឱ្យគាត់បំភ្លឺនោះ ពីព្រោះថាមានតែគាត់ទេដែលអាចបំភ្លឺយើងឱ្យបានដឹងច្បាស់អំពីឈ្មោះទាំងពីរនេះបាននោះ។

[១១:០៤:២២]

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ឈ្មោះ សិន នេះគឺខ្ញុំអត់មានស្គាល់ទេ គឺតែឈ្មោះ សឿន។ ខ្ញុំស្គាល់តែឈ្មោះ សឿន ខ្ញុំធ្លាប់នៅជាមួយគ្នាហ្នឹង។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅពេលដែលលោកនិយាយថាលោករស់នៅជាមួយគាត់នោះ លោកនិយាយអំពីក-៣ ឬក៏នៅកន្លែងផ្សេង?

**ឆ៖** បាទ នៅក-៣ ហ្នឹងឯងនៅជាមួយ សឿន ហ្នឹង។

**ស៖** ពាក់ព័ន្ធទៅនឹងមន្ទីរក-៣ ដដែល នៅពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺត្រង់ចំណុចអំពីភារកិច្ចរបស់លោក ខៀវ សំផន។ អម្បាញ់មិញនេះសួរលោកថា តើលោកមានបានឃើញលោក ខៀវ សំផន បំពេញភារកិច្ចអ្វីផ្សេងទៀតទេ? ដូច្នេះខ្ញុំចង់ដឹងថា តើនៅពេលដែលខ្ញុំអានឃ្លាហ្នឹងទៅធ្វើឱ្យលោកចងចាំដែរឬទេ? គឺឯកសារដដែលទេ គឺឯកសារ

E3/385។ ERN ជាភាសាបារាំង 00702546, ERN ជាភាសាខ្មែរ 00357213, ERN ជាភាសាអង់គ្លេស 00360130។

[១១:០៦:៤២]

សំណួរដែលគេបានចោទសួរលោកនៅពេលនោះ "តើលោកដឹងថា ខៀវ សំផន ធ្វើការអ្វីផ្សេងទៀតដែរឬទេ?" ចម្លើយលោកនៅពេលនោះ "មានថ្ងៃមួយនោះ ខ្ញុំឃើញមានគេយកលិខិតមកជួប ខៀវ សំផន នៅក-៣ ដើម្បីសូមចំណាយបើកសម្ភារៈ។ ក្រោយមកខ្ញុំឃើញម្នាក់នោះចេញមកវិញថា យកទៅបើកសម្ភារៈនៅឃ្លាំងរដ្ឋ នៅជួរមាត់ទន្លេ។ ខ្ញុំមិនស្គាល់ថា អ្នកណាទេ ដែលមកស្នើសុំបើកសម្ភារៈនោះ។ ក្រៅពីនោះ ខ្ញុំមិនដែលឃើញមានអ្នកណាមកស្នើសុំសម្ភារៈពីគាត់ទៀតទេ"។ សូមបញ្ចប់ការដកស្រង់ចម្លើយរបស់លោក។

សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធទៅនឹងសន្តិសុខនៅក-៣ តើអ្នកណាម្នាក់ក៏អាចចូលទៅក្នុងបរិវេណក-៣ បានដែរឬអ៊ីចឹង? លោកបញ្ជាក់ថា កន្លែងនុ៎ងជាកន្លែងមួយដ៏ធំ ហើយមានផ្ទះប្រហែលជា២០ផ្ទាយ។ ដូច្នេះតើអ្នកណាក៏អាចចូលទៅកន្លែងនុ៎ងបានដោយងាយស្រួល ដោយមិនចាំបាច់មានការអនុញ្ញាតដែរឬក៏យ៉ាងម៉េច? ឬក៏ត្រូវតែមានលិខិតអនុញ្ញាត ឬក៏មានការឆែកឆេរសន្តិសុខអីមុននឹងចូលទៅនោះ?

**ឆ៖** បាទ អារឿងលិខិតអនុញ្ញាតចេញចូលកន្លែងហ្នឹង ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំដឹងតែខ្លួនខ្ញុំ។ ខ្លួនខ្ញុំមានសិទ្ធិចូលបានតែខ្លួនខ្ញុំ ខ្ញុំអត់ដឹងយ៉ាងម៉េចដែរ។ ប៉ុន្តែមានគេបើកទ្វារ បិទទ្វារ បិទស័ង្កសីហ្នឹង។ អារឿងលិខិតអនុញ្ញាតខ្ញុំមិនអាច -- ខ្ញុំមិនដឹងទេ។ ខ្ញុំអត់មានដែលឃើញគេមានលិខិតអីផង។

[១១:០៨:៤១]

**ស៖** សំណួរទី២ ពាក់ព័ន្ធទៅនឹងចំណុចនេះ តើលោកចាំអំពីមនុស្សដែលមកមើល -- មកសុំសម្ភារៈនៅកន្លែងនោះៗលោកចាំទេ ឥឡូវនេះ នៅពេដែលខ្ញុំអានទៅនុ៎ង គឺថាលោកថា មានមនុស្សមកសុំសម្ភារៈពីលោក ខៀវ សំផន នោះ?

**ឆ៖** ខ្ញុំអាហ្នឹង ខ្ញុំចាំ ប៉ុន្តែឈ្មោះមនុស្សខ្ញុំអត់ចាំទេ។ ចាំតែជំនាន់នុ៎ង វាយូរឆ្នាំហើយគិតទៅ៣០ជិត ៤០ឆ្នាំហើយ ៣៦-៣៧ឆ្នាំហើយនេះ។ ដល់អ៊ីចឹងវាយូរដែរហើយ ដល់អ៊ីចឹងខ្ញុំវាមិនអាចចាំអស់ដែរ ប៉ុន្តែគាត់មានមកសុំមែន ប៉ុន្តែមិនទេ សូមជាសំបុត្រ យកសំបុត្រមកឲ្យទេ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយបញ្ជាក់តាមការចងចាំរបស់លោក។ ខ្ញុំមានចំណុចមួយ

ទៀតចង់សួរលោក តើលោកស្គាល់ឈ្មោះ នង សុផង់ ហៅ ផង់ ដែរឬទេ? សូមទោសផងបើសិនជាខ្ញុំអានមិនច្បាស់នោះ គឺ នង សុផង់ ហៅ ផង់។ លោកស្គាល់ឈ្មោះហ្នឹងដែរឬទេ?

**ផ៖** ឈ្មោះ ផង់ៗ ស្គាល់។

**ស៖** បាទ អ៊ីចឹងឈ្មោះ ផង់ នេះហើយ ឈ្មោះ ផង់ នេះមែនជាឈ្មោះ ប៉ង់ ដែលយើងលើកនិយាយអម្បាញ់មិញដែលថាជាអ្នកធ្វើការនៅ៨៧០ហ្នឹងទេ។ ដូច្នេះ ផង់ ហ្នឹងគឺជាមនុស្សផ្សេង។ ខ្ញុំសួរបែបហ្នឹង ព្រោះថាដោយសារជាភាសាបារាំងហ្នឹង យើង ផង់ ហើយនិង ប៉ង់ ហ្នឹងគឺដូចតែគ្នាទេ យើងអានទៅអត់លក្ខណៈខុសគ្នាទេ បើជាភាសាខ្មែរ គឺខុសគ្នា?

**ផ៖** គាត់ចង់និយាយថា ដែលឈ្មោះ ផង់ ហើយ ប៉ង់ ហ្នឹង គឺមនុស្សពីរនាក់ មិនមែនមនុស្សម្នាក់ទេ។

**ស៖** បាទអ៊ីចឹងហើយគឺ ផង់ៗ ហ្នឹងខ្ញុំចង់ដឹងថា តើគាត់ធ្វើអីដែរនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បើលោកដឹងនោះ?

[១១:១១:៤១]

**ផ៖** បាទដឹងហ្នឹង ដឹងពេលទៅហូបបាយជួបគ្នាទេ បើថារឿងការងារទេ អត់ដឹងទេ ព្រោះការងារអ្នកណា ការងារអ្នកហ្នឹងផ្សេងៗគ្នា ខ្ញុំអត់ដែរទេ។ ប៉ុន្តែពេលទៅធ្វើបាយ គឺហូបជួបជុំគ្នា។

**ស៖** តើលោកស្គាល់សាលាបឋមសិក្សាសុធារស ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីក-១ នោះលោកស្គាល់ទេ សាលាបឋមសិក្សាសុធារស?

**ផ៖** អត់ស្គាល់ទេ ខ្ញុំអត់ស្គាល់ផង។

**ស៖** ការបញ្ជាក់ទី១ ដើម្បីឲ្យយើងដឹច្បាស់ថា យើងកំពុងតែនិយាយអំពី នង សុផង់។ តើលោកស្គាល់តែឈ្មោះ ផង់ ទេ ឬក៏ស្គាល់គាត់ថា គាត់ហ្នឹងឈ្មោះ នង សុផង់?

**ផ៖** ស្គាល់តែឈ្មោះ ផង់ៗ ទទេ ទេ ប៉ុន្តែជីតាខ្ញុំអត់ស្គាល់ទេ។

**ស៖** លោកឆ្លើយថា ផង់ នេះ លោកមិនដឹងពីមុខងាររបស់គាត់ទេ តើអ៊ីចឹងមែនទេ?

**ផ៖** បាទ ខ្ញុំអត់ដឹងមុខងារគាត់ទេ។ ស្គាល់គាត់ដោយសារតែពេលយើងហូបបាយ ទៅហូបជាមួយគ្នា ស្គាល់ដឹង។ ដឹងទេគេធ្វើអី ធ្វើផ្សេងៗពីគ្នាការងារ។

[១១:១៣:៤៩]

**ស៖** សូមអរគុណ។ ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹង នង សុផង់ៗ ជាសាក្សីមួយរូបដែលមក

ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គឺនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២។ គាត់ជាប្រធានមន្ទីរទូរលេខ។ តើលោកមាននឹកឃើញអ្វីទេ នៅពេលដែលខ្ញុំនិយាយថា គាត់ជាប្រធានមន្ទីរទូរលេខនេះ ឬក៏លោកនៅតែមិនដឹងដដែល?

**ឆ៖** ដឹងថាគាត់ទូរលេខហ្នឹង ប៉ុន្តែមិនដឹងទូរលេខ ដឹងថាមុខងារគេអីអត់ដឹង ទូរលេខ។

**ស៖** ដូច្នេះកាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ គឺប្រតិចារឹកសវនាការ គឺលេខ E1/122.1 គឺប្រហែលជាក្រោយម៉ោង១៤:២០នាទី, នង សុផង់ បានឆ្លើយថា៖ "មន្ទីរខ្ញុំនៅក្នុងសាលាសុធារសហើយៗមន្ទីររបស់មេដឹកនាំ គឺនៅក-១ៗ"។ នៅក្នុងកំណត់ -- នៅក្នុងប្រតិចារឹកដដែលនោះ គាត់បានបញ្ជាក់អំពីចម្ងាយរវាងមន្ទីររបស់គាត់ និងក-១ គឺប្រហែលជា១គីឡូ។ តើលោកចាំទេ ចាំអំពីការិយា -- មន្ទីររបស់ នង សុផង់ ទេ? ឥឡូវនៅពេលដែលខ្ញុំអានបែបនេះទៅ តើធ្វើឲ្យលោកចងចាំឡើងវិញទេ?

[១១:១៥:៥៨]

**ឆ៖** ដល់ឈ្មោះ ផង់ ហ្នឹង ខ្ញុំនៅជាមួយគ្នា ស្គាល់គ្នានៅមន្ទីរក-៣ ហ្នឹងទេ អត់មានស្គាល់នៅកន្លែងណាទៀត។ គាត់ទៅមកធ្វើការនៅហូបបាយនៅមន្ទីរ"ក"ទេ បានស្គាល់គ្នាហ្នឹង។ ស្គាល់គ្នានៅកន្លែងក-៣នេះ។

**ស៖** នង សុផង់ គាត់បាន -- គាត់មិនបាននិយាយថាគាត់ធ្វើការនៅក-៣ ទេ។ តើលោកដឹងទេថាមានផ្នែក ឬក៏មន្ទីរផ្សេងទៀតនៅក-៣ ដែលជាកន្លែងធ្វើការរបស់លោក ផង់ នោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ អាហ្នឹងខ្ញុំរឿងការងារខ្ញុំអត់ដឹងអីដែរ ខ្ញុំនៅតូចដែរ ខ្ញុំចាំមិនបានទេ យូរឆ្នាំប៉ុន្តែដូចខ្ញុំដូចអត់ដឹង។ ហើយក្នុងចម្លើយខ្ញុំក៏ខ្ញុំឆ្លើយថាអត់ដែរ បើស្គាល់ៗ។ ដឹងថាឈ្មោះ ផង់ ធ្វើការងារអី ខ្ញុំដូចមិនមានដែលឆ្លើយថា --

**ស៖** ចុះលោកផ្ទាល់នោះ តើលោកធ្លាប់ធ្វើការជាមួយ ផង់ ហ្នឹងទេ? ហើយលោកធ្លាប់ទៅមន្ទីរដែលផង់ធ្វើការទេ?

[១១:១៧:៤២]

**ឆ៖** ដូចមិនមានមន្ទីរអីផង មានតែផ្ទះកន្លែងគាត់សម្រាកហ្នឹង ខ្ញុំមិនដែលដើរកាត់ហូបបាយជួនកាលដើរកាត់មុខផ្ទះហ្នឹង ប៉ុន្តែមិនដែលផ្ទះគាត់ ឬកន្លែងគាត់។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺមិនដឹងថានៅក្នុងផ្ទះរបស់ ផង់ នោះមានអ្វីខ្លះទេ។ អីចឹងមែនទេ?

**ឆ៖** បាទ កាលហ្នឹងខ្ញុំដើរកាត់មុខផ្ទះទៅមុខទៅហួបបាយហ្នឹង បានដើរកាត់ ប៉ុន្តែផ្ទះកន្លែងគាត់ធ្វើអីៗ ខ្ញុំមិនប៊ានចូលទៅទេ។ គាត់សម្រាកនៅហ្នឹង។ ដឹងតែប៉ុណ្ណឹងឯង។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺនៅទំព័រដដែល ក៏ប៉ុន្តែលេខ ERN គឺ 0072546 ជាភាសាបារាំង, ERN ជាភាសាខ្មែរ 00357213, ERN ជាភាសាអង់គ្លេស 00360130។

[១១:១៩:៣១]

ចុះក្រោមមកបន្តិចមក លោកបានឆ្លើយទៅនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា គេសួរលោកថា “នៅៗពេលលោកបើកឡានឲ្យ ខៀវ សំផន តើលោកមានបានរត់សំបុត្រដែរឬទេ?” លោកឆ្លើយថា “ខ្ញុំមិនដែលទេ។ ខ្ញុំធ្លាប់ទទួលសំបុត្រពី ផង់ ផ្ញើទុកឲ្យ ខៀវ សំផន ម្តងនៅពេល ខៀវ សំផន សម្រាក។ ប៉ុន្តែខ្ញុំមិនដឹងសំបុត្រអ្វីទេ។ ខ្ញុំធ្លាប់យកសំបុត្រពី ផង់ យកទៅឲ្យមន្ទីរក-១ ដែរ តែខ្ញុំមិនដឹងថាសំបុត្រនោះមានអត្ថន័យអ្វីនោះទេ”។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា ក្រោយពីហេតុការណ៍ទាំងពីរនោះ តើលោកធ្លាប់យកសំបុត្រទៅឲ្យ ផង់ ឬក៏ទៅឲ្យលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** មានតែទៅទទួលសំបុត្រពី ផង់ នោះមកវិញ បើថាខ្ញុំយកឲ្យលោក ផង់ នោះ ដូចមិនដែលមាន ដូចជាមិនចាំ ខ្ញុំមិនចាំច្រើន យូរឆ្នាំទៅមិនចាំបាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាលោកធ្លាប់យកសំបុត្រទៅនោះតែម្តងទេ នៅពេលដែលលោកធ្វើការជូនលោក ខៀវ សំផន នោះ?

[១១:២១:២០]

**ឆ៖** អត់ចាំទេ មិនដឹងជាប៉ុន្មានដងទេ ខ្ញុំវាមិនចាំ ខ្ញុំថាប៉ុន្តែធ្លាប់យកឲ្យលោក ខៀវ សំផន នោះធ្លាប់គេផ្ញើទុក គាត់សម្រាកអីហ្នឹង ពួកខ្ញុំនៅខាងក្រៅ គាត់អាចផ្ញើទុក ដល់ពេលអីចឹងទៅខ្ញុំមិនដឹងជាប៉ុន្មានដងទេ ខ្ញុំមិនចាំទេអាហ្នឹង។

**ស៖** នៅក្នុងចម្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេតនោះ លោកនិយាយថាម្តង។ ដូច្នេះលោកចាំថាមានលើកណាផ្សេងទៀត ឬក៏តែម្តងទេ? សំណួរខ្ញុំនោះ គឺសួរទៅតាមការចងចាំរបស់លោក បើលោកមិនចាំទេ មិនចាំពាក្យនិយាយប៉ាន់ស្មាន ឬក៏ព្រាវទេ សូមលោកឆ្លើយឲ្យច្បាស់។ បើសិនលោក ចាំថាចាំ បើលោកមិនចាំទេ ខ្ញុំមិនឲ្យលោកសន្និដ្ឋាន ឬក៏ទាយស្មាននោះទេ?

**ផ៖** ខ្ញុំមិនចាំច្បាស់ទេ។

[១១:២២:៤៦]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចូលទៅរយៈពេលមួយទៀត។ គឺនៅពេលដែលចុងក្រោយនៃការធ្វើការងាររបស់លោកជូនលោក ខៀវ សំផន នៅពេលដែលលោករត់គេចចេញពីកម្ពុជា។ អម្បាញ់មិញនេះលោកឆ្លើយថាការងាររបស់លោកចប់នោះ នៅពេលដែលលោករត់ឡើងភ្នំនៅពេលវៀតណាមចូល គឺនៅខែមករា ឆ្នាំ១៩៧៩។ តើលោកចាំថ្ងៃខែច្បាស់លាស់ទេ ថ្ងៃណានៅពេលដែលលោករត់ចេញពីភ្នំពេញនោះ?

**ផ៖** ខ្ញុំអត់ចាំទេ។

**ស៖** លោកមិនចាំថ្ងៃខែ ក៏ប៉ុន្តែលោកចាំអំពីលក្ខខណ្ឌទេ កាលៈទេសៈគឺថានៅពេលព្រឹក ឬក៏ពេលរសៀល លោកចាំទេ អាចគិតមើលឡើងវិញទៅមើល?

**ផ៖** ពេលយប់កាលហ្នឹង។

**ស៖** តើលោកនៅចាំទេថានៅពេលព្រឹក ឬក៏ពេលថ្ងៃមុនពេលដែលលោកចាកចេញនោះ នៅថ្ងៃដែលលោកចាកចេញនោះ លោកមានរៀបចំអីវ៉ែអីវ៉ាន់ខ្លះដើម្បីរត់ចេញទៅនោះ?

**ផ៖** ដូចមាន អត់មានអីផងកាលហ្នឹង ទៅៗបណ្ដោយ ទៅពេលយប់ ទៅអត់មានអីវ៉ាន់អីផង។

[១១:២៤:៥៩]

**ស៖** លោករត់ចេញហ្នឹង លោករត់តែម្នាក់ឯង ឬក៏មានគ្នា?

**ផ៖** រត់ជាមួយនឹងលោក ខៀវ សំផន ហ្នឹងហើយបើកឡានឲ្យគាត់ហ្នឹងឯង។

**ស៖** តើលោកដឹងទេ នៅពេលនុ៎ងៗ តើប្រពន្ធរបស់លោក ខៀវ សំផន នៅឯណាដែរ? អម្បាញ់មិញនេះលោកឆ្លើយថា លោកធ្លាប់ឃើញគាត់នៅធ្វើការនៅក-៣។ អ៊ីចឹងពេលរត់ហ្នឹង តើប្រពន្ធលោក ខៀវ សំផន នៅឯណាដែរ?

**ផ៖** គាត់អត់បានរត់ជាមួយគ្នាទេ ខ្ញុំរត់ទៅតែខ្ញុំ ហើយនិងគាត់ ហើយនិងដែលឈ្មោះ សឿន ហ្នឹង។ ប្រពន្ធគាត់ទៅផ្សេងអត់ដឹង ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកចាំទេ ថាមុនពេលលោករត់ចេញទៅហ្នឹង លោកបានជួបប្រពន្ធរបស់លោក ខៀវ សំផន ទេ មុនពេលលោករត់ចេញ នៅថ្ងៃនុ៎ងៗ ថ្ងៃមុនរត់ហ្នឹងលោកមានឃើញប្រពន្ធលោក ខៀវ សំផន ទេ បើតាមការចងចាំរបស់លោកនោះ?

**ឆ៖** ឃើញតើ នៅផ្ទះនៅចម្ងាយគ្នា ឃើញគាត់ គ្រាន់តែឃើញៗអ៊ីចឹង ឃើញពីចម្ងាយអ៊ីចឹង ប៉ុន្តែមិនដែលបានទៅសួរសុខទុក្ខទៅសួរអីគាត់ទេ គឺឃើញ។

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរបែបនេះ ពីព្រោះថាលោកស្រី សូ សុជាតិ ដែលជាប្រពន្ធរបស់ លោក ខៀវ សំផន ហ្នឹងបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ គឺក្រោយម៉ោង១៥:៤៤ នាទីបន្តិច គាត់បានឆ្លើយថា “នៅថ្ងៃរត់យួននុ៎ង លោក ខៀវ សំផន ហើយនិងលោកផ្ទាល់នោះបានទៅ ស្ថានីយ៍រថភ្លើងដើម្បីជិះរថភ្លើង ហើយមាននាំកូនៗទៅដែរ”។ តើលោកមាននៅចាំហេតុការណ៍នេះទេ ឬក៏លោកមិនដឹងអ្វីទេ?

[១១:២៧:៤១]

**ឆ៖** នេះខ្ញុំអត់ចាំទេ ទាល់តែគាត់រំឭកអ៊ីចឹងគឺខ្ញុំដូចអត់មានបានទៅទេខ្ញុំ អត់បានទៅរថភ្លើង ស្ថានីយ៍រថភ្លើងទេ។ ខ្ញុំអត់ចាំទេ តាំងពី --

**ស៖** តើលោកចាំទេថា បែបលោកអត់ចាំពីថ្ងៃខែឆ្នាំទេ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកមាននឹក ឃើញថា លោកមានបាននៅជាមួយលោក ខៀវ សំផន ទេ នៅថ្ងៃដែល មុនរត់ហ្នឹងលោកនៅជាមួយ លោក ខៀវ សំផន ឬក៏ដល់តែយប់ហើយទើបលោកជួបលោក ខៀវ សំផន នោះ?

**ឆ៖** ខ្ញុំនៅៗហ្នឹងផ្ទះខ្ញុំហ្នឹង ប៉ុន្តែមិននៅជាមួយគាត់ នៅផ្ទះផ្សេងពីគ្នា ប៉ុន្តែនៅជិតគ្នាហ្នឹងឯង មានការអីហៅបាន។

**ស៖** លោកសាក្សីជាភាសាបារាំងនោះ គឺខ្ញុំអត់យល់ឃ្លាចុងក្រោយនៃចម្លើយរបស់លោកទេ។ ដូច្នេះសូមឲ្យលោកឆ្លើយបញ្ជាក់ឲ្យច្បាស់ម្តងទៀត។ ខ្ញុំសួរលោកថា នៅពេលថ្ងៃ នៅពេលដែលលោក រៀបចេញរត់ចេញទៅពីទីក្រុងភ្នំពេញនោះ រត់ចេញពីភ្នំពេញនោះ លោកនៅជាមួយលោក ខៀវ សំផន ដែរទេ ឬក៏លោកឃើញគាត់នៅពេលដែរ នៅពេលយប់ដែលលោករត់ទៅជាមួយគាត់នោះហើយ?

[១១:២៨:៤១]

**ឆ៖** ពេលថ្ងៃហ្នឹងខ្ញុំនៅជាមួយគាត់ហ្នឹង នៅ -- មិននៅជាមួយទេ នៅជិតហ្នឹង។ ពេលយប់ បានរត់ ពេលយប់បានរត់ចេញ។

**ស៖** នៅពេលដែលលោកនិយាយថា លោកនៅជាមួយគាត់នៅជិតផ្ទះគាត់នោះ មានន័យថា លោកនៅផ្ទះរបស់លោក ដែលមានចម្ងាយប្រហែលដប់ម៉ែត្រពីផ្ទះលោក ខៀវ សំផន អ៊ីចឹងមែនទេ? មានន័យ ថា ពេលនុ៎ងមិនមែនលោកនៅផ្ទះជាមួយលោក ខៀវ សំផន ទេ?

**ផ៖** បាទ ខ្ញុំនៅផ្ទះជិតគាត់ មិននៅផ្ទះជាមួយគាត់ទេ។

**ស៖** តើលោកដឹងទេថា នៅថ្ងៃនុំងលោក ខៀវ សំផន អាចចេញទៅក្រៅដោយអត់មានលោកនោះ លោកអាចនៅចាំទេ?

**ផ៖** ដូចមិនៗគាត់ចេញទៅណាអត់កើតទេ ព្រោះអត់មានតែកុងឡាន បើតែកុងឡាន មានតែខ្ញុំម្នាក់ទេ។

[១១:៣១:១៧]

**ស៖** សូមអរគុណ។ ចុះនៅពេលព្រឹកៗមុនពេលចេញ រត់ចេញនោះ តើលោកមានបើកឡានជូនលោក ខៀវ សំផន ទៅចូលរួមប្រជុំនៅកន្លែងណាទេ? លោកមានចាំទេថា ព្រឹកមុនរត់ហ្នឹងលោកបានជូនលោក ខៀវ សំផន ទៅចូលរួមប្រជុំ?

**ផ៖** ដូចមិនចាំ អាហ្នឹងខ្ញុំមិនចាំ មើលទៅក្នុងនេះ ខ្ញុំដូចអត់មានចាំទេ។ អត់ដែលមានទៅណាផងថ្ងៃនុំង នៅតែផ្ទះ។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយនៅថ្ងៃមុនពេលលោករត់ចេញពីភ្នំពេញ គឺមុន១ថ្ងៃ តើលោកចាំថាលោកមានបានជូនលោក ខៀវ សំផន ទៅកិច្ចប្រជុំមួយនៅបុរីកីឡាដែរទេ?

**ផ៖** អត់មានផង។ ខ្ញុំអត់ដែលមានបានទៅ ពេលរត់ ជិតរត់នុំង ដូចអត់មានទេ។

**ស៖** ខ្ញុំសួរលោកបែបនេះហ្នឹង ពីព្រោះថា នៅក្នុងតុលាការនេះសាក្សីពីររូបបានមកផ្តល់សក្ខីកម្ម គឺសាក្សី ស៊ឹម ហោ ដែលបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ ហើយនិងរស់ ស៊ុយ ដែលបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣។ អ្នកទាំងពីរហ្នឹង គឺថាគាត់រៀបរាប់ជាលក្ខណៈផ្សេងគ្នា ប៉ុន្តែរៀបរាប់ហ្នឹង គឺអំពីការប្រជុំនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ គឺមុនពេលរត់ចេញពីទីក្រុងភ្នំពេញ។ អ៊ីចឹងខ្ញុំសួរលោកម្តងទៀតថា តើលោកមាននៅចាំទេថា លោកបានជូនលោក ខៀវ សំផន ទៅប្រជុំនៅបុរីកីឡានោះ?

[១១:៣៤:០៥]

**ផ៖** ខ្ញុំអត់មានដែលជូនទៅផង បើតាមខ្ញុំចាំហើយនេះ បើ --

**ស៖** សម្រាប់ភាគី ហើយនិងអង្គជំនុំជម្រះ ខ្ញុំសូមរំឭកថា សាក្សី ស៊ឹម ហោ បាននិយាយអំពីកិច្ចប្រជុំនេះនៅខែមេសា -- នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ គឺនៅម៉ោង ១៤:២៦ ហើយនៅមួយទៀតនោះ គឺថានៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ គឺនៅក្រោយម៉ោង ១១:៣៥ បន្តិច។ អ្នកទាំងពីរហ្នឹង

គាត់បាននិយាយអំពីកិច្ចប្រជុំនៅបុរីកីឡាន៉ុង។

ឥឡូវនេះ ខ្ញុំចង់ដកស្រង់ឃ្លានៅចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/385 ERN ជាភាសាបារាំងគឺ 00702548, ERN ជាភាសាខ្មែរ 00357215, ERN ជាភាសាអង់គ្លេស 00360132។ អ្នកស៊ើបអង្កេតបានសួរលោកនៅថ្ងៃនោះថា "តើពេលណាលោកដឹក ខៀវ សំផន រត់ចេញពីភ្នំពេញ?" លោកបានឆ្លើយនៅពេលនោះថា "នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានដឹកខៀវ សំផន ចេញពីភ្នំពេញនៅប្រហែលម៉ោងប្រាំពីរយប់ ហើយបានមកសម្រាកនៅពោធិ៍សាត់។ ខៀវ សំផន បានជួប ប៉ុល ពត, នួន ជា នៅសាលាខេត្តពោធិ៍សាត់។ បន្ទាប់មកខ្ញុំបានដឹក ខៀវ សំផន មកបាត់ដំបងរហូតមកដល់ប៉ៃលិន។ ខ្ញុំបែកគាត់នៅខែមេសា ឆ្នាំ១៩៧៩"។ សូមបញ្ចប់ការដកស្រង់។

[១១:៣៦:២៥]

សំណួរដំបូងពាក់ព័ន្ធទៅនឹងចំណុចនេះ នៅក្នុងចម្លើយរបស់លោក លោកឆ្លើយថា ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ដូច្នេះតើលោកមាននឹកឃើញឡើងវិញទេ ឬក៏លោកនៅតែរក្សាចម្លើយថា លោកមិនចាំទេ?

**ឆ៖** បាទអានេះខ្ញុំនឹកឃើញ ព្រោះគាត់និយាយអ៊ីចឹងទៅ ខ្ញុំមើលឯកសារហ្នឹងទៅឃើញ ខ្ញុំបានឆ្លើយអ៊ីចឹងមែន។ ហើយខ្ញុំមកហ្នឹងគឺគាត់សួរខ្ញុំហ្នឹង គាត់នេះទៅ អាចនឹងថ្ងៃទី៦ ហ្នឹងហើយ យប់នោះចេញមកយប់។ អាហ្នឹងត្រឹមត្រូវតាមសំណួរដែលខ្ញុំឆ្លើយនោះឯង។

**ស៖** ខ្ញុំដឹងថាមានការបកប្រែខុស ឬក៏យ៉ាងណាទេ ព្រោះថាខ្ញុំឮការបកប្រែអម្បាញ់មិញនេះជាភាសាបារាំង គឺថាថ្ងៃទី៦ មករា ឆ្នាំមួយពាន់ប្រាំមួយ -- ០៦ មេសា ឆ្នាំ១៩៧៩។ លោកសូមបញ្ជាក់កាលបរិច្ឆេទហ្នឹងបានទេ?

**ឆ៖** បាទថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺចេញហ្នឹង ពេលម៉ោងប្រាំពីរយប់ហ្នឹងឯង។

[១១:៣៧:៥៩]

**ស៖** ខ្ញុំសូមអរគុណ ដែលបានបំភ្លឺ។ ឥឡូវនិយាយចំណុចចុងក្រោយ ដោយសារលោកបានធ្វើការនៅក្បែរលោក ខៀវ សំផន នៅរយៈពេលប៉ុន្មានខែចុងក្រោយដែលពេលនោះ លោកធ្វើការជាអ្នកបើកបរឲ្យគាត់។ តើលោកអាចពិពណ៌នាដោយសង្ខេបអំពីអាកប្បកិរិយារបស់គាត់បានដែរឬទេ?

**ឆ៖** បាទបាន ខ្ញុំពិពណ៌នាគាត់ទៅ គាត់គឺជាមនុស្សមួយស្លូតបូត សុភាពរាបសា គឺមិនដែល

ឃើញថាមាន។ ខ្ញុំរស់នៅជាមួយគាត់នេះ ខ្ញុំដឹងតែរយៈពេលខ្លីមែន ប៉ុន្តែខ្ញុំឃើញថាគាត់ស្លូតបូតសុភាពរាបសា មិនមានអី។ មិនដែលឃើញទៅចាត់ចែងឯណាផង ឃើញគាត់ ឮតែក្នុងវិទ្យុប្រកាសគាត់ថាប្រមុខរដ្ឋ។ ហើយប្រមុខរដ្ឋពេលនោះគឺ គាត់អត់មានឃើញចាត់ចែងអីទាំងអស់ ដល់ពេលខ្ញុំធំ ដឹងក្តីឡើង ខ្ញុំដឹងថាប្រមុខរដ្ឋចាត់ចែងប្រទេសដែរ។ ដល់ពេលអ៊ីចឹងអត់ ទាល់តែអ៊ីចឹងសូម្បីតែចៅក្រមហ្នឹងសួរខ្ញុំថា ប្រមុខរដ្ឋអត់មានអំណាច។ ហើយខ្ញុំថា ដែលខ្ញុំឆ្លើយថាអ៊ីចេះវិញដែរ ប៉ុន្តែក្នុងហ្នឹងអត់មានចម្លើយក្នុងហ្នឹងអត់មានឆ្លើយទេ ខ្ញុំថាដែលគាត់ប្រមុខរដ្ឋពេលនោះ គឺគាត់អត់មានអំណាចអ៊ីចឹង ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តហ្នឹង។

[១១:៣៩:០៥]

នេះដល់ខ្ញុំធំឡើង ខ្ញុំនិយាយអ៊ីចឹង និយាយតាមយល់របស់ខ្ញុំទេ ខ្ញុំជាមួយគាត់។ ហើយឃើញថាកាលសម័យនោះ គាត់គឺឃើញដូចខ្ញុំនិយាយអ៊ីចឹងឯង។ បើអ្នកធ្លាប់ស្គាល់គាត់ ទៅ -- សូម្បីតែកម្មសិទ្ធិទ្រព្យសម្បត្តិក៏គ្មានដែរ។ ខ្ញុំឃើញថា តាំងពីខ្ញុំរស់នៅជាមួយរហូតខ្ញុំធ្លាប់ស្គាល់គាត់នោះ។ បើថាអស់លោកខាងតុលាការមិនជឿ ទៅស៊ើបអង្កេតដល់ផ្ទះគាត់ទៀត ក៏មិន -- ខ្ញុំឃើញតែអ៊ីចឹង គាត់អត់មានកម្មសិទ្ធិអីសោះ។ សូម្បីតែខ្ញុំរស់នៅជាមួយគាត់ ខ្ញុំក៏អត់មានកម្មសិទ្ធិអីដែរជំនាន់ណោះ។ ប៉ុន្តែខ្ញុំនៅតូចៗ ដល់គាត់នោះចាស់ហើយ ក៏គាត់អត់មានកម្មសិទ្ធិអី អាកប្បកិរិយាគាត់គឺល្អ សុភាពរាបសា ហើយគួរតែគោរពគាត់។ នេះគួរជាគោរពនេះ ចំពោះខ្លួនខ្ញុំទេ មិនមែនថាអស់លោកទៅឱ្យទៅគោរពទេ គឺចំពោះខ្លួនខ្ញុំគួរតែគោរពគាត់។ ហ្នឹងខ្ញុំសូមមានយោបល់ជូនលោកតុលាការឱ្យជ្រាបតែប៉ុណ្ណឹង។ សូម --

**កញ្ញា អង់តា ហ្គីសសេះ**

លោកសាក្សី ខ្ញុំសូមអរគុណ។ លោកប្រធាន ខ្ញុំសួរចប់ហើយ។ ហើយសូមបញ្ជាក់ផងដែរថានៅសល់ពេល១៥នាទីចំពោះក្រុមយើងទៀតនេះ។ អ៊ីចឹង១៥នាទីនេះ បើសិនជាសហភាគា កូប៉េ របស់ខ្ញុំនេះគាត់ចង់ប្រើប្រាស់ពេលវេលានេះ គាត់ប្រើប្រាស់បាន។

[១១:៤០:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុម -- តំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្ត -- សួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកៗចៅក្រម ឡាវែន៍ មានសំណួរចង់សួរ ហើយលោកតំណាងសហព្រះរាជអាជ្ញាចាំលោកចៅក្រម ឡាវែន៍ សួរចប់សិនបាទ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី ខ្ញុំជាចៅក្រម ឡាវែន៍ ខ្ញុំនៅចំពោះមុខលោកសាក្សី។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរតិចបំផុតដើម្បីសួរទៅលោកនេះ។ ពីដើមទីនេះ គេសួរលោកអំពីផ្ទះរបស់លោក ខៀវ សំផន នៅមន្ទីរក-៣។ ហើយចំពោះខ្ញុំ វាមានភាពស្រពេចស្រពិល តើលោកធ្លាប់មានឱកាសចូលមើលក្នុងផ្ទះរបស់ ខៀវ សំផន នេះដែរឬទេ?

[១១:៤២:១២]

**លោក ឡេង ឈឿង៖**

**ឆ៖** ចំពោះផ្ទះលោក ខៀវ សំផន នេះ ខ្ញុំដូចមិនមានដែលចូលអីទៅបោសច្រាស់អីក៏អត់ទេ ខ្ញុំអត់មានសិទ្ធិ។ ចង់និយាយថា អ្នកតែកុងឡាន គេនៅខាងក្រៅគឺខាងក្រៅ។

**ស៖** ពីព្រោះថាអ៊ីចេះ យើងបានឮលោកឆ្លើយទាក់ទងទៅនឹងសម្ភារៈដែលមាននៅក្នុងផ្ទះរបស់លោក ខៀវ សំផន នោះ។ លោកបាននិយាយថា ពុំមានការិយាល័យ មានទូរស័ព្ទ លោកបានពិពណ៌នាលើគ្រឿងសង្ហារមមួយចំនួនដែលទៅកាន់ផ្ទះនេះ។ តើលោកអាចពន្យល់បានដែរឬទេ ថាដោយសារលោកមិនបានចូលទៅក្នុងផ្ទះហ្នឹងទេ ហើយលោកបែជាមានសមត្ថភាពក្នុងការពិពណ៌នាអ្វីៗដែលមាននៅក្នុងផ្ទះនេះទៅវិញ។ លោកបានពន្យល់បានទេ ត្រង់ចំណុចនេះ?

**ឆ៖** បាទ អានេះ ខ្ញុំអាចពន្យល់បានព្រោះមូលហេតុដែលផ្ទះហ្នឹងមើលឃើញពីក្រៅទៅ មើលមកឃើញអ៊ីចឹង ឃើញកញ្ចក់ មើលទៅឃើញផ្ទះហ្នឹងត្រូវរៀបអីៗ មើលឃើញពីឃើញពីក្រៅ អើតទៅឃើញពីក្រៅមក។ អ៊ីចឹង ខ្ញុំឃើញតែប៉ុណ្ណឹង ឃើញតែពីក្រៅអ៊ីចឹងឯង ខ្ញុំមិនបានចូលទៅផ្ទះគាត់ទេ។ មើលពីក្រៅទៅឃើញ។

[១១:៤៤:០២]

**ស៖** បាទ សូមសួរសំណួរមួយទៀត លោកបានឆ្លើយថា ក្នុងឱកាសមួយចំនួនដែលលោក

និយាយថាកម្រណាស់ លោកបានជូនលោក ខៀវ សំផន ទៅក្រៅភ្នំពេញ។ នេះលោកបានប្រើពាក្យថា "នៅជុំវិញភ្នំពេញ" នេះជាពាក្យរបស់លោក។ លោកក៏បានជូនលោក ខៀវ សំផន នៅក្នុងភ្នំពេញផងដែរ។ លោកសាក្សី តើនៅពេលដែលលោកត្រូវជូនលោក ខៀវ សំផន ទៅណានោះ លោកត្រូវមានលិខិតអនុញ្ញាតជាក់លាក់ណាទេ? តើលោកត្រូវបានគេត្រួតពិនិត្យទេ ដើម្បីឲ្យដឹងថានៅក្នុងឡាននោះមានអ្នកណាខ្លះ ហើយឲ្យដឹងថាតើឡានទ្រុំងទៅណា?

**ផ៖** បាទ អានេះវាអត់ដឹងទេ ព្រោះឡានទៅណាៗក៏គាត់អត់ដែលប្រាប់ទៅណាដែល ជិតៗហ្នឹងគាត់ អត់មានទៅណា គ្មានអ្នកដឹងទេ ចង់និយាយថា សូម្បីតែអ្នកបើកឡានខ្លួនឯងក៏អត់ដឹងដែរ។

[១១:៤៥:៣៧]

**ស៖** បាទ ខ្ញុំសូមចោទសំណួរខ្ញុំឡើងវិញ។ តើគេមានឆែកឆេរលោកដែរឬទេ? តើគេ លោកមានបានសុំការអនុញ្ញាតដើម្បីទៅកន្លែងណាមួយទេ ពីព្រោះថាពេលដែលលោកចេញទៅក្រៅភ្នំពេញគេមានដែលសួរឆែកឆេរលោកថាមានលិខិតអនុញ្ញាតអីដែរឬទេ?

**ផ៖** ដូចអត់ផង អត់មានលិខិតអីផង អត់ដែលឆែកអត់មានពីណាឆែកអីផង។

**ស៖** បាទ សូមសួរសំណួរមួយទៀត។ លោកបានពិពណ៌នាឡានដែលលោក ខៀវ សំផន ប្រើប្រាស់ តើលោកអាចជម្រាបជូនតុលាការដែរឬទេ ឬឡានហ្នឹង ឬក៏ឡានរបស់អ្នកដឹកនាំផ្សេងទៀតហ្នឹងមានស្លាកសម្គាល់? តើលោកដឹងទេ មានសង្កេតឃើញអីចឹងទេ?

**ផ៖** ខ្ញុំអត់បានសង្កេតឃើញអីចឹងដែរ ប៉ុន្តែឡាន បើឡានគាត់ធ្លាប់ជិះហ្នឹងគេអាចអ្នកកន្លែងបើកទ្វារអាចស្គាល់ហ្នឹង បានគេបើក ហើយគាត់អត់មានបិទបាំងអីផងជិះទៅ។

**ស៖** បាទ ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើឡានលោក ខៀវ សំផន នោះមានស្លាកលេខដែរឬទេ? ខ្ញុំមិនសួរថា ឡានហ្នឹងមានបិទបាំងអីនោះទេ ខ្ញុំគ្រាន់តែចង់ដឹងថាតើឡានហ្នឹងមានស្លាកលេខដែរឬក៏អត់?

[១១:៤៨:០១]

**ផ៖** បាទ ខ្ញុំសូមជម្រាបលោកតុលាការថា ខ្ញុំមិនចាំទេ អារឿងស្លាកលេខ ស្លាកអីនោះ ព្រោះអត់ដឹងមានអត់ជំនាន់នោះ ខ្ញុំអត់ដឹង។ ខ្ញុំនៅតូច ខ្ញុំអត់ដឹងដែរ ព្រោះអត់ដឹង អត់បានចាប់អារម្មណ៍មកដល់សព្វថ្ងៃនេះភ្លេចអស់ហើយ អត់ដឹងទេ។

**ស៖** តើលោកធ្លាប់បានឃើញឡានផ្សេងទៀតដែលមានស្លាកលេខដែរឬទេ? ឬក៏លោកមិនដែល

បានកត់សម្គាល់ថាមានស្លាកលេខនៅលើឡាននោះទេ ឡានដែលគេប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំអត់បានកត់សម្គាល់លើស្លាកលេខអីទេ។ គឺសម័យហ្នឹង គឺខ្ញុំនៅតូចដែរ ខ្ញុំមិនបានចាប់អារម្មណ៍ ហើយដល់សព្វថ្ងៃនេះបានដឹងថាមានស្លាកលេខ។ ពីមុនមកដូចមិនមានធ្វើអីផង។

**ស៖** សាក្សីដែលយើងបានស្តាប់ថ្មីៗនេះបានរៀបរាប់អំពីឡានមួយដែលមានស្លាកលេខដោយមានសរសេរជាពណ៌ក្រហមពាក្យថា ម-៨៧០។ តើចំណុចនេះៗធ្វើឲ្យលោកនឹកឃើញទេ?

**ឆ៖** ខ្ញុំអត់មាននឹកឃើញផង ព្រោះអត់មានដឹងថាមានស្លាកលេខអីផងឡានហ្នឹង គឺនឹកអត់មានឃើញទេ គឺខ្ញុំមកបើកឡានដឹងតែបើកឡាន មិនដឹងថាមានស្លាកលេខ ឬមិនមានស្លាកលេខទេ។

[១១:៥០:១៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំសួរចប់ហើយ សូមអរគុណលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានសូមអភ័យទោស ដើម្បីជាកំណត់ហេតុប្រតិចារឹក សាក្សីដែលលោកចៅក្រមបាននិយាយអម្បាញ់មិញនេះ នៅពេលដែលគាត់ឆ្លើយនៅក្នុងសវនាការនេះ នៅពេលមេធាវី អាកទួរវែកគែន នោះសួរគាត់នោះ គាត់បាននិយាយថាម-៧០ ទេ មិនមែន ម-៨៧០ ទេ លោកប្រធាន។ នេះគ្រាន់តែសូមបញ្ជាក់បំភ្លឺចំណុចនេះបន្តិច។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា!

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។ សូមជម្រាបសួរលោក ឡេង ឈឿង ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី ជាសហព្រះរាជអាជ្ញារងជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាបន្តទៅនេះ ខ្ញុំសូមជម្រាបសួរលោកមួយចំនួន នូវសំណួរមួយចំនួន ដែលសំណួរនេះគឺខ្ញុំសួរក្នុងនាមតំណាងសហព្រះរាជអាជ្ញា។

[១១:៥១:២៩]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ច័ន្ទ តារាស្រី៖**

**ស៖** សូមលោកជួយបញ្ជាក់នូវចន្លោះពេលឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៦។ ខ្ញុំចង់ដឹងថា តើនៅពេលនោះលោកនៅអាយុ១០ឆ្នាំ។ តើមែនដែរឬទេ?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ ១០ឆ្នាំ។

**ស៖** បាទ អរគុណ។ តើនៅពេលនោះ លោកសម្រេចចិត្តចូលរួមក្នុងចលនាបដិវត្តន៍ដោយខ្លួនឯង ឬក៏ការសម្រេចចូលរួមនេះដោយសារតែឪពុកម្តាយរបស់លោកជាអ្នកសម្រេចឲ្យលោកចូលរួមក្នុងចលនាបដិវត្តន៍?

**ឆ៖** បាទ ដោយខ្លួនឯងៗ ឪពុកម្តាយឃាត់ឃាំងទេ ប៉ុន្តែត្រូវតែមក។

[១១:៥២:២២]

**ស៖** បាទ តើមានហេតុផលអ្វីបានជាលោកចូលរួមក្នុងចលនាបដិវត្តន៍ក្នុងសម័យកាលនោះ?

**ឆ៖** មានមេភូមិគេសួរទៅ ចុះក្នុងសាលាតាមភូមិក្រោមផ្ទះហ្នឹង ដល់អ៊ីចឹងរៀនទៅៗ គេមកសួរក្រុមកុមារហ្នឹង អ្នកណាចង់ចូលជួរក្នុងបម្រើបដិវត្តន៍ -- ដល់អ៊ីចឹងទៅ គេត្រូវតែ -- ចេះតែលើកដៃតាមគ្នាទៅ ចេះតែថាមកទៅ ដល់ពេលខ្លះទៅប្រធានភូមិសម្រេចអត់មក ពេលជាមួយខ្ញុំនោះមានអត់មកច្រើនដែរ។ ដល់អ៊ីចឹងខ្ញុំសម្រេចចិត្តថាមក ឪពុកម្តាយឃាត់ដែរ តែចេះមកៗ។

**ស៖** បាទ តើនៅពេលនោះអង្គការ ឬក៏មេភូមិហ្នឹងបានពន្យល់ប្រាប់លោកយ៉ាងដូចម្តេចក្នុងការអូសទាញឲ្យកុមារចូលរួមក្នុងចលនាបដិវត្តន៍ក្នុងសម័យកាលនោះ?

**ឆ៖** គេអូសទាញអ៊ីចឹងហើយ អប់រំណែនាំវាយូរឆ្នាំហើយ វាភ្លេចអស់ហើយ។ ខ្ញុំមិនដឹងរៀននិយាយម៉េចខ្លះ ប៉ុន្តែដឹងថាគេអប់រំណែនាំ បើមិនមានចលនាអប់រំណែនាំក៏មិនមានមកដែរ ព្រោះមូលហេតុអ៊ីចឹង ប៉ុន្តែឪពុកម្តាយឃាត់ដែរ ប៉ុន្តែឃាត់អីបានទៅលើកដៃថាទៅនឹងគេហើយ ត្រូវតែមក។

[១១:៥៣:៥២]

**ស៖** បាទ សូមអរគុណ។ តើនៅពេលនោះមានបងប្អូនប្រុស ឬក៏បងប្អូនស្រីរបស់លោកបានចូលរួមក្នុងចលនាហ្នឹងបដិវត្តន៍ហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់ទេ មានតែខ្ញុំម្នាក់ឯង។

**ស៖** បាទ សូមអរគុណ។ សូមលោកជួយបញ្ជាក់ថា តើក្នុងពេលដែលគេរំដោះតំបន់ត្រាំខ្នារនៅតំបន់ភូមិភាគនិរតី តើការរំដោះនោះគឺរំដោះដោយសារកងកម្លាំងណា? ហើយរំដោះក្នុងពេលណា?

**ឆ៖** គឺរំដោះត្រាំខ្នារហ្នឹង គឺកងកម្លាំងកម្ពុជាប្រជាធិបតេយ្យហ្នឹងឯងវ៉ៃចូលមករំដោះឆ្នាំ១៩៧៣។ ខ្ញុំចាំៗតែមិនចាំខែ ប៉ុន្តែដឹងថាឆ្នាំ១៩៧៣ ក្រោយរំដោះមក គេបញ្ជូនខ្ញុំមកនៅហ្នឹងត្រាំខ្នារហ្នឹងតែម្តង។

**ស៖** នៅពេលដែលកងកម្លាំងរំដោះចូលទៅតំបន់ត្រាំខ្នារ តើលោកមានបានចងចាំទេថា កងកម្លាំងហ្នឹងបាននិយាយប្រាប់អ្វីខ្លះទៅប្រជាជន ឬក៏លោកបានចងចាំនៅពាក្យសម្តីអ្វីដែលកងកម្លាំងរំដោះបដិវត្តន៍ហ្នឹងបានប្រាប់លោក ឬក៏ប្រជាជននៅពេលនោះ?

**ឆ៖** ពេលរំដោះត្រាំខ្នារនេះអត់ឃើញមានប្រជាជនទេ គឺទៅបាត់ -- ទៅណាអស់ចេញពីត្រាំខ្នារអត់មានប្រជាជននៅទេ មានតែកងខ្ញុំ។ ខ្ញុំនៅកងកុមារមានតែកងកុមារ ហើយនិងកងនារី ដែលដឹកជញ្ជូន រៀបចំសម្ភារៈ អត់មានឃើញមានប្រជាជនទេ។

[១១:៥៥:៤៨]

**ស៖** សូមលោកជួយបញ្ជាក់ថា នៅពេលដែលលោកស្ថិតនៅក្នុងកងកុមារបដិវត្តន៍នៅក្នុងឆ្នាំ១៩៧៣ ក្នុងឆ្នាំ១៩៧៤ និងឆ្នាំ១៩៧៦ តើអង្គការបានប្រើប្រាស់កងកុមារហ្នឹងយ៉ាងដូចម្តេច? ហើយលោកផ្ទាល់ តើលោកទទួលមុខងារភារកិច្ចធ្វើអ្វីខ្លះនៅក្នុងកងកុមារបដិវត្តន៍នោះ?

**ឆ៖** កាលហ្នឹងខ្ញុំលើកទំនប់ ជីកប្រឡាយដូចតែគ្នា។ លើកទំនប់ ជីប្រឡាយនៅត្រាំខ្នារហ្នឹងលើក។

**ឆ៖** បាទ សូមអរគុណ។ នៅពេលដែលលោកនៅជាកងកុមារភាពអាយុប្រហែល១០ ទៅ ១១ឆ្នាំ អង្គការបានប្រើប្រាស់លោកឲ្យធ្វើជា គេហៅថា កងកម្លាំងមួយដែលជីកប្រឡាយ ឬក៏លើកទំនប់។ តើការងារនេះមានភាពធ្ងន់ធ្ងរចំពោះកុមារ តើលោកមានបានប្រកែកតវ៉ា ឬក៏កងកុមារដទៃទៀតបានប្រកែកតវ៉ាចំពោះការប្រើកម្លាំងកុមារនៅពេលនោះដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[១១:៥៧:០៧]

**ស៖** សូមលោកឆ្លើយម្តងទៀតបាទ?

**ឆ៖** ដូចជាអត់មានបង្ខិតបង្ខំអី កាលខ្ញុំនៅនុ៎ងដូចអត់មានបង្ខិតបង្ខំអី ខ្ញុំ -- អ្នកឈឺក៏ឈឺទៅ អ្នកណាអត់ឈឺទៅធ្វើការងារទៅ ធម្មតា ដូច --

**ស៖** អរគុណ។ សូមលោកជួយបញ្ជាក់ថា ហេតុអ្វីបានជាគេប្រើកុមារដែលមានវ័យអាយុទើបតែ ១០-១១ឆ្នាំ ឬក៏លើសបន្តិចបន្តួចឲ្យធ្វើការងារដ៏ធ្ងន់ធ្ងរបែបនេះ? តើអង្គការបានពន្យល់ហេតុផលអ្វីខ្លះដែលបាន -- មូលហេតុដែលគេធ្វើការងារបែបនេះ ជំរុញឲ្យកុមារធ្វើការងារដែលមានលក្ខណៈធ្ងន់ធ្ងរបែបនេះ?

[១១:៥៧:៥៩]

**ផ៖** បាទ កាលនោះ ខ្ញុំអត់ដឹងដែរ ឲ្យធ្វើក៏ធ្វើ បើយើងធ្វើរួចក៏ធ្វើទៅ បើអត់ធ្វើរួចក៏តាមដំណើរហ្នឹង។ ខ្ញុំអត់ដឹងថាមានឃើញបង្ខិតបង្ខំកម្លាំងដែលត្រូវធ្វើពលកម្មហ្នឹង បង្ខិតបង្ខំផងចំពោះខ្លួនខ្ញុំ ហើយនិងកុមារដែលនៅកងជាមួយគ្នាហ្នឹង ដូចអត់មានដឹងថា គេបង្ខិតបង្ខំអីផងទៅធ្វើដោយស្ម័គ្រចិត្ត ប៉ុន្តែចេះតែមានកងគេប្រាប់យើងឲ្យទៅធ្វើនេះ ដាក់ផែនការ ប្រជុំល្ងាចហ្នឹងដាក់ផែនការទៅធ្វើការ។ ប៉ុន្តែឲ្យបង្ខិតបង្ខំអត់ ថាឈឺឈប់ បើអត់ឈឺទៅធ្វើការធម្មតា។

**ស៖** បាទ នៅពេលដែលកុមារមិនធ្វើការ តើមានវិធានការទណ្ឌកម្ម ឬក៏ទទួលនូវការធ្វើបាបចំពោះកុមារដែរឬទេ? តើមានវិន័យតឹងតែងអ្វីខ្លះដែលកុមារត្រូវធ្វើខានមិនបាន ឬក៏មិនមានការបង្ខិតបង្ខំទេនៅពេលនោះ ចំពោះកុមារជាទូទៅ?

[១១:៥៩:០០]

**ផ៖** បាទ ពេលនោះ គឺដូចអត់មានបង្ខិតបង្ខំអីទេ ហើយកុមារទូទៅខ្ញុំអត់ដឹងដែរ ប៉ុន្តែចំពោះកុមារអង្គភាពខ្ញុំ ខ្ញុំដឹងថានៅរស់នៅជាមួយគ្នា ដឹងដូចថាអត់មានពីណាគេបង្ខិតបង្ខំអីផង។ ខ្ញុំដឹងតែក្នុងនិយាយរួម ដឹងតែកន្លែងខ្ញុំ។ ដឹងតែអង្គភាពកន្លែងកុមារជាមួយគ្នាហ្នឹង។ បើកន្លែងផ្សេងខ្ញុំមិនបានដើរទៅរហេតរហូតដែរទេ។ ត្រូវតែគោរពអង្គការវិន័យ ហើយបើសិនជានេះអត់មានបង្ខិតបង្ខំអីទេ ប៉ុន្តែមានតែរឿងមួយដែលត្រូវថា យើងគិតថា បង្ខិតបង្ខំគឺគ្រាន់តែប្រជុំដើម្បីដកពិសោធ ហើយនិងដាក់វិធានការ ដែលដើម្បីថាត្រូវតែធ្វើអត់ បើអ្នកហ្នឹងបើថាសេរី កាលហ្នឹង ជំនាន់ហ្នឹង គេនិយាយថាសេរីមិនធ្វើការងារប្រជុំថា ដែលសេរីមូលហេតុអី បើយើងមិនធ្វើអាហ្នឹងរឿងផ្សេង។ ប៉ុន្តែខ្ញុំអត់ដែលដឹងរឿងអី ប៉ុន្តែចំពោះកងកុមារក្រុមពួកខ្ញុំហ្នឹង ដូចអត់ដែលមានបញ្ហាអី។ ខ្ញុំក្តាប់មិនបានដែរ។ ទី១ក្តាប់មិនបាន។ ទី២ ចំពោះខ្លួនខ្ញុំក៏មិនទាន់យល់ហៅថា ដូចសព្វថ្ងៃនេះទេ។ អង្កាល់នុំងវានៅតូចដែរ ហើយក៏ការអប់រំខាងហ្នឹងក៏អត់មានបានយល់អីដែរ។ ដល់អីចឹងវាអាចមិនដឹងពលកម្មលើកុមារនេះ មិនដឹងថា យ៉ាងម៉េចដែរ។ អត់ដឹងកាលជំនាន់ហ្នឹង។

[១២:០០:១១]

**ស៖** បាទសូមអរគុណ។ ជាបន្តទៀត ខ្ញុំចង់ដឹងថានៅពេលនោះមានការបំបែកកុមារ ពីឪពុកម្តាយរបស់ខ្លួន។ បានន័យថា ឲ្យកុមារនិងឪពុកម្តាយហ្នឹងរស់នៅឆ្ងាយពីគ្នា។ សូមលោកជួយបញ្ជាក់ថាតើការពិតមែនដែរឬទេ ឬក៏គ្មានការបំបែក? តើការបំបែកឲ្យរស់នៅឆ្ងាយពីគ្នាមានជាទូទៅនៅគ្រប់ទីកន្លែង ឬក៏យ៉ាងម៉េចបាទ?

**ឆ៖** រឿងនេះ ខ្ញុំមិនបានដឹងទេ ប៉ុន្តែបើចំពោះខ្លួនខ្ញុំវិញស្ម័គ្រចិត្ត។ បើរឿងផ្សេង ខ្ញុំអត់បានដឹងទេបាទ។

**ស៖** អរគុណ តើពេលនោះលោករស់នៅបែកពីក្រុមគ្រួសារ ហើយលោករស់នៅក្នុងកងកុមារហ្នឹង តើលោកជួបប្រទះនូវបញ្ហាលំបាកអ្វីខ្លះនៅក្នុងការរស់នៅបែកពីឪពុកម្តាយនៅក្នុងកងកុមារបដិវត្តន៍ក្នុងសម័យកាលនោះ?

[១២:០១:០៩]

**ឆ៖** បាទនឹកឃើញយំ នឹកឪពុកម្តាយដូចតែគ្នាហ្នឹង ប៉ុន្តែនឹកឃើញថាគេមកហើយ មកហើយត្រូវតែខំ គេប្រជុំអត់អប់រំណែនាំទៅចេះតែធ្វើតាម។

**ស៖** លោកបានលះបង់ជីវិតរបស់លោក ពេលវេលា និងការខិតខំប្រឹងប្រែង ដើម្បីបដិវត្តន៍ តើរហូតមកដល់ពេលដែលបែក មានន័យថាក្រោយ៧៩ តើលោកបានគិតអ្វីដែលលោកបានធ្វើក្នុងអំឡុងពេលនៃការធ្វើបដិវត្តន៍នោះ លោកមានការសោកស្តាយ ឬមានវិប្បដិសារីចំពោះសកម្មភាពដែលរបស់ខ្មែរក្រហមបានធ្វើចំពោះលោកដែរឬទេ?

**ឆ៖** បាទចំពោះខ្លួនខ្ញុំ ដូចមានអីផង អត់មានអី។ ព្រោះទី១ នៅតូច ប៉ុន្តែទី២ រស់នៅតែកន្លែងដែលនៅកន្លែងធម្មតាអីចឹងទៅ ហើយគោរពអង្គការវិន័យ។ ជំនាន់នោះគោរពអង្គការវិន័យទៅ អត់ដែល ដូចអត់មានគេធ្វើបាបអី។ ដល់អីចឹងវិប្បដិសារីនៅក្នុងសង្គមហ្នឹងក៏អត់មានអីដែរ។ ខ្ញុំអត់មានអត់ដឹងថា --

**ស៖** បាទអរគុណ។ នៅក្នុងរបបខ្មែរក្រហម តើលោកបានទទួលការអប់រំក្នុងវគ្គអប់រំនយោបាយអ្វីខ្លះ? តើអ្នកណាខ្លះដែលបានចូលធ្វើជាអ្នកឧទ្ទេសនាម បង្ហាត់បង្រៀនដល់លោក ក្នុងនាមលោកធ្វើជាកុមារនៅក្នុងសម័យកាលនោះ?

[១២:០២:៥១]

**ឆ៖** ដូចជាមិនដែលបានរៀនវគ្គធំដុំអីផង បើប្រជុំកុមារគ្នាឯងហ្នឹង មានតែគេប្រជុំមេក្រុម មេអីហ្នឹង ប្រជុំអត់ដែលបានវគ្គធំដុំៗ អត់ដែលទេ។

**លោក ច័ន្ទ តារាស្មី៖**

បាទលោកប្រធាន ប្រហែលជាដល់ម៉ោងសម្រាកហើយ បាទលោកប្រធាន។ បើសិនជាលោកប្រធាន ខ្ញុំគិតថាប្រហែលជាសំណួរខ្ញុំនឹងបន្តនៅក្រោយពេលសម្រាកចូលវិញនៅពេលរសៀលបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាបសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រងចាំ សម្រាប់សាក្សី ឬអ្នកជំនាញ ឬកន្លែងណាមួយសមស្របសម្រាប់សាក្សីនេះសម្រាកនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់នេះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលារសៀលនេះ វេលាម៉ោងមួយសាមសិបនាទី រួមទាំងមេធាវីប្រឹក្សារបស់គាត់ផង។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក ខៀវ សំផន ទៅកាន់បន្ទប់រងចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលមកកាន់ មកចូលរួមនៅក្នុងសវនាការនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ច័ន្ទ តារាស្មី៖**

បាទ សូមគោរពសាជាថ្មីចំពោះលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ និងអង្គសវនាការទាំងមូល។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** នៅពេលនេះ ខ្ញុំសូមបន្តសំណួរទៅទៀត សួរលោក ឡុង ឈឿង។ ឡុង ឈឿង ខ្ញុំសូមបន្តសំណួរមួយចំនួនទៀតមុននឹងខ្ញុំផ្តល់វេទិកាជូនទៅសហការីរបស់ខ្ញុំ។

ព្រឹកមិញលោកបានបញ្ជាក់ថា លោកបានទទួលការបណ្តុះបណ្តាល ឬក៏ការអប់រំក្នុងវគ្គនយោបាយ ឬវគ្គអប់រំនៅក្នុងរបបខ្មែរក្រហម។ សូមលោកជួយបញ្ជាក់ថា តើការអប់រំនៅពេលនោះ លោកបានទទួលនូវចំណេះដឹង ឬការយល់ដឹងអ្វីខ្លះពីវគ្គអប់រំនោះ បាទ?

**លោក ឡុង ឈឿង៖**

**ឆ៖** វគ្គអប់រំនោះ គឺមិនមែនជាវគ្គធំដុំទេ គឺប្រជុំផ្សព្វផ្សាយរវាងតាមក្រុមនីមួយៗតាមក្រុមនោះ។ មិនជាវគ្គអីធំដុំទេ។

**ស៖** អរគុណ។ តើក្នុងវគ្គនោះគេប្រាប់លោក ពន្យល់ប្រាប់លោកអំពីខ្លឹមសារអ្វីខ្លះ?

**ឆ៖** ដូចជាមិនចាំ យូរហើយ និងមិន -- អត់ចាំទេ។

**ស៖** បាទសំណួរមួយទៀតសូមសួរថា នៅពេលដែលលោកនៅក្នុងរបបខ្មែរក្រហមនោះប្រហែលជាលោកបានឮពាក្យដែលកម្មាភិបាលខ្មែរក្រហមធ្លាប់បានប្រើពាក្យដូចជាពួកមូលធននិយម ពួកសក្តិភូមិ ពួកគហបតី ពួកចក្រពត្តិនិយម ឬក៏ពួកបញ្ញវន្ត ដែលពាក្យទាំងអស់នេះ តើលោកធ្លាប់បានឮផ្ទាល់នឹងត្រចៀកនៅក្នុងពេលដែលលោករស់នៅក្នុងតំបន់ដែលលោករស់នៅហ្នឹងដែរឬទេ?

[១៣:៣៤:៥៧]

**ឆ៖** បាទ ជាយោបល់នេះ គឺខ្ញុំបានឮ ដូចគាត់សំណួរនេះ ដូចធ្លាប់បានឮ ប៉ុន្តែគេនិយាយអប់រំណែនាំ ឮ។

**ស៖** បាទ តើពាក្យទាំងអស់នេះ កម្មាភិបាលខ្មែរក្រហមបានប្រើពាក្យនេះពន្យល់លោក ពន្យល់ប្រជាជនដទៃទៀតក្នុងន័យយ៉ាងដូចម្តេច? តើប្រាប់អត្ថន័យហ្នឹងក្នុងន័យយ៉ាងដូចម្តេច? សូមលោកជួយបញ្ជាក់អំពីអត្ថន័យដែលកម្មាភិបាលខ្មែរក្រហមបានប្រើប្រាស់ពាក្យនេះនៅក្នុងសម័យកាលនោះ?

**ឆ៖** អត់ដឹង។ ខ្ញុំអត់ចាំដែរ អាពាក្យហ្នឹងវាមិនចាំ។

**ស៖** អរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរសំណួរលោកនៅក្នុងឆ្នាំ១៩៧៦ ទាក់ទងទៅនឹងការចេញដំណើរឆ្ពោះទៅទីក្រុងភ្នំពេញ និងការធ្វើការងារនៅក-១២។ តើលោកបានវិលត្រឡប់នៅក្នុងក-១២ ធ្វើការងារនៅក-១២ ហ្នឹង នៅពេលណា? ហើយពីឆ្នាំណា ដល់ឆ្នាំណា?

[១៣:៣៦:១៣]

**ឆ៖** បាទ នៅចូលធ្វើការងារនៅក-១២ ហ្នឹង តាំងពីឆ្នាំ១៩៧៦ ប៉ុន្តែខែឆ្នាំ ខ្ញុំអត់ចាំទេ។

**ស៖** អរគុណ។ តើនៅក្នុងក-១២ ហ្នឹង លោកធ្វើកិច្ចការអ្វីខ្លះ? គេបានប្រើលោកឲ្យធ្វើកិច្ចការអ្វីខ្លះ?

**ឆ៖** កាលហ្នឹង ខ្ញុំនៅកុមារគឺបោសសម្អាតផ្ទះសម្បែង។ ពេលចង់នៅផ្ទះណា ទៅបោសសម្អាតលាង។

**ស៖** បាទ តើលោកអាចពន្យល់បានទេ ថាតើក-១២ ហ្នឹង គេបង្កើតឡើងក្នុងបំណងអ្វី? តើក្នុងក-១២ ហ្នឹង លោកឃើញថា គេធ្វើសកម្មភាពអ្វីខ្លះនៅក្នុងក-១២ ទាំងមូលហ្នឹង?

**ឆ៖** ក-១២ ហ្នឹង ខ្ញុំអត់ដឹងយ៉ាងម៉េចដែរ ប៉ុន្តែឃើញតែអ្នកធំៗគេបើកឡាន។ អ្នកតូចៗ កុមារអីចឹង គេបើកឡានទៅណាមិនដឹងទេ បើកឡាន។ មានគ្នាបើកឡានច្រើនអីចឹង គេចាត់ចែងទៅណា ខ្ញុំអត់ដឹងទេ។ ប៉ុន្តែខ្ញុំកុមារហ្នឹង ខ្ញុំនៅបោសសម្អាតផ្ទះ។

**ស៖** បាទ នៅក្នុង ក-១២ ហ្នឹង លោកឃើញកុមារ ឬក៏មានយុវជន ឬក៏មនុស្សចាស់នៅក្នុងក-១២ ហ្នឹង គេធ្វើសកម្មភាពអ្វីខ្លះ? តើគេធ្វើការងារអ្វីខ្លះនៅក្នុងក-១២ ហ្នឹង? ក្រៅរូបលោក ហើយលោកឃើញមានយុវជន ឬក៏មនុស្សចាស់នៅក្នុងក-១២ តើគេធ្វើអ្វីខ្លះនៅក្នុងនោះ នៅពេលនោះបាទ?

[១៣:៣៧:៥១]

**ឆ៖** បាទ គេបើកឡាន បើកបរចេញ។

**ស៖** អរគុណ។ តើក-១២ ហ្នឹង លោកអាចបញ្ជាក់ជូនអង្គសវនាការបានទេ ថាមានរចនាសម្ព័ន្ធយ៉ាងដូចម្តេច? តើក-១២ ហ្នឹង មានប្រធាន អនុប្រធាន ឬក៏បែងចែកជាផ្នែកអ្វីខ្លះនៅក្នុងក-១២ ហ្នឹងបាទ?

**ឆ៖** ប្រធាន ឬអនុប្រធាន ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំនៅកុមារ។ នៅកុមារដឹងគេឲ្យធ្វើអី ដូចអត់ដឹងទាំងអស់នៅសម័យហ្នឹង គឺមានតែគេប្រជុំកុមារមក ប្រជុំកុមារឲ្យធ្វើអី ព្រឹកឡើងដាក់ផែនការធ្វើអី ទៅធ្វើការ។

**ស៖** តើលោកស្គាល់ តាមៀល ទេបាទ។ តាមៀល លោកស្គាល់ទេ តើតាមៀល ជាអ្នកណា?

**ឆ៖** តាមៀល ហ្នឹងស្គាល់។ គេថាប្រធានមន្ទីរ គេហៅប្រធានមន្ទីរ តាមៀល ហ្នឹង។

[១៣:៣៩:០៨]

**ស៖** តើគាត់ជាប្រធានមន្ទីរក-១២ ឬក៏ប្រធានមន្ទីរណា?

**ឆ៖** តាមៀល ហ្នឹង ប្រធានមន្ទីរក-១២ ហ្នឹង។

**ស៖** ចុះអនុប្រធានក-១២ តើនរណាគេទៅ ឬក៏មានបុគ្គលប៉ុន្មាននាក់ដែលជាអនុប្រធាន ក-១២? តើក-១២ មានអនុប្រធានប៉ុន្មាននាក់ ហើយមានឈ្មោះអ្វី? តើលោកអាចរៀបរាប់បានទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ អនុប្រធានអី អត់ដឹងទាំងអស់។

**ស៖** អរគុណ។ តើលោកស្គាល់កម្មាភិបាលឈ្មោះ សឿន -- សារឿន ឈ្មោះ សារឿន ទេបាទ កម្មាភិបាលឈ្មោះ សារឿន ហើយនិងឈ្មោះ យ៉ង់ៗ? តើលោកស្គាល់លោកទាំងពីរនាក់ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់ទេ សារឿន ហ្នឹង យ៉ង់ ហ្នឹងក៏អត់ស្គាល់ដែរ។

**ស៖** បាទ អរគុណ។ តើលោកអាចរំឭកការចងចាំបានដែរឬទេ ថាមានរឿងអ្វីកើតឡើងចំពោះកម្មាភិបាល ឈ្មោះ តាមៀល? តើ តាមៀល ហ្នឹងមានរឿងអ្វីកើតឡើងចំពោះគាត់?

**ឆ៖** ខ្ញុំអត់ដឹងដែរ អាហ្នឹងអត់ដឹងរឿងហ្នឹងរឿង -- ទី១ ខ្ញុំនៅកុមារ ហើយទី២ ទៀត ខ្ញុំក៏មិនបានដឹងរឿងអីច្រើនជាងហ្នឹងដែរ។

**ស៖** លោកអាចរំឭកអំពីព្រឹត្តិការណ៍ដែលកើតឡើងឆ្នាំ១៩៧៨ តើលោកអាចបញ្ជាក់ជូនអង្គសវនាការបានដែរទេថា តើកម្មាភិបាលណាខ្លះបានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៨? លោកអាចចងចាំឬក៏អ្នកដឹកនាំណាខ្លះដែលលោកនៅក្បែរ ឬក៏ស្គាល់ច្បាស់ ហើយបានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៨?

[១៣:៤១:៣៥]

**ឆ៖** ដូចជាអត់មានស្គាល់អ្នកណាទេ ខ្ញុំដូចមិនស្គាល់ទេ។

**ស៖** បាទ លោក ឡេង ឈឿង ខ្ញុំសូមរំឭកអំពីចម្លើយរបស់លោក។

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានជូននូវខ្លឹមសារនៃការឆ្លើយរបស់គាត់នៅក្នុងកំណត់ចម្លើយដែលគាត់បានឆ្លើយជាមួយនឹងមន្ត្រីស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឯកសារដដែលដូចជាឯកសារដែលមេធាវីការពារក្តីបានលើកឡើងនោះ បាទ។

ខ្ញុំសូមអនុញ្ញាតលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

លោកបង្ហាញអំពីលេខ ERN ផង លេខដដែលក៏បញ្ជាក់ផងដែរ ដើម្បីជាប្រតិចារឹក។

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធានអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ឯកសារនេះគឺ E3/385 ដែលមានលេខ ERN ជាភាសាបារាំង 00702543, ERN ជាភាសាអង់គ្លេស 00360127, ERN ជាភាសាខ្មែរ 00357210។ នៅក្នុងឯកសារនេះ គាត់បានឆ្លើយថា "គេបញ្ជូនខ្ញុំទៅមន្ទីរក-១២ ហើយគេឱ្យខ្ញុំបោសសម្អាត។ ខ្ញុំដឹងថាកន្លែងនោះជាមន្ទីរក-១២ ដោយសារអ្នកមុនៗប្រាប់ថានេះជាមន្ទីរក-១២។ តាមៀល ជាប្រធានមន្ទីរក-១២។ តាមៀល ក្រោយមកត្រូវគេចាប់យកទៅសម្លាប់បាត់នៅក្នុងឆ្នាំ១៩៧៨។ ខ្ញុំឮគេនិយាយ -- ខ្ញុំនៅមន្ទីរក-១២ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨។ ពេលខ្ញុំនៅមន្ទីរក-១២ គេឱ្យខ្ញុំដើរតាមឡាន ដែលមានអ្នកមុនបើក ដើម្បីរៀនបើក"។ បាទ នេះគឺជាចម្លើយរបស់លោក តើមែនឬទេបាទ?

[១៣:៤៣:៥១]

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ ចម្លើយនេះគឺចម្លើយខ្ញុំឆ្លើយ។ ប៉ុន្តែដែលឮថា តាមៀល ដែលគេចាប់ខ្លួនហ្នឹង ក្រោយពីខ្ញុំទៅនៅ ទៅបើកឡានឱ្យលោក ខៀវ សំផន ទៅ បានឮគេនិយាយតៗគ្នាទេ ខ្ញុំចេញទៅនោះ។

**ស៖** បាទ អរគុណ។ ចំពោះលោក សារឿន តើលោកអាចរំឭកបានអំពីការណ៍ដែលមានរឿងអ្វីកើតឡើងចំពោះលោក សារឿន ដែរឬទេ នៅក្នុងសម័យកាលនោះ?

**ឆ៖** ខ្ញុំដូចជាអត់ចាំលោក សារឿន នោះទេ។

**ស៖** ចុះលោកស្គាល់លោក ទន ទេបាទ? លោក ទន គឺជានរណា? លោក ទន!

**ឆ៖** ខ្ញុំចាំមិនបានទេ ដឹង ទន ណា៎។

**ស៖** អរគុណ។ ចុះឈ្មោះ ភា លោកចាំទេ ឈ្មោះ ភា នៅក-១២ តើ ភា ជានរណាបាទ?

**ឆ៖** ខ្ញុំអត់មានចាំផង ឈ្មោះ ភា ហ្នឹង ខ្ញុំអត់ដែលស្គាល់ដែរ។

**ស៖** ចុះលោកស្គាល់ឈ្មោះ សុត ទេបាទ តើ សុត ហ្នឹងជានរណាបាទ?

**ឆ៖** បាទ លោក សុត ហ្នឹងស្គាល់។ គាត់តែងតែដឹកនាំខ្ញុំទៅណាមកណា បោសសម្អាតអីគាត់ប្រាប់ខ្ញុំ ដឹកនាំខ្ញុំទៅជួយមើលថែ ហើយបោស ហើយគាត់ដឹងគាត់ទៅណាទៀតបាត់ ដល់ហើយគាត់ --

**ស៖** តើលោក សុត គាត់ជាអ្នកបើកឡាន ឬក៏មិនមែនជាអ្នកបើកឡានដូចរូបលោកទេ?

**ឆ៖** គាត់បើកឡានដែរតើ ប៉ុន្តែគាត់ប្រាប់ខ្ញុំឲ្យធ្វើកាលពីខ្ញុំនៅកុមារហ្នឹង ក្រោយមកគាត់សួរហ្នឹងចុះឡើងៗ ខ្ញុំមិនដឹងឆ្លើយមុន ឬឆ្លើយក្រោយ ខ្ញុំមិន សួរថាពេលក្រោយ ឬពេលមុននោះ។ មុនខ្ញុំដែលមុននឹងបើកឡាន ខ្ញុំបោសសម្អាត ដល់អ៊ីចឹងក្រោយមកនេះ បានខ្ញុំចេះបើកឡានទៅ ដើរតាមគេចេះបើកឡានទៅ អាហ្នឹងបានវាដែលបញ្ជាក់ថាសួរពេលមុន ឬសួរពេលក្រោយ។ ដល់អ៊ីចឹងខ្ញុំមិនដឹងឯណាច្របូកច្របល់ អត់ដឹងអី។

[១៣:៤៦:២៨]

**ស៖** អរគុណ។ គឺខ្ញុំចង់ដឹងអំពីក្រោយមកថា តើលោក សុត ហ្នឹងគាត់មានតួនាទីជាអ្នកបើកឡានទៀត ឬដែរ ឬក៏មិនមែន? តើគាត់ទទួលភារកិច្ចបើកឡាន ឬក៏អត់ទេ?

**ឆ៖** សុត ហ្នឹងគាត់បើកឡាន។

**ស៖** អរគុណៗច្រើន តើលោក សុត បើកឡានឲ្យលោកណាដែរបាទ?

**ឆ៖** តាមខ្ញុំឃើញៗគាត់បើក គាត់បើកឲ្យលោក នួន ជា ក្រោយមកនេះ។

**ស៖** សំណួរមួយទៀត ខ្ញុំសុំសួរលោកដែរថា ក្នុងនាមលោកជាអ្នកបើកបរឡាន តើលោកបើកបរឡានហើយ លោកធ្វើជាអង្គរក្សការពារលោកដែលលោកបើកឡានជូនគាត់ហ្នឹង ឬក៏គ្រាន់តែមានមុខងារជាអ្នកបើកឡានតែប៉ុណ្ណោះ? ហើយមានអង្គរក្សផ្សេងទៀត ឬក៏បើកឡានផង ហើយដើរតួជាអង្គរក្សការពារគាត់ផង?

[១៣:៤៧:៣៨]

**ឆ៖** បាទ សំណួរនេះគឺអ្នកដែលបើកឡានហ្នឹង គឺបើកផ្សេង អ្នកដែលការពារហ្នឹងការពារផ្សេង។ ព្រោះមិនមែនច្រឡូកច្រឡំគ្នាទេ គឺ --

**ស៖** បាទ អរគុណច្រើន។ ឥឡូវខ្ញុំសូមឆ្លងទៅព្រឹត្តិការណ៍មួយទៀតគឺខែមេសា ឆ្នាំ១៩៧៥ គឺចង់ដឹងអំពីការស្នាក់នៅក-១៣ និងការងារជាអ្នកបើកបរឡានរបស់លោកជូនលោក ខៀវ សំផន។ លោកធ្លាប់បានជម្រាបជូនអង្គសវនាការហើយថា លោកជាអ្នកបើកបរឡានជូនលោក ខៀវ សំផន តើការបើកបរឡាននេះ បើកជាអចិន្ត្រៃយ៍រហូត ឬក៏បើកមានការដាច់ៗចាប់ពីពេលណា? ហើយបើកដល់

ដំណាក់កាលណាបានលោកឈប់បើកបរជូនលោក ខៀវ សំផន?

**ឆ៖** ពេលខ្ញុំមកបើកបរឡានលោក ខៀវ សំផន ហ្នឹង ខ្ញុំបើករហូតអត់មានទេ រហូតដល់៧៩ ដល់ឆ្នាំ១៩៧៩។

**ស៖** អរគុណ។ នៅពេលដែលលោកបើកបរឡានជូនលោក ខៀវ សំផន តើលោក ខៀវ សំផន បាននិយាយប្រាប់លោកអ្វីខ្លះអំពីព្រឹត្តិការណ៍ផ្សេងៗ ឬក៏លោកធ្លាប់សួរទៅលោក ខៀវ សំផន តើលោក ខៀវ សំផន បានឆ្លើយអ្វីខ្លះទៅលោកដែរទេ? លោកមានចងចាំអំពីអ្វីដែលគាត់បាននិយាយជម្រាបលោក ដែរឬទេនៅក្នុងពេលនោះ?

**ឆ៖** ដូចជាមិនដែលឮនិយាយអីផង គាត់ធម្មតាគឺ គិតតែបើកឡានជូន គាត់ប្រាប់ទៅណាមក ណា ប្រាប់ទៅតាម -- ប្រាប់ថាទៅនេះ មកនេះប៉ុណ្ណឹងឯង។ អត់មានដែលនិយាយ។

[១៣:៤៩:៥៥]

**ស៖** អរគុណ។ តើការបើកឡានជូនលោក ខៀវ សំផន នេះ លោកឧស្សាហ៍ជួបលោក នួន ជា ដែរឬទេ? តើគាត់មានបានឲ្យលោកជូនទៅជួបលោក នួន ជា នៅផ្ទះគាត់ ឬក៏ទៅជួបលោក នួន ជា នៅកន្លែងណាៗដែរ ឬទេ? ឬក៏ជួបជាមួយមេដឹកនាំខ្មែរក្រហមណាផ្សេងទៀតដែរឬទេ? ហើយលោកមាន បានឮគាត់និយាយអ្វីខ្លះដែរឬទេនៅពេលនោះ?

**ឆ៖** ដូចសំណួរនេះ គឺខ្ញុំសូមឆ្លើយថា ដែលខ្ញុំជាអ្នកតែកុងឡាន មិនដឹងទៅជួបអ្នកណាៗទេ ប៉ុន្តែគាត់ទៅជួប បើសិនជាស្គាល់ៗខាងតែកុងឡានគេផ្សេងនោះ ដូចជា នួន ជា ហ្នឹងអី គាត់អាចទៅ ជួបគ្នា បើឃើញតែកុងឡានបានខ្ញុំវាស្គាល់គ្នា។ បើថាអត់ដឹង ក៏អត់ដឹងគាត់ទៅជួបនៅកន្លែងផ្សេង ខ្ញុំ មិនបានចូលទៅទេ។ ដូចខ្ញុំបញ្ជាក់តាំងពីព្រឹកមកហើយ គឺថាខ្ញុំ គឺកន្លែងចូលមកនៅកន្លែង -- បើសិនជា កន្លែងនេះ គឺនៅខាងក្រៅនោះ ខាងក្រៅខ្លោងទ្វារនោះ។ ខ្ញុំមានសិទ្ធិតែត្រឹមខាងក្រៅទេ គឺអត់មានសិទ្ធិ ចូលមកក្នុងទេ គឺអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបន្តទៀត តើនៅពេលណាលោកត្រឡប់ចូលមកក្នុង ក-១២ វិញ? តើលោកវិលត្រឡប់ចូលមក ក-១២ វិញ នៅពេលណា? ហើយក្នុងហេតុផលអ្វីដែរ?

[១៣:៥១:២៣]

**ឆ៖** សំណួរនេះ ខ្ញុំអត់យល់ទេ ត្រឡប់ចូល ក-១២ ត្រឡប់ពីណាមកណា?

**ស៖** អរគុណ។ ខ្ញុំចង់បញ្ជាក់ថា នៅក្រោយខែមេសា ឆ្នាំ១៩៧៨ តើលោកធ្វើការនៅកន្លែង

ណា? ក្រោយខែមេសា ឆ្នាំ១៩៧៨ តើលោកនៅ ក-១២ ឬក៏លោកចល័តទៅកន្លែងផ្សេង?

**ឆ៖** នេះខ្ញុំនិយាយអ៊ីចេះបានគាត់យល់ ដូចថា នេះវាវែងឆ្ងាយបន្តិច ខ្ញុំឆ្នាំ១៩៧៦ ខ្ញុំចូលមក ខ្ញុំនៅសាលាបច្ចេកទេស ចេញពីសាលាបច្ចេកទេសខ្មែរ-សូវៀតហ្នឹងទៅនៅក-១២ នៅកងកុមារ។ ក្រោយពីខ្ញុំបានរៀនបើកបរឡានចេះទៅ បានគេឲ្យទៅនៅមន្ទីរក-៣ វាដាច់ៗពីគ្នា។ ក្រោយពីខែមេសា មិនដឹង ខែមេសា ឆ្នាំ១៩៧៨ ហ្នឹងបានខ្ញុំបានចេញពីក-១២ ទៅៗបើកឡានឲ្យលោក ខៀវ សំផន ហ្នឹងក៏ -- ហើយបែកលោក ខៀវ សំផន ដល់តែពេលរត់ឡើងភ្នំឆ្នាំ៧៩ ខែប៉ុន្មាន ដូចជាខែ -- មិនដឹងជាខែ៣ ឬខែ៤ ហើយកាលហ្នឹង ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែរវាងខែ៣ ខែ៤ ហ្នឹងចប់។

[១៣:៥២:៥១]

**ស៖** បាទ សូមអរគុណ។ នៅក-១២ នៅពេលដែល -- ក្រោយពេលដែលគេចាប់ តាម៉ៀល ចេញពីក-១២ ទៅ តើលោកបានសង្កេតឃើញថា មានព្រឹត្តិការណ៍អ្វីកើតឡើងនៅក្នុងក-១២ នោះ?

**ឆ៖** បាទ រឿងគេចាប់ តាម៉ៀល ខ្ញុំអត់ដឹងទេ។ ខ្ញុំទៅនៅក-៣ ទៅនៅជាមួយលោក ខៀវ សំផន បាត់ទៅហើយ ព្រោះគេចាប់ខ្ញុំអត់ដឹងទេ ប៉ុន្តែក្រោយមកគ្រាន់តែនិយាយតៗគ្នាទេ។

**ស៖** អរគុណ។ សូមសួរបន្តទៀត នៅពេលដែលលោក ខៀវ សំផន អវត្តមាននៅក្នុងប្រទេស ឬក៏អវត្តមាននៅក្នុងទីក្រុងភ្នំពេញ តើលោកធ្វើកិច្ចការអ្វី? ហើយធ្វើកិច្ចការហ្នឹងជាមួយអ្នកណា? នៅកន្លែងណា? ខ្ញុំចង់និយាយថា នៅពេលដែលលោក ខៀវ សំផន អវត្តមានក្នុងប្រទេស គាត់ចេញទៅក្រៅប្រទេស ឬក៏អវត្តមាននៅទីក្រុងភ្នំពេញ។ អ៊ីចឹងនៅពេលនោះគាត់ -- លោកអត់អាចទៅបើកឡានជូនគាត់បាន ពីព្រោះគាត់អត់នៅ។ អ៊ីចឹងនៅពេលនោះ ថាតើលោកធ្វើកិច្ចការអ្វី? ហើយធ្វើកិច្ចការហ្នឹងនៅកន្លែងណា? ធ្វើអ្វីជាមួយនឹងអ្នកណា? បាទ សូមលោកជួយបញ្ជាក់។

[១៣:៥៤:១៣]

**ឆ៖** តាំងពីខ្ញុំទៅរស់នៅជាមួយគាត់នោះ តាំងពីហ្នឹងដូចអត់ដែលគាត់អត់មានទៅបរទេសផង គឺខ្ញុំរស់នៅ គាត់នៅរហូត អត់ដែលទៅបរទេសទេ ឆ្នាំ -- តាំងពី៧៨ រហូតដល់៧៩។ ប៉ុន្តែក្រោយ៧៩ មកខ្ញុំអត់ដឹងទេអាហ្នឹង ព្រោះ -- ហើយបើរស់នៅប្រសិនបើនៅកន្លែងនោះ គេឲ្យដាំត្រកួនដាំអីជិតៗផ្ទះហ្នឹង ដល់ពេលត្រូវគាត់ហៅទៅណា ហៅនៅជិតនុំង ធ្វើកន្លែងដាំត្រកួន ដាំបន្លែតិចតួច។

**ស៖** បាទ អរគុណ។ សូមលោកជួយបញ្ជាក់មួយទៀត នៅពេលដែលមានគណៈប្រតិភូបរទេសមកទស្សនកិច្ចនៅប្រទេសកម្ពុជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ នៅពេល

នោះតើលោក ខៀវ សំផន ជាញឹកញាប់បានទទួលគណៈប្រតិភូនោះ ឬក៏មានអ្នកផ្សេង? ហើយបើសិន ជាគាត់ទៅទទួលគណៈប្រតិភូបរទេស តើលោកជូនដំណើរគាត់ទៅជាញឹកញាប់ ឬក៏មានអ្នកផ្សេង ទៀតជាអ្នកបើកឡានជូនគាត់?

[១៣:៥៥:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថាសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញានេះ ជាសំណួរច្រំដែល ដោយសារសាក្សីបានឆ្លើយរួចហើយថានៅពេលដែលសាក្សីមកបើកឡានឱ្យលោក ខៀវ សំផន គឺមានតែគាត់ម្នាក់ទេដែលអ្នកបើកឡានឱ្យគាត់នោះ។ ដូច្នេះចម្លើយនេះគឺបានឆ្លើយរួច ហើយបាទ។ សូមអរគុណ។

**លោក ច័ន្ទ តារាវស្មី៖**

លោកប្រធាន ខ្ញុំកន្លែងនេះខ្ញុំចង់បញ្ជាក់ពីពេលដែលមានគណៈទស្សនកិច្ចរបស់គណៈប្រតិភូមក ពីបរទេមកក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីទស្សនកិច្ចនៅកន្លែងណាមួយ។ តើលោក ខៀវ សំផន ហ្នឹងមានដូរអ្នកបើកបរឡានជូនគាត់ដែរឬទេ? ពីព្រោះចង់ដឹងថា តើគាត់ហ្នឹងបើកឡានជូនលោក ខៀវ សំផន គ្រប់សកម្មភាពសំខាន់ៗ ឬក៏មានអ្នកផ្សេងនេះជំនួសគាត់។ ខ្ញុំគ្រាន់តែចង់ដឹងប៉ុណ្ណឹងបាទ ពីព្រោះ នៅក្នុងឯកសារនេះបានបង្ហាញថា ពេលនោះមានអ្នកផ្សេងទៀតបើកឡាន។ អរគុណបាទ។

[១៣:៥៦:១៤]

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីជំទាស់មិនមានមូលដ្ឋានសមស្របទេ។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សី ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ!

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ គឺក្រោយពីខ្ញុំទៅនៅនឹងក-៣ ហ្នឹង គឺគ្មានអ្នកណាបើក ទៀត គ្មានអ្នកណាបើកឡានជូនគាត់ទៀតទេ ប៉ុន្តែចំណែកដែលខ្ញុំទៅនៅរហូតហ្នឹង គឺតាំងពីខែមេសាៗ ហ្នឹង ខែមេសាៗហ្នឹង ១៩៧៨ ហ្នឹង ៧៩ហ្នឹង គឺគាត់អត់ដូចមានដែលទទួលភ្ញៀវបរទេសទេ ទទួលភ្ញៀវ

ធំៗដូចអត់ដែលមានទេ។ ដូចជាប្រធានាធិបតីអីជំនាន់មុន កាលហ្នឹងខ្ញុំអត់ទាន់ទៅបើកឡានជូនគាត់ទេ។ មានអ្នកផ្សេង ខ្ញុំអត់ស្គាល់គេទេ ប៉ុន្តែខ្ញុំឮក្នុងវិទ្យុ។ កាលហ្នឹងគេចាក់វិទ្យុតាមផ្លូវ តាមអី គេដាក់វិទ្យុតាម។ អ៊ីចឹងចេះតែឮតាម។ ក្រោយមកនេះ ខ្ញុំអត់មានដែលបានជូនគាត់ទៅទទួលគណៈប្រតិភូធំៗអត់ទេ។ គាត់ក៏មិនដែលចេញដែរ បើសិនជាចេញ តែកុងមានតែម្នាក់ទេ ដល់ពេលអ្នកណាទៅ គឺមានតែម្នាក់។

[១៣:៥៧:៣៥]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** បាទសូមអរគុណ។ សំណួរមួយទៀត តើលោកស្គាល់លោក វន វ៉េត ទេបាទ? វន វ៉េត ជាអ្នកណា?

**ឆ៖** បាទស្គាល់តើ គ្រាន់តែឃើញហ្នឹងស្គាល់។ ប៉ុន្តែ វន វ៉េតៗហ្នឹង មានអ្នកណាទៀត។

**ស៖** អរគុណ។ តើលោក វន វ៉េត គាត់ទទួលខុសត្រូវកិច្ចការអ្វីខ្លះ? គាត់កាន់មុខតំណែងជាអ្វីមួយនៅក្នុងរបបនោះដែរឬទេ? ហើយគាត់ធ្វើកិច្ចការនៅកន្លែងណាបាទ? ហើយគាត់រស់នៅៗកន្លែងណា?

**ឆ៖** ខ្ញុំអត់ដឹងរស់នៅកន្លែងណា ប៉ុន្តែគាត់ឈ្មោះ វន វ៉េត ហ្នឹងគឺផ្សេងក្នុងវិទ្យុ ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច។ ឮតែក្នុងវិទ្យុទេ ចង់និយាយថា ប៉ុន្តែគាត់ធ្វើអី ខ្ញុំអត់ដឹងទេ ខ្ញុំនៅ --

**ស៖** តើមានរឿងអ្វីកើតឡើងលោក គឺក្រោយពេលដែលមានព្រឹត្តិការណ៍មួយបានកើតឡើងចំពោះលោក វន វ៉េត? តើលោកចងចាំ ឬក៏អាចបញ្ជាក់ជូនអង្គសវនាការបានដែរឬទេថា មានបញ្ហាអ្វីកើតឡើងចំពោះគាត់ លោក វន វ៉េត ហ្នឹង? តើកម្មាភិបាលខ្មែរក្រហមដទៃបានធ្វើអ្វីចំពោះគាត់? តើគាត់ទទួលរងនូវផលវិបាកអ្វីខ្លះចំពោះគាត់នៅពេលនោះបាទ?

[១៣:៥៩:០២]

**ឆ៖** បាទខ្ញុំអត់ដឹងទេរឿងនេះ ព្រោះរឿងកម្មាភិបាល ព្រោះខ្ញុំឃើញថា ខ្ញុំអ្នកក្មេង ចង់និយាយថាជំនាន់នោះក្មេង ចាំក៏មិនចាំដល់ឥឡូវ។ បើសិនជាធំដូចឥឡូវក៏ចាំដែរ ប៉ុន្តែកាលណោះវាតូច អត់ចាំដែរ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមឲ្យលោកជួយបញ្ជាក់ជូនអង្គសវនាការថា តើលោកបានធ្លាប់ជួបលោក ប៉ុល ពត ជួបលោក តាម៉ុក ឬក៏ជួបជាមួយនឹងលោក សុន សេន ដែរឬទេ? ថាតើលោក សុន

សេន និង ប៉ុល ពត, តាម៉ុក ធ្លាប់បានចេញចូលនៅក-១៣ ដែរឬទេ? ក-៣ បាទ តើគាត់បានមកក-៣ ដែរឬទេ ប៉ុល ពត, តាម៉ុក, សុន សេន តើគាត់បានមកក-៣ ដែរឬទេ? លោកបានឃើញគាត់មកដែរឬទេបាទ? ហើយគាត់ចេញចូលទីនោះញឹកញាប់ដែរឬទេ?

[១៤:០០:០៥]

**ឆ៖** រឿងនេះ ខ្ញុំដូចជាមិនដែលបានសូវឃើញផង ព្រោះបើឲ្យជួបតែម្តង អត់ជួបទេ គ្រាន់តែបើឃើញ គ្រាន់តែឃើញដឹងថាឡានគាត់ ប៉ុន្តែដូចជាអត់ដែលឃើញចូលមក។ សុន សេន ក៏អត់ដែលចូលមក។ បើ វន វ៉េត គាត់អាចចូលមកយូរៗម្តង។

**ស៖** ចុះលោក ប៉ុល ពត គាត់បានចូលមកទេបាទ?

**ឆ៖** លោក ប៉ុល ពត មិនដឹង -- ដូចអត់ដែលសូវឃើញចូលមកដែរ អត់ដែលឃើញតែម្តង ឃើញតែឡាន ជួនកាលអត់។

**ស៖** បាទ សូមអរគុណ។ ដោយសារតែខ្ញុំគ្មានពេលនឹងសួរសំណួរបន្តលោកទៀត ប៉ុន្តែមុនបញ្ចប់ ខ្ញុំសូមសួរសំណួរលោកតែបីសំណួរទៀតទេបាទ។

[១៤:០០:៥៤]

សំណួរទី១សូមសួរថា តើក្នុងពេលដែលលោករស់នៅក្នុងរបបខ្មែរក្រហម តើលោកនៅចងចាំនូវពាក្យសម្តីរបស់មេដឹកនាំខ្មែរក្រហម ដែលក្នុងនាមលោកជាអ្នកបើកឡាន ឬក៏ចូលប្រជុំ ឬក៏រស់នៅ ឬក៏ឮគេថានៅពេលនុ៎ង តើគេនិយាយប្រាប់លោកអ្វីខ្លះអំពីរបបខ្មែរក្រហមហ្នឹង? គឺអំពីសកម្មភាពរបស់របបខ្មែរក្រហម មេដឹកនាំខ្មែរក្រហមនិយាយប្រាប់លោកអ្វីខ្លះ? ខ្ញុំចង់ឲ្យលោករំឭកការចង ថាតើលោកបានឮសម្តីរបស់មេដឹកនាំខ្មែរក្រហមរូបណាដែលបាននិយាយអ្វីខ្លះពីសកម្មភាពរបស់មេដឹកនាំខ្មែរក្រហមហ្នឹង ឬក៏គោលនយោបាយរបស់មេដឹកនាំខ្មែរក្រហមនោះ? តើលោកចងចាំដែរឬទេបាទ?

[១៤:០១:៣៧]

**ឆ៖** រឿងនេះខ្ញុំដូចមិនចាំទេ ខ្ញុំដូចគ្មានគោលការណ៍ដឹងអីផង វាម្យ៉ាងខ្លួននៅកុមារ។

**ស៖** បាទ អរគុណ។ សំណួរទី២ ខ្ញុំសូមលោកជួយបំភ្លឺបន្តិចជូនអង្គសវនាការថា ពីព្រឹកមិញលោកបានបញ្ជាក់ជូនសវនាការថា លោក ខៀវ សំផន គឺជាមនុស្សគួរឲ្យគោរព។ ជាមនុស្សសុភាពរាបសា និងស្លូតត្រង់។ តើលោកផ្អែកលើមូលហេតុអ្វី មូលដ្ឋានអ្វីបានជាលោកបញ្ជាក់ជូនអង្គសវនាការយ៉ាងដូច្នេះ? សូមលោកបញ្ជាក់អំពីហេតុអ្វីបានជាលោកបញ្ជាក់ថាលោក ខៀវ សំផន ជាមនុស្សបែប

ហ្នឹងបាទ?

**ឆ៖** បាទ សំណួរនេះគឺខ្ញុំគោរពនេះ ចំពោះគោរពតែខ្លួនខ្ញុំ មូលហេតុដែលខ្ញុំគោរព ខ្ញុំធ្លាប់រស់នៅជាមួយគាត់ ហើយគាត់ស្លូតបូត សុភាពរាបសា គួរឲ្យគោរពអ៊ីចឹងទេ។ ខ្ញុំគោរព មូលហេតុអ៊ីចឹងឯង ដែលព្រោះគាត់មិនដែលឃើញសកម្មភាពអី។ អ៊ីចឹងខ្ញុំគោរពគាត់អ៊ីចឹងឯង។

[១៤:០២:៤៦]

**ស៖** បាទ អរគុណ។ សូមសួរសំណួរចុងក្រោយថា ក្នុងពេលដែលលោករស់នៅក្នុងរបបខ្មែរក្រហម លោកគឺជាមនុស្សដែលរស់នៅជាតួអង្គឯកក្នុងហ្នឹងគឺលោករស់នៅដឹងព្រឹត្តិការណ៍ទាំងអស់ ទោះបីជាលោកនៅក្មេង ប្រហែលជាលោកនៅចងចាំ។ ថាតើលោកមើលឃើញថា សង្កេតឃើញថា សកម្មភាពដែលរបបខ្មែរក្រហមបានបង្កឡើងនៅពេលនោះ អ្វីខ្លះដែលជាការលំបាក ដែលលោកមិនពេញចិត្ត ឬក៏ប្រជាជនកម្ពុជាមិនពេញចិត្តចំពោះរបបខ្មែរក្រហមនៅក្នុងសម័យកាលនោះ? តើលោកអាចសង្កេតបញ្ជាក់ជូនអង្គសវនាការបានដែរឬទេ អំពីអ្វីដែលលោកបានឃើញ បានឮដោយផ្ទាល់ត្រចៀកនៅក្នុងព្រឹត្តិការណ៍នោះ? ខ្ញុំនិយាយដូច្នេះមិនមែនឲ្យលោកសន្និដ្ឋានទេ ប៉ុន្តែឲ្យលោកឃើញអ្វីថាតាមការសង្កេតឃើញជាក់ស្តែងរបស់លោក។ ប្រសិនបើលោកអាចបញ្ជាក់ជូនបានបាទ។

[១៤:០៣:៣៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះការសង្ខេបនូវសេចក្តីដើមសេចក្តីមុននឹងតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជូនចំពោះសាក្សី ដែលបញ្ជាក់ថាសាក្សីរូបនេះ លោកជាតួឯកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំគិតថាវាមិនមែនជារឿងត្រឹមត្រូវទេ ការសង្ខេបនេះ។ ហើយមិនមែនទៀត វាមិនមែនជាសន្និដ្ឋានបែបនេះទេ។ ហើយទី២ លោកបញ្ជាក់ថា សាក្សីដឹងព្រឹត្តិការណ៍ទាំងអស់កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះការសរុបមួយនេះ ឬក៏ការសន្និដ្ឋានមួយនេះក៏ជាចំណុចមិនត្រឹមត្រូវ។ ដូច្នេះ ខ្ញុំសូមឲ្យបញ្ជាក់ចំពោះការសួរឡើងវិញឲ្យបានត្រឹមត្រូវ បើសិនជាតំណាងសហព្រះរាជអាជ្ញាចង់ឲ្យសាក្សីឆ្លើយនូវសំណួរនេះបាទ។ សូមអរគុណ។

[១៤:០៤:៣៤]

**លោក ច័ន្ទ តារាស្មី៖**

អរគុណៗ។ លោកប្រធាន ខ្ញុំសូមបំភ្លឺជូនលោកមេធាវីការពារក្ដីលោក ខៀវ សំផន បន្តិច។ ចំណុចនេះ ខ្ញុំនិយាយនេះគឺក្នុងបរិបទថា លោកសាក្សីគឺតួឯក។ មានន័យថាគាត់ជាអ្នកដែលរស់នៅដោយផ្ទាល់ក្នុងព្រឹត្តិការណ៍ដែលគាត់បានមកបំភ្លឺក្នុងសវនាការនៅពេលនេះ ក្នុងនាមជាសាក្សីដែលផ្ដល់សក្ខីកម្មជូនអង្គសវនាការនៅពេលនេះ។ ដូច្នេះ បើគាត់មិនបានដឹងច្បាស់ទេ ប្រហែលជាតុលាការនៅថ្ងៃនេះ ប្រហែលជាមិនអញ្ជើញគាត់ចូលរួមផ្ដល់សក្ខីកម្មនៅថ្ងៃនេះទេ។ អ៊ីចឹងគឺគាត់ជាអ្នកដែលដឹងរឿងនេះពិត។ អ៊ីចឹងយើងអាចនិយាយថាក្នុងន័យធៀប តួឯកក្នុងរឿងនេះ មិនមែនតួឯកក្នុងតួអង្គនយោបាយទេ មិនតួអង្គនៅក្នុងសកម្មភាពដឹកនាំថ្នាក់កំពូលរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬក៏បក្សកុម្មុយនីស្ដកម្ពុជាទេ។ គឺជាតួឯកមានន័យក្នុងន័យក្នុងសំណួរបរិបទនេះ គឺគាត់បានដឹងឮច្បាស់ក្នុងជីវិត ក្នុងសកម្មភាពដែលគាត់រស់នៅក្នុងបរិបទនៃការងារ ទីកន្លែងដែលគាត់រស់នៅ ទីតាំងដែលគាត់បានឃើញផ្ទាល់ អ្វីដែលគាត់បានឮដោយផ្ទាល់ត្រចៀក គឺគាត់អាចផ្ដល់ជូនអង្គសវនាការនៅពេលនេះបាន។ សំណួរនេះគឺមានសារៈសំខាន់ ពីព្រោះគាត់បំភ្លឺ គាត់អាចធ្វើឲ្យអង្គសវនាការបានយល់ច្បាស់ អំពីអ្វីដែលបានឃើញ។

[១៤:០៥:៤៤]

ជាពិសេស គឺគាត់ជាអ្នកបើកឡានរបស់លោក ខៀវ សំផន។ អ៊ីចឹងគាត់ពិតជាអាចបញ្ជាក់ជូនអង្គសវនាការអំពីឥរិយាបថ អាកប្បកិរិយារបស់លោក ខៀវ សំផន និងមេដឹកនាំមួយចំនួនទៀត។ ដូច្នេះចម្លើយសំណួរនេះ គឺមានសារៈសំខាន់ជូនអង្គសវនាការនៅពេលនេះ។ ហើយអ្វីដែលខ្ញុំនិយាយថាគាត់ដឹងព្រឹត្តិការណ៍ទាំងអស់នោះ មិនមែនព្រឹត្តិការណ៍ទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ ធម្មតាមនុស្សម្នាក់មិនអាចដឹងទាំងអស់បានទេ។ មនុស្សម្នាក់អាចដឹងនូវអ្វីដែលខ្លួនអាចដឹង ហើយមិនអាចដឹងនូវអ្វីដែលខ្លួនមិនអាចដឹង។ ដូច្នេះ ក្នុងនាមគាត់ជាសាក្សី គាត់អាចដឹងទាំងអស់នេះ គឺដឹងរឿងព្រឹត្តិការណ៍នៅក្នុងទីកន្លែងគាត់រស់នៅ និងទីកន្លែងដែលគាត់ធ្វើការ និងបរិបទទាំងអស់ដែលគាត់អាចធ្វើចល័តពីកន្លែងមួយទៅកន្លែង ដឹងនូវអ្វីដែលគាត់អាចដឹង។ ដូច្នេះការដឹងរបស់គាត់ប៉ុណ្ណា គឺអាចបង្ហាញជូនសវនាការឲ្យបានជ្រាបបញ្ហាប៉ុននុ៎ង គឺជាមូលដ្ឋានដើម្បីស្វែងរកយុត្តិធម៌ និងសច្ចភាពនូវរឿងក្ដីនេះ។

ខ្ញុំគិតថា សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់ឆ្លើយ គឺជាការចាំបាច់។

សូមអរគុណលោកប្រធាន។

[១៤:០៦:៤១]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីអាចឆ្លើយតបទៅនឹងសំណួរដែលសួរ តែសំណួរទី១ បានហើយ ចំណែកឯសំណួរទី២ សូមឲ្យវាយតម្លៃទៅលើការយល់ដឹងរបស់ពលរដ្ឋខ្មែរនោះ គឺជាមតិយោបល់សន្និដ្ឋានរបស់សាក្សីមិនអាចឆ្លើយបានទេ។ ដូច្នេះលោកសាក្សីអាចឆ្លើយក្នុងនាមសង្កេតរបស់ផ្ទាល់ឯងបាន។ ចំពោះសង្កេតថាពលរដ្ឋខ្មែរហ្នឹងយល់យ៉ាងម៉េចដែរនោះ គឺសាក្សីមិនមែនអ្នកជំនាញទេ។ មិនគប្បីឆ្លើយតបទៅនឹងសំណួរបែបនេះទេ។

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរម្តងទៀត ហើយមិនគប្បីប្រើតួឯក តួរង នៅក្នុងសវនាការនេះទេ។ ប្រើត្រឹមតែសាក្សីខ្លួនឯងផ្ទាល់ទៅគ្រប់គ្រាន់ហើយ ហើយសំណួរកុំឲ្យពាក់ព័ន្ធទៅដល់ការសន្និដ្ឋាន។ ទោះបីលោកប្រើពាក្យសង្កេតក៏ដោយ ក៏ខ្លឹមសារវាគឺជាសេចក្តីសន្និដ្ឋាន គ្រាន់តែរបៀបនៃការប្តូរពាក្យប៉ុណ្ណោះ ខ្លឹមសារគឺឲ្យវាយតម្លៃទៅលើការយល់ដឹងរបស់ពលរដ្ឋទូទៅអំពីបញ្ហាមួយដោយឲ្យសាក្សីនិយាយអំពីការយល់ដឹង ការគិតគូរទស្សនៈរបស់ពលរដ្ឋខ្មែរទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**លោក ច័ន្ទ តារាស្មី៖**

អរគុណលោកប្រធាន។

[១៤:០៨:១៨]

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី សូមលោកជួយបញ្ជាក់អង្គសវនាការឲ្យបានជាក់ច្បាស់ ប្រសិនបើលោកអាចបញ្ជាក់ជូនបាន អំពីការសង្កេតជាទូទៅក្នុងនាមលោកផ្ទាល់ នូវអ្វីដែលលោកបានឃើញ បានឮដោយភ្នែក ឬក៏ផ្ទាល់ត្រចៀក ស្តាប់ឮដោយផ្ទាល់ត្រចៀកនូវអ្វីដែលព្រឹត្តិការណ៍កើតឡើង ថាតើវាមានការលំបាកយ៉ាងណាខ្លះចំពោះរូបលោកផ្ទាល់? និងចំពោះមនុស្សចំនួនទៀតដែលនៅតំបន់របស់លោកនៅក្នុងរបបខ្មែរក្រហមនេះ បាទ?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ សំណួរនេះ បើសួរសំណួរនេះខ្ញុំអាចឆ្លើយបាន។ បើសំណួរមុន ឲ្យថាសង្កេតអី ដែលដឹងរឿងពីការយល់ដឹង ខ្ញុំអត់យល់ ដឹងតែ -- បើសំណួរនេះ ខ្ញុំថាចំពោះខ្លួនខ្ញុំ ដឹងតែខ្លួនឯង ហើយម្យ៉ាង

វ័យខ្លួនឯងក៏នៅក្មេងដែរជំនាន់ហ្នឹង ហើយដឹងទៅ ដឹងថាដូចអត់មានលំបាកអីផងខ្លួនឯង។ នៅពេលនៅកុមារ អត់មាន មានតែការកៀបសង្កត់អី អត់។ ដល់អ៊ីចឹងការឈឺចាប់អីក៏អត់ដែរ អត់មានឈឺចាប់អីផង។ បើនៅស្រួលទៅហើយ បើមានឈឺចាប់អីទៀត។

[១៤:០៩:២៥]

**លោក ច័ន្ទ តារាស្មី៖**

បាទ អរគុណលោកសាក្សី។ ដោយសារតែខ្ញុំមិនមានពេលវេលាសួរលោកតទៀត ខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំនៅពេលនេះ។ ហើយសូមថ្លែងអំណរគុណចំពោះលោកដែលបានឆ្លើយសំណួររបស់ខ្ញុំ ហើយសង្ឃឹមថា ការឆ្លើយរបស់លោកពិតជាអាចចូលរួមចំណែកក្នុងការស្វែងការនិងយុត្តិធម៌នៅក្នុងសំណុំរឿងក្ដី០០២ នៅក្នុងសវនាការនៅពេលនេះ។ ហើយសូមលោកប្រធាន អនុញ្ញាតឲ្យខ្ញុំឆ្លើយមកនេះ ហើយសូមអរគុណ ហើយសូមវេទិកានេះជូនទៅសហការីរបស់ខ្ញុំដើម្បីសួរសំណួរបន្ត។ សូមអរគុណលោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

[១៤:១០:០៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរសួរលោករហូតទៅដល់ពេលក្រោយឈប់សម្រាកទៀត វាអាស្រ័យទៅតាមចម្លើយរបស់លោកថាខ្លី និងច្បាស់លាស់ដែរឬទេ? ខ្ញុំឈ្មោះ វ៉ាំងសង់ ដឺវីលខ្ញុំតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា។ សំណួរទី១របស់ខ្ញុំៗចង់ដឹងថាតើលោកធ្លាប់ឃើញលោក ខៀវ សំផន មុនពេលដែលលោកទៅក-៣ ដែរឬទេ? ឧទាហរណ៍ដូចជានៅក-៣ នោះ តើលោកធ្លាប់ឃើញលោក ខៀវ សំផន ដែរឬទេ? ក-១២ *(សុំទោស!)* នៅ ក-១២ មុននៅក-៣ តើលោកមានឃើញលោក ខៀវ សំផនទេ?

**លោក ឡុង ឈឿង៖**

**ឆ៖** សំណួរនេះ ខ្ញុំអត់ដែលឃើញគាត់ផង។

[១៤:១១:០៣]

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីអ្វីដែលកើតឡើងនៅក-១២ ដែលលោកនិយាយថាមាន តាម៉ៀល។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមបង្ហាញជូនឯកសារមួយទៅសាក្សីលោកប្រធាន គឺឯកសារលេខ E3/858 មួយទៀត IS18.56 ឯកសារនេះគឺជាបញ្ជីបុគ្គលិកក-១២។ ដូច្នេះខ្ញុំចង់បង្ហាញឯកសារនេះ ជូនសាក្សីដើម្បីឲ្យគាត់កំណត់អត្តសញ្ញាណមនុស្សមួយចំនួន។ ដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាតបង្ហាញឯកសារនៅលើអេក្រង់និងផ្តល់ជូនសាក្សី។ ឯកសារជាភាសាខ្មែរគឺលេខរៀងទី៦ ទំព័រទី៦ លេខ ERN 0011--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកព្រះរាជអាជ្ញាអានលេខ ERN ម្តងទៀត។ អ្នកបកប្រែតាមអត់ទាន់។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាអាននូវលេខឯកសារសាជាថ្មីម្តងទៀត ពីព្រោះអ្នកបកប្រែមិនអាចបកប្រែបានទេ ដោយសារលោកញាប់ពេក។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ឯកសារនេះគឺលេខ E3/858 ទំព័រពាក់ព័ន្ធនោះគឺទំព័រទី៦ ជាភាសាខ្មែរ 00021158, ទំព័រទី១១ ជាភាសាបារាំង និងទំព័រទី ៩ ជាភាសាអង់គ្លេស។

[១៤:១៣:០៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ នៅក្រោមចំណងជើងថាមន្ទីរក-១២ ផ្នែកបើកបរ ស-៧២ គឺមានក្នុងនោះមានឈ្មោះមួយចំនួន។ ឈ្មោះទី១នោះ ឈ្មោះ ម៉ៀល ក្នុងនោះគេដាក់ថាប្រធានក-១២។ តើម្នាក់ហ្នឹង ហើយដែលលោកបាននិយាយអំបាញ់មិញគឺ តាម៉ៀល ហ្នឹង?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ មន្ទីរក-១២ តាម៉ៀល ខ្ញុំស្គាល់តាម៉ៀលហ្នឹង។

**ស៖** មានឈ្មោះផ្សេងៗទៀតនៅក្នុងបញ្ជីនេះគឺក្នុងនេះមាន សារឿន អនុប្រធានមន្ទីរក-១២, មានលេខ៣ គឺ យ៉ាង ប្រធានផ្នែកឡានភ្ញៀវ, លេខ៤ ចុន ប្រធានរោងជាងឡាន, ភា ប្រធានខាងរុំឌីណាម៉ូ, រ៉េត បើកបរឡានភ្ញៀវ, គឿន បើកបរឡានភ្ញៀវ, ជាចុងក្រោយគឺមានឈ្មោះ អួន ជាងឡាន ក-១២។ តើមនុស្សប្រាំពីរផ្សេងទៀតនៅក្នុងឯកសារនេះ លោកស្គាល់ដែរឬទេ ក្រៅពី តាមៀល?

[១៤:១៥:០៦]

**ឆ៖** ដូចជាអត់ស្គាល់ទេ ប្រហែល ប៉ុន្តែដល់ប្រហែលទៅយូរឆ្នាំពេកទៅ អត់ស្គាល់។ ខ្ញុំនឹកអត់ឃើញទេ។

**ស៖** បាទ មិនអីទេ ខ្ញុំនឹងត្រឡប់មកនិយាយអំពីឯកសារនេះនៅពេលក្រោយពាក់ព័ន្ធនឹងក-១ និងក-៣។ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំចង់បង្ហាញឯកសារមួយផ្សេងទៀតជូនលោក គឺឯកសារ E3/1953។ នេះគឺជាបញ្ជីអ្នកទោសដែលត្រូវបានសួរចម្លើយនៅឆ្នាំ១៩៧៨ នៅស-២១។ មានឈ្មោះមួយដែលខ្ញុំចង់បង្ហាញគឺនៅក្រោមក្រសួងស-៧១។

[១៤:១៦:០៤]

ជាភាសាខ្មែរគឺទំព័រទី១ លោកប្រធាន។ ERN គឺ 00039917, ជាភាសាអង់គ្លេសគឺនៅទំព័រ 0023388 -- 43, ទំព័របារាំងគឺទំព័រទី១ គឺ 00874783។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ដូច្នេះសូមការអនុញ្ញាតពីលោកប្រធានបង្ហាញជូនឯកសារនេះនៅលើអេក្រង់ និងប្រគល់ឯកសារប្រកាសជូនសាក្សី ដើម្បីឲ្យគាត់មើលមនុស្សនៅក្នុងឯកសារនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីនៅក្នុងឯកសាររបស់លោក គឺទំព័រពណ៌លឿន នៅទំព័រដំបូង ក្នុងនោះមានសរសេរឈ្មោះថា សាន់ ស្រឿន ហៅ មៀល ប្រធានមន្ទីរបើកបរក-១២ ហើយថ្ងៃចាប់ហ្នឹងគឺថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៨។ អម្បាញ់មិញនេះលោកនិយាយហើយថាមានឈ្មោះ មៀល នេះ នៅក្នុងឯកសារផ្សេងទៀត។ ដូច្នេះតើឈ្មោះនេះគឺជាឈ្មោះដដែលដែលជាប្រធានក-១២ ដែលលោកធ្វើការនៅជាមួយ

នឹងមែនទេ?

[១៤:១៧:៥០]

**លោក ឡេង ឈឿង៖**

**ឆ៖** ខ្ញុំដឹងតែឈ្មោះ មៀល ទេព្រោះ មៀល ដឹងតែឈ្មោះ មៀល។ ប្រធានក-១២ មានតែ មៀល ហ្នឹងហើយ។ ប៉ុន្តែគាត់និយាយពីខែប៉ុន្មានថាចាប់ខ្លួន មៀល ហ្នឹង វាខុសខ្ញុំចេញពីក-១២ ហ្នឹង ទៅបាត់ទៅ ដល់អ៊ីចឹងខ្ញុំអត់បានដឹងទេ អត់ដឹងគេចាប់។

**ស៖** បាទ សូមអរគុណ។ មានព័ត៌មានមួយដែលខ្ញុំចង់សួរលោក នៅលើឯកសារទាំងពីរដែលខ្ញុំបានបង្ហាញជូនលោកនោះ ឈ្មោះ មៀល គឺស្ថិតនៅក្នុងក្រសួងស-៧១ ឬក៏មន្ទីរស-៧១ តើលោកធ្លាប់ឮគេនិយាយអំពីមន្ទីរស-៧១ ទេនៅពេលដែលលោកធ្វើការនៅក-១២ បន្ទាប់មកនៅក-៣ នោះ?

**ឆ៖** ខ្ញុំអត់ដឹង ស-៧១ ក៏អត់ដឹងទេ ក៏ប្រធានមន្ទីរក-១២ ខ្ញុំដឹងគាត់ធ្វើប្រធាន ដឹងតែប្រធាន។ ដឹងគាត់ធ្វើអីទៀត ខ្ញុំអត់ដឹងផង។

[១៤:១៩:២១]

**ស៖** សូមអរគុណ។ ជាភាសាបារាំង ខ្ញុំឮថាលោកនិយាយអំពីស-២១។ ខ្ញុំមិនមែននិយាយពី ស-២១ ទេ ខ្ញុំនិយាយពី ស-៧១។ តើអម្បាញ់មិញនេះលោកឆ្លើយ ស-៧១ ឬក៏ស-២១? សំណួរខ្ញុំគឺ ស-៧១ ទេ។ សូមឲ្យលោកឆ្លើយម្តងទៀត ព្រោះខ្ញុំឮបកប្រែជាភាសាបារាំងនោះថា ស-២១។

**ឆ៖** បាទ សំណួរនេះខ្ញុំឆ្លើយថា ខ្ញុំស្គាល់ឈ្មោះ មៀល ប៉ុន្តែមិនដឹងគាត់ធ្វើការ ដឹងតែប្រធានមន្ទីរក-១២ ទេ ប៉ុន្តែតែរឿងទៅអីស-៧១ នេះគឺខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។ អម្បាញ់មិញមេធាវីការពារក្តីលោក ខៀវ សំផន បានលើកឡើងនៅកំណត់ហេតុស្តាប់ចម្លើយ តាសុត គឺឯកសារ E3/464 ។ ខ្ញុំចង់ដកស្រង់ឃ្លាមួយដោយមិនចាំបាច់បង្ហាញកំណត់ហេតុនេះទាំងស្រុងជូនលោកទេ។ ឃ្លានេះនៅទំព័រអង់គ្លេស ទំព័រ៥, ទំព័របារាំងក៏៥, ខ្មែរ ៥ និង៦។ នេះជា សុត គាត់និយាយអំពី ប៉ង់ និងមន្ទីរ-ក។ “ប៉ង់ ជាប្រធានមន្ទីរកទាំងអស់ ដូចជា ក-១, ក-២, ក-៣, ក-៤, ក-៧, ក-១២”។ ចុះក្រោមបន្តិចទៀតមក “ប៉ង់ ទទួលបញ្ជាពីថ្នាក់លើដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា គឺអាស្រ័យទៅតាមឯកទេសជំនាញរបស់មេដឹកនាំជាន់ខ្ពស់នីមួយៗ គឺបើករង់ក្រចកមកថា (គោលដៅនៃភារកិច្ច)”។ ចុះមកក្រោមបន្តិចមក “ប៉ង់ ទៅជួប ខៀវ សំផន នៅក-៣ ហើយ ខៀវ សំផន ក៏ទៅជួប ប៉ង់ នៅក-៧ ផងដែរ”។ សូមបញ្ចប់ការដកស្រង់។

តើលោកអាចបញ្ជាក់បានទេថា លោកធ្លាប់ជូនលោក ខៀវ សំផន ទៅក-៧ ដែរឬទេ នៅពេលដែលលោកធ្វើការជូនគាត់នោះ?

[១៤:២២:០៥]

**ផ៖** ខ្ញុំដូចអត់ដែលបានជូនទៅផង ខ្ញុំចាំមិនបានផង ខ្ញុំអត់ដែលបានជូនទេ ទៅក-៧ ហ្នឹង ប៉ុន្តែដឹងថា ប៉ង់ គ្រប់គ្រងមន្ទីរទាំងអស់ហ្នឹង គឺខ្ញុំក៏អត់ដឹងដែរ ទើបមកលើកសំណួរដែលលើកឡើងឥឡូវនេះ បានខ្ញុំដឹងថា ប៉ង់ ហ្នឹងគ្រប់គ្រងមន្ទីរទាំងអស់ហ្នឹង ប៉ុន្តែពីមុនមកខ្ញុំអត់ដឹងទេ។

**ស៖** តើលោកធ្លាប់ឃើញ ប៉ង់ មកមន្ទីរក-៣ ដែរឬទេ? ព្រោះថាលោកអាចទទួលបានដំណឹងឬក៏លោកឃើញដោយផ្ទាល់ឃើញឡានគាត់មកក-៣ នោះ?

**ផ៖** អត់ដែលបានឃើញមកផង ខ្ញុំដូចជាមិនចាំ ចង់និយាយថា វាអត់ចាំ។ ខ្ញុំអត់ដែលបានឃើញមកទេ។ ហើយអារឿងសំណួរដែលសួរខ្ញុំ រឿង ប៉ង់ ដែលមកក-៣ ខ្ញុំដូចអត់ដែលបានឆ្លើយថាឃើញ ឬក៏សំណួរ អត់ដែលឃើញទេ។

[១៤:២៣:២៨]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមអានឃ្លាមួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកនៅចំពោះមុខអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ E3/385 គឺនៅទំព័រ៧ នៅក្នុងភាសានីមួយៗ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំគិតថា សាក្សីគាត់មានឯកសារនេះជាភាសាខ្មែររួចហើយនៅពេលដែលមេធាវីការពារក្តី ខៀវ សំផន សួរគាត់នោះ។ ប៉ុន្តែប្រសិនបើគាត់មិនមានទេ ខ្ញុំអាចប្រគល់ជូនគាត់មួយច្បាប់ទៀតក៏បានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឯកសារមានហើយ មេធាវីជួយៗ ប្រឹក្សាជួយពិនិត្យមើលគាត់បន្តិចមើល!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

[១៤:២៤:៣៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្បាងឯលៈ**

**សៈ** ខ្ញុំសូមដកស្រង់នៅទំព័រទី៧ គឺប្រហែលជានៅពាក់កណ្ដាលទំព័រជាភាសាបារាំង។ "ខ្ញុំមានការភ័យខ្លាចក្រោយពីឮថា មានការចាប់ខ្លួន តាមៀល និង ប៉ង់ និងដោយសារខ្ញុំឮថាមានការផ្លាស់ប្ដូរមនុស្ស និងបាត់ខ្លួនជាបន្តបន្ទាប់"។ ក្រៅពី មៀល និងប៉ង់ តើលោកនិយាយនេះពីការបាត់ខ្លួនហ្នឹង បាត់ខ្លួនអ្នកណាខ្លះ? ហើយមានការផ្លាស់ប្ដូរអ្នកណាខ្លះ? តើលោកដឹងទេថាកម្មាភិបាលសម័យនោះ គឺថាមានការបាត់ខ្លួន ឬក៏ត្រូវបានចាប់ខ្លួននោះនៅពេលដែលលោកនៅមន្ទីរក-៣?

**លោក ឡេង ឈឿង៖**

**ឆៈ** នេះខ្ញុំនិយាយថា ភ័យខ្លាចនេះគឺក្រោយពីឮនេះ គឺខ្ញុំទៅនៅជាមួយ បើកឡានឲ្យលោក ខៀវ សំផន ហើយបានឮទៅ ក៏បាត់ទៅ ចេះតែខ្លួនឯងក៏ភ័យខ្លាចដែរ ប៉ុន្តែដល់ពេលទី១, ទី២ទៀត ខ្លួនឯងអាងនៅតែកុមារតូចទៅ បើសិននេះចុះ ធ្វើម៉េចក៏មិនដឹងយ៉ាងម៉េចដែរ ព្រោះមិនយល់ដែរអារឿងហ្នឹងមិនដឹងយ៉ាងម៉េច ប៉ុន្តែឲ្យដូចគាត់និយាយអ៊ីចឹងថា ឲ្យគេធ្វើបាបធ្វើអីខ្ញុំ អត់ដែលធ្វើបាបដែរ។ ប៉ុន្តែបើគេចាប់នេះ ចាប់នោះ ខ្ញុំអត់ដឹងដែរ។ ក្រោយមកទេ ឮគេថាហ្នឹង ដល់ពេលឮគេថាមក ចុះភ័យចេះតែភ័យទៅក្នុងខ្លួនឯងហ្នឹង។

[១៤:២៦:១៧]

**សៈ** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចង់សួរលោកនូវសំណួរមួយចំនួនទៀតពាក់ព័ន្ធទៅនឹងប្រធានបទដែលយើងបានពិភាក្សារួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺពិភាក្សាជាមួយនឹងប្រពន្ធរបស់លោក ខៀវ សំផន។ តើលោកអាចជម្រាបជូនបានទេថា នៅក-៣ ហ្នឹងលោកមានអាហារហូបចុកគ្រប់គ្រាន់?

**ឆៈ** បាទ ខ្ញុំនៅហ្នឹងកន្លែងគេដាំបាយ ខ្ញុំដឹងតែហូបទៅ។ មានម្ហូបហូបបាយគ្រប់គ្រាន់ ខ្ញុំហូបមួយឆ្អែត មិនថាគ្រប់គ្រាន់ទេ វាមិនមានម្ហូបច្រើនទេ ប៉ុន្តែដឹងថាមួយមុខ ប៉ុនហូបបានមួយឆ្អែត។ ដល់អ៊ីចឹងទៅ។

**សៈ** អ៊ីចឹងឧទាហរណ៍ ខ្ញុំចង់សួរលោកថា បាយហ្នឹង បាយហូបគ្រប់គ្រាន់ទេ ហូបឆ្អែតពេញលេញទេ?

**ឆៈ** បាទឆ្អែត ហូបឆ្អែត ប៉ុន្តែមិនមានម្ហូបបីបួនមុខ ដូចយើងកុម្ម៉ង់តាមហាងឥឡូវទេ។ ប៉ុន្តែវាមានមួយមុខមែន ប៉ុន្តែមួយមុខហូបឆ្អែត អស់ដួសទៀតៗម៉ាឆ្អែតដែរ?

**ស៖** ចុះមេដឹកនាំខ្មែរក្រហមនោះ ពួកគាត់ហូបចុកដូចគ្នាដែរ ដូចៗលោកដែរទេ មានម្ហូបអាហារដូចលោកទេ ពីព្រោះលោកថាអម្បាញ់មិញនេះគឺថា ផ្ទះបាយហ្នឹង គឺថាបែងចែកដាច់ពីគ្នា អ៊ីចឹងតើលោកដឹងទេថា មេដឹកនាំហ្នឹងគាត់ហូបចុកដូចលោកដែរឬទេ?

**ឆ៖** បាទ ផ្ទះបាយហ្នឹង ខ្ញុំសូម្បីតែទៅជិត ក៏មិនបានទៅជិតដែរ គឺនៅឆ្ងាយពីគ្នា ដាច់ពីគ្នា។ ខ្ញុំអត់បានដឹងទេរឿងហ្នឹង រឿងរបស់គាត់ ខ្ញុំអត់ដឹងទេ។

[១៤:២៨:២៨]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយថានៅពេលទៅដល់ក-៣ លោកបានឃើញ នួន ជា, អៀង សារី, ខៀវ សំផន រស់នៅក្នុងផ្ទះនីមួយៗដាច់ដោយឡែកពីគ្នា។ លោកស្រី សូ សុជាតិ ដែលមកផ្តល់សក្ខីកម្មនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ដែលគាត់បានឆ្លើយនៅម៉ោង ០៩:៣៣:១៨វិនាទី។ គេសួរថា “តើលោកស្រី សូ សុជាតិ តើនៅឆ្នាំ១៩៧៦ មេដឹកនាំផ្សេងៗទៀត ចាកចេញអស់ ទុកចោលលោកស្រី និងប្តីនៅក-៣ មែនទេ?” លោកស្រី សូ សុជាតិ គាត់ឆ្លើយថា “ចាស ពិតជាអ៊ីចឹងហើយ”។ សូមបញ្ចប់ការដកស្រង់។ នេះជាការសង្ខេបនូវចម្លើយរបស់ប្រពន្ធ របស់លោក ខៀវ សំផន។ អ៊ីចឹងគាត់បានបញ្ជាក់ថា នៅឆ្នាំ១៩៧៦នោះ មេដឹកនាំផ្សេងទៀតចេញទៅអស់ហើយ នៅសល់តែលោក ខៀវ សំផន ទេ។ ហើយនៅក្នុងចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងនៅទីនេះថាលោកនៅពេលដែលលោកទៅដល់ឆ្នាំ១៩៧៨ នោះ នួន ជា, អៀង សារី គឺគាត់មានផ្ទះនៅក-៣។ តើលោកអាចបញ្ជាក់បានទេថា លោកពិតជាបានឃើញ នួន ជា និង អៀង សារី នៅក-៣មែន គឺនៅក្នុងផ្ទះរបស់ពួកគាត់រៀងៗខ្លួន?

[១៤:២៩:៥៣]

**ឆ៖** បាទសំណួរនេះគឺថា ផ្ទះគាត់មានចល័ត ប៉ុន្តែចង់និយាយថាផ្ទះគាត់មានអាហ្នឹងមែន ប៉ុន្តែគាត់ចេញចូលមកសម្រាក ក៏ខ្ញុំអត់ដឹងដែរ ព្រោះផ្ទះគាត់មានពីរបីកន្លែងអ៊ីចឹងទៅ។ គាត់នៅទៅសម្រាកនៅ១យប់២យប់ទៅ។ ប៉ុន្តែផ្ទះគាត់នៅក-៣ហ្នឹងមាន ប៉ុន្តែគាត់ចេញចូលខ្ញុំធ្លាប់ឃើញ។ ប៉ុន្តែឲ្យសម្រាករាល់យប់ អត់ដឹងដែរ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយថា សឿន ដែលជាកងការពាររបស់លោក ខៀវ សំផន បានទៅតាមលោក ខៀវ សំផន ជាប់ជានិច្ច។ កាលពីថ្ងៃទី១០ ខែមិថុនា នៅក្នុងពង្រាងប្រតិចារឹក គឺថានៅម៉ោង១៥:៣៩នាទីនោះ លោកស្រី សូ សុជាតិ គាត់បាននិយាយ

ផ្ទុយទៅវិញ។ គេ សួរគាត់ថា "តើពេលដែលគាត់ចេញពីក-៣ មានអង្គរក្សតាមទេ? គាត់ឆ្លើយថាអត់មានទេ"។ ឥឡូវនេះ ខ្ញុំសូមអាននូវចម្លើយពេញលេញរបស់លោក ឯកសារ E3/385 នៅទំព័រ៤ ក្នុងភាសាទាំងបី។ លោក បានឆ្លើយថា "មានឈ្មោះ ហឿន ដែលជាអ្នកបើកឡើនឲ្យ ខៀវ សំផន ក្រោយមកទៀតគេប្តូរគាត់ឲ្យ បើកឡានឲ្យ អៀង សារី វិញ"។ ហើយចុះមកទៀតលោកឆ្លើយថា "ខ្ញុំស្គាល់ ទន ជាកងការពារឲ្យ ខៀវ សំផន មែន។ ក្រោយមកគេប្តូរឈ្មោះ សឿន ឲ្យមកជំនួស ទន វិញ។ ដូច្នេះពីខែ៤ ឆ្នាំ១៩៧៨ មក ខៀវ សំផន មានអ្នកបើកឡាន គឺរូបខ្ញុំ និងកងការពារឈ្មោះ សឿន នេះ"។

[១៤:៣១:៥៤]

ជាដំបូងនោះ តើលោកអាចបញ្ជាក់បានទេថា សឿន បានទៅតាមលោក ខៀវ សំផន បានជូន ខៀវ សំផន ទៅគ្រប់ទីកន្លែង ហើយបន្ទាប់មកទៀតក៏មានកងការពារទៅតាមលោក ខៀវ សំផន ដែរ នៅពេលដែលគាត់ធ្វើដំណើរទៅណាមកណានោះ?

**ផ៖** ដូចជាអត់មានទេ មានតែ សឿន ហ្នឹងម្នាក់ហ្នឹង។ ហើយសំណួរសួរដែលសួរថាឈ្មោះ ទន ឈ្មោះអីហ្នឹងទាល់តែគាត់សួរលើកលែងឆ្ងាយអ៊ីចឹង ខ្ញុំនឹកឃើញ។ ខ្ញុំធ្លាប់ដឹងថាគេដូរពីមុនមក ដល់ពេលយើងទៅដល់អ៊ីចឹង គេដូរៗមនុស្សទៅ។ ដល់អ៊ីចឹងដឹងថាគាត់ហ្នឹង។ ប៉ុន្តែឲ្យស្គាល់គាត់ជិតស្និទ្ធអត់ទេ។ ចង់និយាយថា គាត់ដូរទៅ គាត់ទៅនៅ មិនដឹងទៅនៅណាទេ ប៉ុន្តែដល់ពេលយូរៗឃើញជួបគ្នាម្តង។ ហើយក្រោយមកបាត់ ខ្ញុំក៏បានសួរ ទាល់គាត់រំឭករឿងហ្នឹង ខ្ញុំក៏នឹងអត់ឃើញដែរ ទើបតែមើលឯកសារហ្នឹងនិយាយទៅ បាននឹកឃើញថា អូ៎! វាយូរឆ្នាំពេកទៅហើយ។

[១៤:៣៣:០៧]

**ស៖** ខ្ញុំនឹងរំឭកការចងចាំរបស់លោកបន្ថែមទៀតលោកសាក្សី។ ឥឡូវនេះខ្ញុំចង់យោងទៅលើឯកសារដែលខ្ញុំបានប្រគល់ជូនលោកអម្បាញ់មិញ គឺលោកគឺឯកសារលេខ E3/858 នេះជាបញ្ជីបុគ្គលិកមន្ទីរ-ក គឺនៅឆ្នាំ១៩៧៨។ ខ្ញុំសូមយោងទៅលើឯកសារទំព័រទី១ ជាភាសាខ្មែរ ជាភាសាពីរ -- ជាទំព័រ២ ជាភាសាអង់គ្លេស និងទំព័រ៣ ជាភាសាបារាំង។ គឺនៅក្រោមចំណងជើងថា ក-៣ នៅភាសាបារាំងគឺនៅចុងទំព័រតែម្តង "ទន ជាបុគ្គលិក ជា១កងការពាររបស់បង ហែម មកពីភូមិថ្មី ជ័យសែនតំបន់១០៣។ ទី២ ហឿន អង្គរក្ស បងហែម មកពីតំបន់១០៣។ ទី៣ សឿន អង្គរក្ស បងហែម មកពីភូមិភាគព្រៃសាន គាត់ជាជនជាតិភាគតិច"។ តើ សឿន នេះគឺជា ហើយនិង ទន នេះគឺជាមនុស្សដដែល ព្រោះថាលោកបាននិយាយអំពីឈ្មោះទាំងអស់នេះ។ អ៊ីចឹងតើឈ្មោះហ្នឹងហើយជាឈ្មោះដែលលោកឆ្លើយជូនសហព្រះ

រាជអាជ្ញានោះមែនទេ? -- (សូមទោស) សហចៅក្រមស៊ើបអង្កេតនោះ?

[១៤:៣៤:៥២]

**ឆ៖** បាទ ឈ្មោះហ្នឹងហើយ ឈ្មោះ ទន ហ្នឹងប៉ុន្តែខ្ញុំអត់បានទៅទាន់គាត់ទេ គឺខ្ញុំមកនៅហ្នឹង គឺឃើញ សឿន ហើយ។ ប៉ុន្តែ សឿន ហ្នឹង ប្រាប់ខ្ញុំថាមុនហ្នឹង គេឲ្យ ទន ហ្នឹងនៅមុន។ ហើយ ហឿន ហ្នឹងក៏ដូរៗឈ្មោះ ហឿន នោះគឺគាត់ដូរជាមួយខ្ញុំដែរ ដល់ពេលខ្ញុំទៅដល់ហ្នឹង គេឲ្យចាត់តាំងខ្ញុំឲ្យបើកឡានជូនគាត់ហ្នឹង។

**ស៖** ចុះ សឿន ដែលនៅលេខរៀងទី៣នោះ ដែលជាកងការពារនោះ គឺថាជាអ្នកដែលលោកធ្វើការជាមួយ ក្នុងពេលដែលលោកជាអ្នកបើកឡានទុំង ហើយគាត់ជាអង្គរក្សរបស់លោក ខៀវ សំផន ហ្នឹង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

[១៤:៣៥:៥៣]

**ស៖** មុនពេលឈប់សម្រាក លោកប្រធាន។ ខ្ញុំសូមអនុញ្ញាតបន្តិច នៅលើខាងលើនៃឯកសារដដែលនេះ គឺក្រោមចំណងជើងមន្ទីរក-៣ មានឈ្មោះបួន មានគឺទី១ ទឿង ការពារអ៊ំទី២។ បាទ ខ្ញុំសូមរំលងព័ត៌មានលម្អិតមកពីណាៗអី អត់ទេ។ គឺថាទី២ សុត បន្ទាប់ការពារអ៊ំទី២, ដាន ការពារអ៊ំទី២, រ៉ន ការពារអ៊ំទី២។ តើលោកស្គាល់ឈ្មោះទាំងបួននាក់ហ្នឹងទេ? លោកធ្លាប់បាននិយាយអំពី សុត ហើយ ចុះ ទឿង, ដាន, រ៉ន តើលោកធ្លាប់ជួបពួកគាត់ទេ នៅពេលដែលលោកធ្វើការជូនលោក ខៀវ សំផន នោះ? តើពួកគាត់ពិតជាកងការពាររបស់អ៊ំទី២ មែនទេ?

**ឆ៖** ដូចជាមិនសូវចាំទេ ប៉ុន្តែឈ្មោះហ្នឹងមានខ្លះ ដូចជាស្រពេចស្រពិល ខ្ញុំ។ វាអត់ចាំ ឥឡូវមកដល់សព្វថ្ងៃនេះ វាអត់ចាំ។ វាបែកគ្នាយូរដែរទៅ វាអត់ចាំ ហើយមិនបានទំនាក់ទំនងអីអ៊ីចឹង វាភ្លេចអស់។ ឈ្មោះហ្នឹងដូចជាប្រហែលៗ ដល់គាត់លើកអ៊ីចឹងទៅប្រហែលៗ ប៉ុន្តែអត់ចាំ ថាចាំពិតប្រាកដអត់ទេ។ មិនដឹងជាមាន ឬមិនមាន ខ្ញុំជម្រាបត្រង់អ៊ីចឹងតែម្តង។

[១៤:៣៧:៣៥]

**ស៖** បាទ សំណួរចុងក្រោយមុនពេលឈប់សម្រាក។ ពាក់ព័ន្ធទៅនឹងមន្ទីរក-១ ខ្ញុំសូមឲ្យលោកមើលទៅលើ នៅទំព័រខាងលើគឺមន្ទីរក-១ មានឈ្មោះពីរ។ គឺពីរដំបូងសូមឲ្យលោកមើល “បងលីន ប្រធានរួមមន្ទីរក-១, ក-៤។ ហើយក្នុងនោះបញ្ជាក់ថា ប្រពន្ធគាត់ឈ្មោះ សែម មកពីភូមិភាគឧត្តរ។

លេខ២ គឺបងតាន ប្រធានមន្ទីរក-១ មកពីព្រៃសាន"។ នៅពេលដែលលោកធ្វើការជូនលោក ខៀវ សំផន នៅមន្ទីរក-៣ តើលោកធ្លាប់ឮឈ្មោះអ្នកទាំងពីរហ្នឹងទេ គឺ បងលីន ហើយនិង បងតាន នេះ ដែលធ្វើការនៅក-១ នោះ?

**ផ៖** បាទ ឮទេ ឈ្មោះពីរនាក់នេះ។ ឮទាំងពីរនាក់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក។ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩នាទី ដល់ម៉ោង ១៥:០០នាទី)*

[១៥:០០:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយសូមរំឮកថា សូមលៃពេលវេលាសមស្របសម្រាប់បម្រុងទុកដល់ក្រុមមេធាវីការពារក្តី នួន ជា ដែលគាត់មានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះ ប្រសិនបើគាត់មានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំឃើញថាមេធាវីរបស់លោក នួន ជា ធ្វើសញ្ញាថាគាត់មិនត្រូវការពេលវេលាអ្វីទេ។ អ៊ីចឹងខ្ញុំគិតថាខាងយើងខ្ញុំនេះអាចសួរទៅដល់ម៉ោងបួនរសៀលនេះ ហើយជា

មួយនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ អានេះលើកលែងតែមេធាវីរបស់លោក នួន ជា ដូរគោលជំហររបស់ខ្លួន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកស្គាល់ឈ្មោះពីរនៅមន្ទីរក-១នេះ គឺថាលោក បងលីន ហើយនិង បងតាន។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើ បងលីន នេះជាមនុស្សតែមួយនិង កែន – កែនដែលលោកបាននិយាយអម្បាញ់មិញនេះ ឬក៏ឈ្មោះ កែន ហើយនិងឈ្មោះ លីន នេះជាមនុស្សពីរនាក់ខុសគ្នា?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ មនុស្សតែមួយ លីន ហើយនិង កែន មនុស្សតែមួយទេ។

[១៥:០២:២៤]

**ស៖** ហើយសូមអរគុណ។ តើលោកស្គាល់ បងតាន នេះតាមរបៀបណានៅមន្ទីរក-១ នោះ? នៅពេលដែលលោកដឹកលោក ខៀវ សំផន ទៅក-១ នេះ លោកជូនគាត់នៅក្នុងតែបរិវេណក-១ តែម្ដង ឬក៏នៅខាងក្រៅបរិវេណ ក-១ ទេ?

**ឆ៖** បាទ ខ្ញុំនៅខាងក្រៅក-១ បរិវេណខាងក្រៅ អត់បានចូលទៅក្នុង ប៉ុន្តែស្គាល់ឮឈ្មោះថា តាន ធ្វើអ្នកគ្រប់គ្រងនៅកន្លែងក-១ ហ្នឹង ទៅឮគេប្រាប់អីចឹង។

**ស៖** បាទសូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីចំណុចមួយចំនួនដែលបានលើកឡើងជាមួយលោកស្រី សូ សុជាតិ នៅក្នុងសវនាការថ្ងៃទី១០, ១២ មិថុនា កន្លងទៅនេះ។ ចំណុចមួយទាក់ទងទៅនឹងពិធីលៀងសាយភោជន៍ដែលលោក ខៀវ សំផន ទំនងជាបានចូលរួម។ តើលោកសាក្សីធ្លាប់បានជូនលោក ខៀវ សំផន ពេលយប់ ឬក៏ពេលល្ងាចនៅពេលដែលគាត់ទៅចូលរួមក្នុងពិធីស្រស់ស្រូបអាហារពេលល្ងាច ឬក៏ការពិធីជប់លៀង ឬក៏សកម្មភាពវប្បធម៌ផ្សេងៗនៅស្ថានទូតផ្សេងៗ នៅផ្ទះទទួលភ្ញៀវ ឬក៏ស្ថានទូតអីជាដើមនោះ។ តើលោកធ្លាប់បានជូនគាត់ទៅពិធីបែបហ្នឹងទេ?

[១៥:០៤:០៤]

**ឆ៖** បាទ សំណួរនេះខ្ញុំដូចជា តាមខ្ញុំមិនចាំ ខ្ញុំដូចជាអត់ដែលទេ។ តាំងពីខ្ញុំទៅរស់នៅជាមួយគាត់ៗដូចមិនដែលបានទៅៗជួបភ្ញៀវ ជួបអីឯណាឆ្ងាយៗដែរ។ ធ្លាប់ដឹង ខ្ញុំដឹងតែប៉ុណ្ណឹង បើជួបជប់លៀងអីហ្នឹង ខ្ញុំអត់ដែលដឹងទេ។

**សៈ** តើយើងអាចគិតបានឬទេថាលោក ខៀវ សំផន នោះទំនងជាអាចទៅជូនអ្នកផ្សេងទៀតទៅជាមួយឡានផ្សេងទៀត ឧទាហរណ៍ថាទៅជាមួយឡាន នួន ជា, អៀង សារី អីជាដើមនេះដើម្បីទៅចូលរួមកម្មវិធីជប់លៀង ឬក៏កម្មវិធីរបៀបហ្នឹងដោយពុំបាននាំលោកយកទៅជាមួយទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមអរគុណ។ ខ្ញុំសូមជំទាស់ទៅនឹងរបៀបសួរបែបនេះ សួរថាតើយើងអាចគិតថាគាត់ធ្វើយ៉ាងនេះយ៉ាងដូច្នេះ អ៊ីចឹងសូមកុំឲ្យគាត់នាំឲ្យសាក្សីឆ្លើយព្រាវ។ អ៊ីចឹងគួរតែសួរថា តើលោកចាំទេថាលោក ខៀវ សំផន បានទៅជាមួយអ្នកផ្សេងក្រៅពីលោក។ អ៊ីចឹងរបៀបសួររបស់គាត់នេះបង្កើតឲ្យមានបញ្ហា លោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**សៈ** បាទ លោកសាក្សី ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ។ បើលោកមិនជូនលោក ខៀវ សំផន ពេលយប់ទេ តើមានអ្នកណាផ្សេងទៀតទេដែលគាត់ឲ្យជូនគាត់ទៀតទៅកន្លែងណាមួយ នៅពេលដែលគាត់ត្រូវបំពេញការងារពេលយប់នេះ?

[១៥:០៦:១៧]

**លោក ឡុង ឈឿង៖**

**ឆៈ** សំណួរនេះគឺ អង្កាល់ពីសម័យហ្នឹងដូចៗជាគ្មានទេ តែខ្ញុំទៅរស់នៅអត់មានដែលទៅណាពេលយប់ទេ។ ព្រោះហើយតែកុងឡានហ្នឹងគឺដូចជាដាច់មុខម្នាក់ៗតែម្តង ព្រោះមិនអាចច្រឡូកច្រឡំគ្នាទេ។

**សៈ** តើលោកដឹង លោកដែលឃើញ លោក ខៀវ សំផន ឡើងឡានលោក នួន ជា ឬក៏លោក អៀង សារី ដែរទេ? លោកធ្លាប់ឃើញទេ?

**ឆៈ** ខ្ញុំនិយាយហើយនិយាយទៀតថា តាំងតែពីខ្ញុំទៅរស់នៅជាមួយគាត់ ដូចជាមិនដែលទេរយៈពេលជិត១ឆ្នាំហ្នឹង។ ប៉ុន្មានខែទេ ដូចជា៧-៨ខែ ខ្ញុំ --

[១៥:០៧:៣០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមរំឭកលោកដោយលើកឡើងថា នៅក្នុងឯកសារហ្វីបីសថា មានលោក ខៀវ សំផន បានចូលរួមក្នុងពិធីជប់លៀងមួយចំនួន គឺជាប្រតិចារឹកនៃការផ្សាយវិទ្យុនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីជាកំណត់សម្គាល់កំណត់ហេតុតុលាការ អ៊ីចឹងមានពិធីជប់លៀងមួយជាកិត្តិយសដល់ប្រធានាធិបតេយ្យរ៉ូម៉ានីចុះថ្ងៃទី២៨ ខែ៥ ឆ្នាំ១៩៧៨ គឺឯកសារ E3/1363, ERN ជាភាសាអង់គ្លេសគឺ 00169785។ ខ្ញុំពុំមានលេខ ERN ជាភាសាផ្សេងទៀត។ ហើយមានពិធីជប់លៀងមួយទៀតដែរ នៅថ្ងៃទី២៣ កក្កដា ឆ្នាំ១៩៧៨ នៅស្ថានទូតអេហ្ស៊ីប នៅគឺឯកសារ E3/293 ចុះថ្ងៃទី២៥កក្កដា ឆ្នាំ១៩៧៨។ ហើយមានពិធីជប់លៀងផ្សេងទៀតដែលសម្រាប់បុណ្យខួបបក្សកុម្មុយនីស្តកម្ពុជាដែលសម្រាប់ទទួលចិននៅ -- លោកមានចាំទេពីទស្សនកិច្ចរបស់ប្រធានាធិបតេយ្យរ៉ូម៉ានី នៅចុងឆ្នាំ៧៨? មានពិធីជប់លៀងមួយគឺនៅថ្ងៃទី២៨ ខែ៥ ឆ្នាំ១៩៧៨ នេះ លោកចាំទេ?

[១៥:០៩:១៩]

**ឆ៖** បាទ នេះចាំមុនហ្នឹងខ្ញុំ អានេះមិនមែន៧៨ ទេ គឺ៧៧។ តាមខ្ញុំចាំនៅ៧៧ មុនខ្ញុំទៅនៅជាមួយគាត់។ ខ្ញុំនៅមន្ទីរក-១២ ឮវិទ្យុផ្សាយតើអាហ្នឹង។ អង្កាល់ហ្នឹងខ្ញុំអត់ទាន់បានទៅបើកបរជូនគាត់ទេ។

**ស៖** ខ្ញុំសូមបញ្ជាក់ថា គឺឯកសារដែលចុះថ្ងៃទី២៨ ឧសភា ឆ្នាំ១៩៧៨។ អម្បាញ់មិញលោកបាននិយាយថា "នៅពេលដែលគេចាប់ខ្លួន មៀល លោក -- ពេលនោះលោកបានចាកចេញពីមន្ទីរក-៣ ហើយ។ ក៏ប៉ុន្តែមាននៅក្នុងឯកសារមួយ មៀល ត្រូវគេចាប់នៅថ្ងៃ០៨ ឧសភា ឆ្នាំ១៩៧៨ ហើយលោកបាននិយាយថា លោកបានមកក-៣ នេះខែ៤ ឆ្នាំ១៩៧៨"។ លោករក្សាចម្លើយនេះ ឬក៏លោកចង់បញ្ជាក់ថា លោកមកមន្ទីរក-៣ នេះក្រោយពេលដែលប្រធានាធិបតីរ៉ូម៉ានី បានមកធ្វើទស្សនកិច្ចប្រទេសកម្ពុជាហើយៗ?

**ឆ៖** បាទ ខ្ញុំសំណួរនេះ ខ្ញុំដូចជាចាំមិនច្បាស់ ប៉ុន្តែខ្ញុំតាមចាំខ្លះ គឺដូចប្រធានាធិបតីរ៉ូម៉ានី ហ្នឹងមកទស្សនកិច្ចហើយ បានខ្ញុំទៅ បានខ្ញុំទៅរស់នៅបើកបរជូនលោក ខៀវ សំផន។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ឯកសារ E3/385 នេះលោកបាននិយាយថា លោកបានស្តាប់ព័ត៌មាននៅតាម នៅវិទ្យុ ហើយនិងមីក្រូ នៅទំព័រទី៦ គ្រប់ភាសាទាំងអស់ និងទំព័រទី៨ គ្រប់ភាសាទាំងអស់ដែរ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថានៅក-៣ ហ្នឹង លោកស្តាប់វ៉ាដ្យូបាន ឬក៏ព័ត៌មានមួយចំនួនត្រូវបានគេផ្សព្វផ្សាយតាមមីក្រូ?

[១៥:១១:៣៩]

**ឆ៖** បាទភាគច្រើនស្ដាប់វិទ្យុ។ មីក្រូគេដាក់តាមផ្លូវ ដល់ពេលយើងបើកឡានទៅបានឮ។ កាលសម័យហ្នឹងដាក់កន្លែងតាមមុខមន្ទីរគេនីមួយៗ គេដាក់មីក្រូ ដើម្បីឲ្យគេស្ដាប់។

**ស៖** តើលោក ខៀវ សំផន ហើយនិងប្រពន្ធគាត់ហ្នឹងមានវិទ្យុផ្ទាល់ខ្លួននៅក-៣ បើតាមដែលលោកឃើញ ហើយនិងបានឮ?

**ឆ៖** ប្រពន្ធគាត់ខ្ញុំមិនដឹងទេ ប៉ុន្តែចំពោះខ្លួនលោក ខៀវ សំផន គាត់មានវិទ្យុគាត់។ គាត់ត្រូវតែស្ដាប់រហូត ឲ្យតែមាននោះ ឃើញគាត់កាន់ចុះកាន់ឡើង។ គាត់ស្ដាប់ភាសាអីក៏ខ្ញុំមិនដឹងដែរគាត់។

**ស៖** សូមអរគុណ។ ព្រឹកមិញនេះ មុនពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់លោក ខៀវ សំផន នោះ លោកឆ្លើយថាយើងត្រូវ --

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែចាប់តាមគាត់អត់ទាន់។ សូមឲ្យលោកព្រះរាជអាជ្ញានិយាយម្ដងទៀតបាទ។

[១៥:១៣:១៦]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញានិយាយម្ដងទៀត ចុងក្រោយនេះ ពីព្រោះអ្នកបកប្រែមិនអាចបកប្រែភាសាលោកបានទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សូមអរគុណ។ លោកសាក្សី ពេលដែលខាងការពារក្ដី ពេលដែលគាត់សួរចប់ហ្នឹង គាត់និយាយថា លោកបាននិយាយថា ខៀវ សំផន គួរឲ្យគោរព ហើយលោកគិតថាមិនត្រូវទៅមើលផ្ទះលោក ខៀវ សំផន នៅស្រុកស្រែ។ បើមិនមិនជឿឲ្យទៅមើលផ្ទះគាត់ផ្ទាល់ទៅ។ តើលោកខ្លួនឯងផ្ទាល់លោកធ្លាប់បានទៅមើលផ្ទះគាត់ទេ ហើយដឹងថាផ្ទះគាត់នៅឯណាទេ?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទពីព្រឹក ខ្ញុំនិយាយហ្នឹង ខ្ញុំមិនមែនថាផ្ទះគាត់នៅស្រុកស្រែទេ ថាគាត់រស់នៅសាមញ្ញធម្មតា ដូចជាអ្នកស្រុកស្រែ ហើយគួរតែគោរព។ ចំពោះខ្លួនខ្ញុំគោរព មិនមែនឲ្យតែប្រជាពលរដ្ឋខ្មែរទាំងអស់គោរពទេ។ ខ្ញុំធ្លាប់រស់នៅហ្នឹងគោរព ខ្ញុំនិយាយអ៊ីចឹងតើ ខ្ញុំបាននិយាយអ៊ីចឹងមែន។ បើរឿងផ្សេង

ទៀត ខ្ញុំអត់ដឹងទេ មិនមែនឲ្យតែប្រជាជនខ្មែរគោរពទាំងអស់នោះ អត់ទេ។ ប៉ុន្តែចំពោះខ្លួនខ្ញុំ គោរពគាត់ ឃើញគាត់រស់នៅល្អ ចេះអប់រំណែនាំចំពោះខ្លួនខ្ញុំ ឃើញតែរស់នៅពេលហ្នឹងទេ។ ខ្ញុំរស់នៅរយៈពេលខ្លីហ្នឹងទេ។ គាត់និយាយប្រាប់អី អប់រំ។ ដល់អីចឹងទៅ ខ្ញុំគោរពអីចឹងទេ។ ចំពោះខ្លួនខ្ញុំទេគោរព មិនមែនឲ្យប្រជាជនខ្មែរទាំងអស់គោរពគាត់ទេ។

[១៥:១៥:៥៥]

ចំពោះខ្លួនខ្ញុំបានឃើញ បើគាត់អ្នកផ្សេងអត់បានដឹង អត់បានឃើញទេ។ អាហ្នឹងគួរតែសំណួរហ្នឹងចែកគ្នាឲ្យដាច់ មិនមែនខ្ញុំមើលផ្ទះគាត់ទេ។ ខ្ញុំអត់បាននិយាយមើលផ្ទះគាត់ ហើយគាត់អត់មានកម្មសិទ្ធិ អាហ្នឹងកម្មសិទ្ធិមែន ចង់និយាយថារបបរហូតមកដល់សព្វថ្ងៃនេះ គាត់ឲ្យមានកម្មសិទ្ធិអាហ្នឹង ខ្ញុំចង់អីចេះ បកស្រាយអីចេះ។ បើគាត់សួរទៅដេញដោលខ្ញុំអារឿងហ្នឹង ខ្ញុំថា ខ្ញុំបកស្រាយឲ្យអស់អីចឹង។ គាត់រស់នៅគួរគោរព គឺរស់នៅអត់មានកម្មសិទ្ធិអី ធ្វើអ្នកដឹកនាំគេធំមួយដែរ ដល់ពេលចុងក្រោយមកអត់មានអី អស់រលីងមកខ្លួនទទេ។ ចង់និយាយថាអីចឹង ខ្ញុំគោរពអីចឹងទេ។

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយអំពីការរបស់លោក ខៀវ សំផន វិញ នៅពេលដែលលោកធ្វើការឲ្យគាត់នៅឆ្នាំ១៩៧៨។ នៅទំព័រ៤ នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក គឺឯកសារ E3/835 ទំព័រទី៤ទាំងបីភាសា លោកនិយាយថា "លោក ខៀវ សំផន មិនសូវបានចេញទៅក្រៅទេ ក៏ប៉ុន្តែលោក អៀង សារី មានការងារច្រើន អីចឹងគាត់ចេញក្រៅច្រើន"។ សូមបញ្ចប់ការដកស្រង់។

[១៥:១៦:១១]

ហើយនៅទំព័រទី៨ នៃកំណត់ហេតុដដែលហ្នឹង គឺគេសួរលោក "តើលោកគឺថាលោក ខៀវ សំផន ជាមនុស្សមានអំណាចទេ?" ហើយខាងការពារក្ដីក៏បានដកស្រង់ចំណុចនេះដែរអំមិញ។ ចម្លើយលោកឆ្លើយថា "មិនទេ គាត់មិនមានអំណាចទេ។ ខ្ញុំមានអារម្មណ៍ថាគាត់ពុំមានការងារធ្វើអីច្រើនទេ ហើយភាគច្រើនគាត់នៅភ្នំពេញ"។ បាទ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី លោកផ្ដល់ចំណាប់អារម្មណ៍របស់លោកច្រើននៅទីនេះ ហើយនឹងនៅចំពោះមុខចៅក្រមស៊ើបអង្កេតផងដែរ ក៏ប៉ុន្តែយើងនៅទីនេះ យើងស្វែងរកបង្ហាញអង្គហេតុពិត។ យើងដឹងហើយថាកាលនោះ លោកអាយុ១៤នោះទេ អីចឹងមិនអាចចាំបានគ្រប់ជ្រុងជ្រោយទេ។ ក៏ប៉ុន្តែបើតាមអ្វីដែលលោកមើលឃើញ កាលពីអាយុ១៤ឆ្នាំនោះ តើជាការចាំបាច់ដែរឬទេ ក្នុងការចេញពីមន្ទីរក-៣ ដើម្បីបំពេញភារកិច្ចរបស់ខ្លួននៅសម័យខ្មែរក្រហម?

[១៥:១៧:១៣]

**ឆ៖** សំណួរនេះខ្ញុំដូចជាមិនយល់ ដោយចាំបាច់ចំពោះខ្លួនខ្ញុំ ឬចាំបាច់យ៉ាងម៉េចទេ។ ដូចជាមិនយល់ទេសំណួរនេះបាទ។ មិនចាំបាច់យ៉ាម៉េច ខ្ញុំអត់យល់។

**សៈ** បាទ តាមពិតលោកបាននិយាយថា លោក ខៀវ សំផន មិនសូវចេញក្រៅទេ ហើយ អៀង សារី គាត់ចេញច្រើន ដោយសារគាត់មានការងារច្រើន។ អ៊ីចឹង១ខ្ញុំសួរថាលោកកាលនោះ លោកធ្វើការឲ្យ ខៀវ សំផន។ អ៊ីចឹងចំពោះការយល់ឃើញរបស់លោកនេះ ការដែលយើងចេញទៅក្រៅច្រើនហ្នឹងបានន័យថាយើងមានការងារច្រើន។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំយល់អ៊ីចឹងចំពោះខ្លួនខ្ញុំ ព្រោះថាអ្នកណាចេញទៅក្រៅច្រើនគឺមានការងារច្រើន។ ព្រោះអ្នកនៅផ្ទះដែលមានអីធ្វើអី នៅតែផ្ទះ ចង់និយាយថាអ៊ីចឹង។ ខ្ញុំគិតថាខ្លួនខ្ញុំ កាលពីជំនាន់។

**សៈ** អម្បាញ់មិញនេះ លោកបាននិយាយថាលោកមិនបានចូលទៅក្នុងផ្ទះរបស់លោក ខៀវ សំផន ទេ។ អ៊ីចឹងតើលោកយល់ស្របនឹងខ្ញុំទេ ក្នុងការនិយាយថាលោកមិនដឹងថាលោក ខៀវ សំផន -- អ្វីដែលលោក ខៀវ សំផន ធ្វើទេ នៅផ្ទះគាត់ក៏ដោយ នៅមន្ទីរក-៣ ក៏ដោយ?

[១៥:១៨:៥៤]

**ឆ៖** បាទខ្ញុំអត់ដឹងមែន ព្រោះខ្ញុំនៅខាងក្រៅ។ ខ្ញុំអត់ដឹងទេ។

**សៈ** បាទទំព័រទី៤ ឯកសារដដែល លោកបាននិយាយថា នៅមន្ទីរក-៣ នេះពុំមានបន្ទប់ប្រជុំរួមទេ។ ហើយលោកក៏មិនដែលឃើញមេៗទាំងអស់នោះដែរមករួមប្រជុំគ្នា ប៉ុន្តែមានកន្លែងហូបបាយរួមគ្នានៅក្រោមផ្ទះ ហើយដ៏ធំមួយ ហើយមានតុវែងមួយ។ អម្បាញ់មិញនេះលោកបាននិយាយថាមេដឹកនាំហូបបាយនៅកន្លែងខុសគ្នាពីកន្លែងពួកលោក ហើយលោកក៏បានបញ្ជាក់ផងដែរថា លោកពុំមានសិទ្ធិចូលរួមកិច្ចប្រជុំរបស់មេដឹកនាំធំៗនោះទេ។ តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថាលោកមិនអាចនិយាយថាអ្នកដឹកនាំខ្មែរក្រហមមិនធ្វើ -- មិនប្រជុំគ្នានៅពេលហូបបាយ ឬក៏គេមិនប្រជុំនៅកន្លែងបាយរួមនោះ ឬក៏លោកមិនដឹងថា មេដឹកនាំខ្មែរក្រហមហ្នឹង បានប្រជុំគ្នានិយាយពីរឿងអ្វីមួយនោះទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងមែន វាមិនដឹង ព្រោះមិនដឹងពេលគាត់ហូបបាយ ផ្ទះបាយផ្សេង ហើយពេលទៅកន្លែងគាត់ធ្វើ -- ទៅជួបជុំគ្នា ក៏ខ្ញុំអត់បានទៅ ព្រោះតែកុងឡាននៅឆ្ងាយ ខ្ញុំអត់ដឹងទេ។ បើសិនជាគាត់ជួបគ្នា ដឹងថាគាត់ជួបគ្នា មិនដឹងនិយាយរឿងអី ខ្ញុំអត់ដឹង។ ដល់អ៊ីចឹងទៅ បានខ្ញុំឆ្លើយថាខ្ញុំមិនដឹងតែម្តង។

[១៥:២០:៤៧]

**ស៖** បាទ មានសាក្សីមួយដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ គាត់ឈ្មោះ ពីន គីន គាត់បានលើកឡើងថា នៅថ្ងៃទី០៣ ឧសភា ឆ្នាំ២០១២ គឺឯកសារ E1/72.1 ប្រតិចារឹកប្រហែលជាម៉ោង១០:២០នាទី។ គាត់និយាយដូច្នេះ “បើតាមការកត់សម្គាល់របស់ខ្ញុំនៅសម័យនោះ ក-៣គឺជាកន្លែងដែលមេដឹកនាំខ្មែរក្រហមប្រជុំគ្នា។ ឧទាហរណ៍ដូចជា អ៊ំប៉ុល, អ៊ំហែម, អ៊ំ នួន ជា, អ៊ំ សុន សេន គាត់ជួបគ្នានៅទីនោះ។ ខ្ញុំបានឃើញគាត់នៅទីនោះ ហើយឃើញគាត់ចូលចេញពីបរិវេណក-៣ ហ្នឹង”។ បាទសូមបញ្ចប់ការដកស្រង់។ តើលោកស្គាល់លោក ពិន គីន ហ្នឹងទេ? បាទ សូមអភ័យទោស លោក ពាន ឃាន (ពីអ្នកបកប្រែ សូមកែប្រែ)។ លោក ពាន ឃាន តើលោកស្គាល់លោក ពាន ឃាន នេះទេ? ហើយលោកយល់ស្របហ្នឹងអ្វីដែលលោក ពាន ឃាន បានលើកឡើងនេះទេ?

[១៥:២២:០០]

**ឆ៖** បាទ ការនិយាយស្តីរបស់លោក ពាន ឃាន ហ្នឹង មិនដឹងជា ខ្ញុំអត់បានស្គាល់ទេ ប៉ុន្តែការនិយាយស្តីរបស់គាត់នេះ បើសិនចំពោះខ្ញុំដែលបានទៅរស់នៅ គឺខ្ញុំដូចមិនមានទេ មិនយល់ស្របនូវពាក្យសម្តីដែលគាត់និយាយហ្នឹង។ ព្រោះគាត់ថាទៅជួបគ្នាប្រជុំហ្នឹង ប៉ុន្តែរយៈពេលដែលខ្ញុំទៅនៅហ្នឹង អត់មានដែលមកជួបជុំគ្នាប្រជុំគ្នាកន្លែងក-៣ ហ្នឹងទេ អត់តែម្តង។

**ស៖** ប៉ុន្តែលោកសាក្សី អម្បាញ់មិញនេះលោកទើបតែនិយាយថាលោកយល់ស្របជាមួយខ្ញុំ ថាលោកពុំដឹងថាមានកិច្ចប្រជុំដែរឬទេ ហើយក៏មិនដឹងថាមានប្រជុំនោះ គេនិយាយអំពីអ្វីដែរ។

បាទ ឥឡូវ ខ្ញុំសូមនិយាយអំពីប្រធានបទមួយទៀត គឺមន្ទីរក-១។ ខ្ញុំសូមអានសម្រង់របស់លោកកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ លោកបាននិយាយអម្បាញ់មិញថា នៅពេលដែលលោកជូនលោក ខៀវ សំផន ហ្នឹង គាត់នៅមន្ទីរក-១ នោះ ប្រហែលជួនកាលកន្លះម៉ោង ជួនកាល១ម៉ោង។ នៅទំព័រទី៥ ជាភាសាខ្មែរ -- ទាំងបីភាសានៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក។ “ខ្ញុំជូនគាត់ទៅក-១ញឹកញាប់ដែរ គឺថាពីរទៅបីដងក្នុង១សប្តាហ៍។ គាត់នៅទីនោះ ប្រហែលជា២ទៅ៣ម៉ោងម្តងៗ ជួនកាលកន្លះម៉ោង ហើយគាត់ ហើយខ្ញុំឃើញគាត់ចេញមកវិញ។ នៅទីនោះ ខ្ញុំឃើញ អៀង សារី ហើយនិង នួន ជា ផងដែរ។ ខ្ញុំដឹងថា អៀង សារី, នួន ជា -- គាត់ជា អៀង សារី, នួន ជា នោះដោយសារខ្ញុំជួបអ្នកបើកបររបស់គាត់ចាំនៅក្រៅដូចខ្ញុំដែរ។ ខ្ញុំមិនដឹងថាគេប្រជុំនិយាយអំពីអ្វីនោះទេ”។ បាទ សូមបញ្ចប់ការដងស្រង់។

[១៥:២៣:៤៥]

តើលោកនៅតែរក្សាចម្លើយលោកដែរឬទេ ថានៅមន្ទីរក-១ នេះ គេប្រជុំគ្នាញឹកញាប់ដែរ ២ទៅ៣សប្តាហ៍ម្តង ហើយលោក ខៀវ សំផន ទៅទីនោះ ពី២ទៅ៣ម៉ោងម្តងៗ? បាទ ពីរបីដងក្នុង១អាទិត្យ បាទ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នឹងរបៀបសួរ។ សាក្សី បាននិយាយថាគាត់ជូនលោក ខៀវ សំផន ទៅទស្សនកិច្ចនៅខាងក្រៅ ហើយគាត់នៅក្រៅមន្ទីរក-១ ទេ ហើយនិយាយពីប្រជុំថា ពី ១ម៉ោង, ២ម៉ោង, ៣ម៉ោងនេះ គឺជាការសន្មត ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញាហើយ ព្រោះថា គាត់មិនដឹងថានៅក្នុងមន្ទីរក-១ បរិវេណមន្ទីរក-១ នោះ មិនដឹងថាគេប្រជុំ ឬមិនប្រជុំទេ ហើយប៉ុន្មានម៉ោងៗយ៉ាងណានោះ គាត់មិនដឹងទេ គាត់នៅក្រៅ។ អ៊ីចឹងសូមឲ្យគាត់សួរឡើងវិញ។

[១៥:២៤:៥៥]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី តើលោកបានទៅក-១ ជាមួយលោក ខៀវ សំផន ពីពីរទៅបីដង ហើយម្តងៗនោះ២-៣ម៉ោង។ ជួនកាលនោះទៅតែកន្លះម៉ោងទេ។ លោករក្សាចម្លើយនេះរបស់លោកទេ?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទ ពេលខ្លីទៅអ៊ីចឹងដូចគាត់និយាយប៉ុន្តែមិនមែនទៀតទាត់ដែរ ជួនកាលក៏មិនបានទៅ ជួនកាលក៏ទៅប៉ុន្តែក្នុង១អាទិត្យហ្នឹងវាមានទៅ ប៉ុន្តែទៅពីរបីម៉ោង ជួនកាលក៏កន្លះម៉ោង ជួនកាល១ម៉ោង ប៉ុន្តែគាត់ធ្វើអីខ្ញុំអត់ដឹងដែរ ព្រោះទៅខ្ញុំអត់បានដឹងទេ ខ្ញុំនៅខាងក្រៅ។

**ស៖** តើលោក ខៀវ សំផន ធ្លាប់នៅក-១ នោះលើសពី៣ម៉ោងទេ? ឧទាហរណ៍១ថ្ងៃពេញ តែម្តង ឬក៏ជួនកាលគាត់អាចសម្រាន្តនៅក-១ ផងដែរ?

**ឆ៖** ដូចអត់ដែលទៅនៅអ៊ីចឹង ខ្ញុំដូចអត់ដែលឃើញគាត់ តាំងពីខ្ញុំទៅរស់នៅជាមួយគាត់អត់ដែលទេ។

[១៥:២៦:២២]

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយពីអ្វីដែលលោកបាននិយាយអម្បាញ់មិញនេះ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ ឯកសារ E3/385 ទំព័រទី៨។ គ្រប់ឯកសារទាំងអស់ លោកនិយាយថាលោក ខៀវ សំផន បានទៅមន្ទីរក-១ ពីរទៅបីដង -- ទទួលភ្ញៀវពីរបីដង។ ហើយបានទៅទទួលសារតាំងអី។ ហើយកន្លែងហ្នឹងគឺនៅក្រោយព្រះរាជវាំង។ តើលោកប្រាកដថាគាត់ទៅតែពីរបីដងទេឬក្នុងរយៈពេលដែលចន្លោះពី៨ -- ៩ទៅ១០ខែ ពេលដែលលោកធ្វើការជាមួយគាត់នោះ ឬក៏ត្រង់ចំណុចនេះដែរ លោកមិនសូវចាំច្បាស់ទេ?

**ឆ៖** បាទ ខ្ញុំ អានេះខ្ញុំឆ្លើយតែខ្ញុំចាំ ខ្ញុំអត់ចាំខ្ញុំអត់ដឹងដែរ ព្រោះបើឆ្លើយទៅនាំឲ្យខុសដល់ខ្លួនខ្ញុំ។ ហើយគាត់ទៅមែន ទៅហ្នឹងដោយសារដឹងហ្នឹង គឺដឹងនៅលើប្រកាសក្នុងវិទ្យុទេ ឮក្នុងវិទ្យុទេប្រកាសថាថ្ងៃនេះៗទៅទទួលសារតាំង អីចឹងទៅបានដឹង។ បើថាឲ្យគាត់ចេញមកវិញដឹងអត់ដឹងទេ គាត់អត់មាននិយាយប្រាប់ណា។

[១៥:២៧:៥២]

**ស៖** បាទ ខ្ញុំកត់សម្គាល់ថាឯកសារដែលមាននៅក្នុងសំណុំរឿង ឯកសារ ហ្វីប៊ីស មានអគ្គរាជទូតចំនួន១១ ដែលបានប្រគល់សារតាំងទៅលោក ខៀវ សំផន ចន្លោះពីខែមេសា ឆ្នាំ១៩៧៨ និងខែធ្នូ ឆ្នាំ១៩៧៨។ បាទ ខ្ញុំមិនរៀបរាប់ទាំងស្រុងនោះទេ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកឯកភាពដែរឬទេក្នុងការនិយាយថាលើសពីពីរបីដងក្នុងរយៈពេលដែលលោកធ្វើការជាមួយគាត់នេះ ឯកអគ្គរាជទូត ដូចជាឯកអគ្គរាជទូតទុយនេស៊ី ខែមេសា ៧៨ ហើយថ្ងៃ -- ហើយនិងឯករាជទូតផ្សេងៗទៀត ថ្ងៃខែផ្សេងៗទៀតដូចជា ម៉ានីល, ន័រវែស, ប៉ាគីស្តង់ អីជាដើមនេះ។ តើបើតាមលោកយល់ឃើញ តើគាត់ទៅទទួលសារតាំងនេះតែពីរបីដងហ្នឹងទេ ឬក៏លើសពីហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវី!

[១៥:២៩:០៥]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសាក្សី ដើម្បីឲ្យយើងខ្ញុំទាំងអស់គ្នាតាមទាន់នោះគួរព្រះរាជអាជ្ញាហ្នឹងផ្តល់លេខយោងនៃឯកសារដែលគាត់យោងអម្បាញ់មិញនេះផង។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឯកសារទី១គឺថា ខែមេសា ឆ្នាំ៧៨ ឯកសារ E3/1361 ចុះថ្ងៃទី៣ មេសា លេខយោង 00168782, ជាភាសាបារាំងគឺ00700200។ ខ្ញុំពុំមានលេខ ERN ជាភាសាខ្មែរទេ។ អ៊ីចឹងនៅថ្ងៃទី០៣ ឆ្នាំ១៩៧៨ ថ្ងៃទី០៦ មេសា ៧៨ ឯកអគ្គរដ្ឋទូតន័រវែសបានប្រគល់សារតាំង, ជាភាសាអង់គ្លេសគឺ 00168791។ ១៨ មិថុនា ៧៨ ទទួលសារតាំងពីឯកអគ្គរដ្ឋទូតម៉ាឡេស៊ី, ឯកសារ E3/1363, ERN ភាសាអង់គ្លេស 00169831។ ថ្ងៃទី១៣ សីហា ឆ្នាំ១៩៧៨ ឯកអគ្គរដ្ឋទូតហ្គីណេ, ឯកសារ E3/95, ERN ជាភាសាអង់គ្លេសគឺ 00168963។ មានឯកសារ E3/76 ចុះថ្ងៃទី០៣ កញ្ញា ឆ្នាំ១៩៧៨ គឺឯកអគ្គរដ្ឋទូតជប៉ុនប្រគល់សារតាំងជូន អង់គ្លេសគឺ 00170348។ ថ្ងៃទី០២ សីហា ឆ្នាំ១៩៧៨ លិខិតសារតាំង E3/294 បាទ (សូមកែប្រែថ្ងៃទី -- ខែតុលា អម្បាញ់មិញនេះ) ភាសាអង់គ្លេស 00170198។ ថ្ងៃទី០៨ តុលា ៧៨ ឯកអគ្គរដ្ឋកូរ៉េខាងជើងប្រគល់សារតាំង, ឯកសារ E3/294, ទំព័រ ERN 00170 219។ ហើយមួយទៀតមានឯកអគ្គរដ្ឋទូតបួនទៀតនៅឆ្នាំ១៩៧៨ ខែ១២ ប៉ាគីស្តង់, ណេប៉ាល់ ហើយនិង ស្វីស ឯកសារ E3295, ERN 0069050។

[១៥:៣២:៤២]

បាទ ឥឡូវខ្ញុំសូមនិយាយអំពីការទទួលភ្ញៀវផ្សេងទៀត ដូចជាភ្ញៀវយូហ្គោស្លាវី ថ្ងៃទី២ ឧសភា ឆ្នាំ១៩៧៨ដែរ, ឯកសារ E3/1362, ERN 00169981 ហើយមានឯកសារ -- មានភ្ញៀវផ្សេងទៀត ឧទាហរណ៍ភ្ញៀវរ៉ូម៉ាំងអ៊ីជាដើម -- រ៉ូម៉ានី។ អង្កាល់នុ៎ងនោះលោកអាយុ១៣-១៤ឆ្នាំទេ តើការចង់ចាំរបស់លោកគួរឲ្យទុកចិត្តបានដែរទេ ដែលលោកនិយាយថា លោកបានទទួលភ្ញៀវបរទេសតែពីរបីដងទេ ឬក៏លោកគិតថា ប្រហែលជាគាត់អាចទទួលភ្ញៀវអ្នកការទូតហ្នឹងច្រើនជាងហ្នឹង លើសពីពីរបីដង?

**លោក ឡុង ឈឿង៖**

**ឆ៖** នេះខ្ញុំតាមខ្ញុំចាំប្រហែលជាពីរបីដងទេ ប៉ុន្តែសន្និដ្ឋានអ៊ីចឹងនាំឲ្យតែខាងព្រះរាជអាជ្ញាចោទមកសួរខ្ញុំរហូតថាដែលខ្ញុំចេះតែថា ចេះតែនិយាយពន្លើសទៅ។ ដល់អ៊ីចឹងក៏ រឿងនេះខ្ញុំវាចាំតែប៉ុណ្ណឹង បាទពីមុនហ្នឹងខ្ញុំអត់បានចាំទេ។ ហើយពីមុនហ្នឹងក៏គាត់មិនធ្វើដែរ អត់បានធ្វើៗជាមួយអ្នកដទៃ អង្កាល់អ្នកដទៃនៅជាមួយ។ ក៏អ៊ីចឹងទៅ ក៏ខ្ញុំក៏អត់ដឹងដែរ ដល់ចោទសួរខ្ញុំក្រោយនេះ ខ្ញុំអត់ដឹងដែរ ពេលដែលខ្ញុំទៅនៅនេះ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១៥:៣៤:២៧]

**ស៖** បាទ អ៊ីចឹងខ្ញុំសំណួរចុងក្រោយ តើលោកបានជូនលោក ខៀវ សំផន ទៅឃ្លាំងមួយចំនួនដែរឬទេ ឃ្លាំងរដ្ឋ? នៅក្នុងការស្ដាប់ចម្លើយរបស់លោកដែលខ្ញុំបានអានអម្បាញ់មិញនេះគឺមានសរសេរថាៗមានឃ្លាំងរដ្ឋនៅមាត់ទន្លេ។ តើលោកធ្លាប់ជូនលោក ខៀវ សំផន ទៅទួលទំពូងដែរឬទេ? គឺថានៅឃ្លាំង និងទៅឃ្លាំងរដ្ឋនៅគីឡូម៉ែត្រលេខ៦ គឺនៅ ហើយនិងទៅច្រាំងចំរេះនៅឆ្នាំ១៩៧៨?

**ឆ៖** បាទអាហ្នឹងជូនៗមែន ប៉ុន្តែមិនដឹងជាឃ្លាំង មិនដឹងជាស្អីទេ គាត់បើកឡាន គាត់អត់មិនជាឈប់មើលផងហ្នឹង។ គាត់មិនឲ្យបើកឡានជូនទៅ ខ្ញុំក៏អត់ដឹងអីដែរ។ ប៉ុន្តែដល់គាត់សួរចម្លើយថា ទៅឃ្លាំងទៅអ៊ីចឹង ខ្ញុំអត់ដឹងដែរ ព្រោះម្ដុំច្រាំងចំរេះ គាត់ដើរទៅមើលអ៊ីចឹងទៅ គាត់ត្រឡប់មកវិញ។ មិនដឹងជាបើកឡានទៅ គាត់ឲ្យបើកទៅ ស្រាប់តែទៅ បើកទៅត្រឡប់មកវិញទៅ។ គាត់ថាឈប់ប៉ុណ្ណឹងបកមកវិញទៅ បកមកវិញប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកនិយាយថា គាត់នៅទីនោះហើយ គាត់នៅតែមួយរយៈពេលខ្លីទេហ្នឹង តើគាត់មានបានចុះពីលើឡានទេ?

**ឆ៖** គាត់អត់ចុះផងហ្នឹង ខ្ញុំទៅគ្រាន់តែទៅ បើកៗឃើញទៅ ត្រឡប់មកវិញហ្នឹង។ អ៊ីចឹងបានថាទៅបើកឡានត្រឡប់មកវិញ។ បើចុះ ខ្ញុំប្រាប់ថាចុះហើយបាទ។

[១៥:៣៦:១៧]

**ស៖** បាទមិនថ្វីទេ តើលោកធ្លាប់បានជូនលោក ខៀវ សំផន ទៅបឹងត្របែកដែរឬទេ?

**ឆ៖** ទៅបឹងត្របែក ខ្ញុំអត់ចាំ ដូចមិនដែលដឹង អត់ដែលជូនទេ ខ្ញុំអត់ចាំ។

**ស៖** លោកមិនចាំ បានន័យថាលោកមិនច្បាស់ ឬក៏ថាអាច លោកអាចទៅដែរ តែលោកមិនចាំឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹងខ្ញុំវាអត់ចាំ មិនដឹងទៅ ឬមិនទៅ ខ្ញុំអត់ហ៊ានសន្និដ្ឋានទេ ព្រោះថាសន្និដ្ឋានទៅវាខុសបានខ្ញុំថា ដូចវាអត់ចាំម្ដង។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទសូមអរគុណលោកសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសួរចប់ហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៥:៣៧:៣៥]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមិនច្រើនប៉ុន្មានទេសម្រាប់សួរលោកសាក្សី។ ហើយខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ។ ខ្ញុំចង់សូមសួរសំណួរសម្រាប់ឲ្យលោកបំភ្លឺនូវចំណុចមួយចំនួន។ តើលោកអាចបញ្ជាក់បានទេ សព្វថ្ងៃមុខរបររបស់លោកធ្វើអ្វី?

**លោក ឡេង ឈឿង៖**

**ឆ៖** បាទបញ្ជាក់បាន មុខរបរខ្ញុំសព្វថ្ងៃធ្វើជាមន្ត្រីនគរបាលជាតិ ប្រចាំនៅស្រុកសំពៅលូន។

**ស៖** តើលោកអាចបញ្ជាក់អំពីឋានៈរបស់លោកបានទេ នៅក្នុងនគរបាលជាតិហ្នឹង?

[១៥:៣៨:៣៥]

**ឆ៖** ខ្ញុំមានមុខតំណែងជានាយរងផ្នែកស្ថិតិនៅក្នុងស្រុកសំពៅលូនហ្នឹង។

**ស៖** បាទសូមអរគុណ។ មុននេះលោកបានឆ្លើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាផ្នែកអន្តរជាតិ។ លោកបាននិយាយថា លោក ខៀវ សំផន គាត់ស្លូតបូត ហើយគាត់ចេះអប់រំ ណែនាំ។ តើលោកអាចបញ្ជាក់បានទេថា តើខ្លឹមសារដែលលោក ខៀវ សំផន ធ្លាប់អប់រំណែនាំដែលលោកធ្លាប់បានឮ តើគាត់និយាយអំពីអ្វីខ្លះ?

**ឆ៖** អានេះគឺខ្ញុំ មិនដឹងនិយាយយ៉ាងម៉េចទេ វា--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះ។ ខ្ញុំមិនដឹងថា ឃើញថាកន្លែងណាទេថាលោក ខៀវ

សំផន ដែលសាក្សីនេះនិយាយថា លោក ខៀវ សំផន ហ្នឹងគាត់ពូកែអប់រំគេអីនេះ ខ្ញុំមិនដឹងថានៅកន្លែងណា។

[១៥:៣៩:៥៩]

**លោក ពេជ អង្គរ៖**

សូមគោរពលោកប្រធាន ខ្ញុំមិនបាននិយាយថាលោក ខៀវ សំផន ពូកែអប់រំនោះទេ។ មុននេះលោកសាក្សីនេះបានឆ្លើយទៅនឹងចម្លើយរបស់ -- ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា គាត់បាននិយាយថាលោក ខៀវ សំផន គាត់ចេះអប់រំណែនាំ។ អ៊ីចឹងសំណួររបស់ខ្ញុំ ពាក់ព័ន្ធទៅនឹងខ្លឹមសារដែលលោកបាននិយាយហ្នឹង ថាតើអ្វីដែលជាខ្លឹមសាររបស់នៅក្នុងការអប់រំនោះ? អ៊ីចឹងអ្វីដែលខ្ញុំលើកយកមកសួរនេះ គឺជាសម្រង់នៃពាក្យពេចន៍ដែលលោកសាក្សីនេះបានឆ្លើយចំពោះតំណាងសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ សូមលោកប្រធានអនុញ្ញាតឲ្យគាត់ឆ្លើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនមាន មិនសមស្របទេ មិនមានមូលដ្ឋានទេ។ សេចក្ដីជំទាស់មិនមានប្រសិទ្ធភាព។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលសួរលោកអម្បាញ់មិញនេះ!

[១៥:៤១:០៥]

**លោក ឡេង ឈឿង៖**

**ឆ៖** សំណួរនេះ ខ្ញុំក៏ការឃើញគាត់ ថាការអប់រំណែនាំតាំងពីការរស់នៅអី គាត់មិនប្រាប់អីទេ ប៉ុន្តែការរស់នៅរបស់គាត់នេះ ដល់ឃើញទៅ គួរតែរៀនសូត្រតាមគាត់។ គាត់ដូចជាអប់រំណែនាំ ហើយគាត់ទៅប្រាប់ថាយើងនៅហ្នឹងមានធ្វើស្អី គាត់ប្រាប់ថារស់នៅ គាត់មិនដែលនិយាយអីថាឲ្យរស់នៅអប់រំអីផង គាត់ថាដែលគ្រាន់តែប្រាប់ថាធ្វើនេះធ្វើនោះទេទៅ ហើយយើងធ្វើតាមទៅ គាត់ក៏គោរព ខ្ញុំក៏គោរពគាត់ គាត់ក៏ស្រលាញ់ខ្ញុំអ៊ីចឹងទៅ។ អ៊ីចឹងខ្ញុំថាដែលជាមនុស្សល្អ ខ្ញុំគិតថាមនុស្សល្អអ៊ីចឹងឯង។

**សួរដោយលោក ពេជ អង្គរ៖**

**ស៖** ខ្ញុំ -- លោកមិនទាន់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ អម្បាញ់មិញលោកបញ្ជាក់ថែមទៀតថាគាត់ឲ្យធ្វើនេះធ្វើនោះទៅ ហើយចេះតែធ្វើតាមទៅ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើការអប់រំ ឬការដែលថាអ្វី

ដែលគាត់ណែនាំឲ្យលោកធ្វើនេះធ្វើនោះហ្នឹង ថាតើគាត់ណែនាំយ៉ាងម៉េចខ្លះនៅក្នុងការណែនាំរបស់គាត់? គាត់និយាយអ្វីខ្លះ? តើលោកអាចលើកករណីមួយចំនួនដែលគាត់បានណែនាំដែរឬទេ?

[១៥:៤២:១៥]

**ឆ៖** ខ្ញុំមិនចាំដែរ ការណែនាំអប់រំវាយូរឆ្នាំពេកទៅហើយ។ ប៉ុន្តែការនិយាយគាត់និយាយឲ្យល្អទៅ មិននិយាយអាក្រក់។

**ស៖** តើគាត់មានធ្លាប់និយាយអំពីបញ្ហាសន្សំសំចៃដែរទេ នៅក្នុងការអប់រំរបស់គាត់ហ្នឹង?

**ឆ៖** បាទ គាត់ធ្លាប់និយាយរឿងហ្នឹង ពាក្យអប់រំសន្សំសំចៃហ្នឹងគាត់សន្សំសំចៃថែរក្សាអីហ្នឹង គាត់ធ្លាប់ៗឮគាត់និយាយប្រាប់។

**ស៖** លោកអាចពន្យល់បន្ថែមបានទេ ពាក់ព័ន្ធនឹងបញ្ហាសន្សំសំចៃហ្នឹង គាត់និយាយយ៉ាងម៉េចខ្លះ? លោកអាចនិយាយឲ្យបានក្បោះក្បាយបន្តិចបានទេ?

**ឆ៖** ខ្ញុំនិយាយអត់បានដែរ ព្រោះបញ្ហាអប់រំ ប្រាប់ថាអប់រំចេះសន្សំសំចៃ ចេះថែរក្សាតែប៉ុណ្ណឹងឯង ដឹងតែប៉ុណ្ណឹងហើយ គេប្រាប់តែប៉ុណ្ណឹង ដឹងឲ្យវាក្បោះក្បាយយ៉ាងម៉េចទៀត ខ្ញុំនឹងនិយាយយ៉ាងម៉េចទៀត។

[១៥:៤៣:២៥]

**ស៖** បាទ ខ្ញុំចូលទៅចំណុចមួយទៀត លោកបានមានប្រសាសន៍ថា លោកធ្លាប់ជូនលោក ខៀវ សំផន ចេញពីភ្នំពេញប្រហែលជា៤គីឡូ ឬក៏ប្រាំប្រាំមួយគីឡូ ឬក៏រហូតទៅដល់១០គីឡូអីចេញពីភ្នំពេញហើយត្រឡប់មកវិញ។ លោកមានបានសង្កេតទេ ពេលដែលលោក ខៀវ សំផន គាត់ដែលលោកជូនដំណើរលោក ខៀវ សំផន ទៅហ្នឹងជាមួយលោក ខៀវ សំផន ហ្នឹង លោកមានសង្កេតឃើញអាកប្ប-កិរិយារបស់គាត់ទេ គាត់ចាប់អារម្មណ៍អំពីអ្វីៗដែលនៅជុំវិញនោះដែរឬទេ ហើយគាត់មានចាប់អារម្មណ៍ពីប្រជាជនឬក៏មនុស្សដែលនៅជុំវិញនោះដែរឬទេ?

**ឆ៖** បាទ សំណួរនេះ ព្រោះខ្ញុំក៏មិនបានសង្កេតគាត់។ ម្យ៉ាងទី១ទៀតក៏ខ្ញុំនៅតូចដែរ មិនដឹងថាចាប់អារម្មណ៍សង្កេតយ៉ាងម៉េច កាលជំនាន់ហ្នឹងទាល់តែរហូតដល់ បើសិនជាធំដូចសព្វថ្ងៃនេះវាដឹងដែរ ប៉ុន្តែរស់នៅជំនាន់ហ្នឹងតូចៗ ក៏មិនបានចាប់អារម្មណ៍។ អត់ដឹង មិនដឹងសង្កេតយ៉ាងម៉េច មិនដឹងគិតថាសង្កេតទៅឃើញគាត់យ៉ាងម៉េច អាហ្នឹងក៏មិនបានគិត ក៏មិនបានចាប់ភ្លឹកហ្នឹងទៅ ក៏អត់ដែលបានគិត មិនដឹងអីចឹង។ ខ្ញុំក៏គិតមិនដល់ដែរ ខ្ញុំនៅតូចៗហ្នឹង។

[១៥:៤៤:៤៨]

**ស៖** ប៉ុន្តែលោកមានធ្លាប់ឮនៅពេលដែលលោកជូនគាត់ទៅហ្នឹង ធ្លាប់ឮគាត់និយាយអំពីអ្វីនៅពេលកំពុងធ្វើដំណើរជាមួយគ្នាចេញពីភ្នំពេញទៅទេ?

**ឆ៖** ដូចដែលអត់និយាយផងលោក ចាំមិនបានផង មិនដឹង។ ភាគីច្រើនដូចអត់និយាយ ជិះឡានជាមួយគ្នា អត់និយាយ។

**ស៖** បាទ ខ្ញុំអរគុណចំពោះចម្លើយរបស់លោក។ ខ្ញុំនឹងបន្តទៅចំណុចមួយទៀត ចំណុចដែលសួរហើយ ក៏ប៉ុន្តែបញ្ជាក់លើបញ្ហានោះបន្ថែមតែប៉ុណ្ណោះ គឺករណីដែលលោកបាននិយាយថា លោកបានដឹកលោក ខៀវ សំផន នៅមន្ទីរក-១ ជាញឹកញាប់ជារៀងរាល់សប្តាហ៍នោះ។ តើលោកអាចបញ្ជាក់បានទេ ពេលដែលលោកដឹកលោក ខៀវ សំផន ទៅមន្ទីរក-១ ហ្នឹង ថាតើពេលណាខ្លះដែលលោកដឹកទៅលោកទៅមន្ទីរក-១ ហ្នឹង? អាចពេលព្រឹក ពេលល្ងាច ពេលត្រង់ថ្ងៃ? តើលោកអាចបញ្ជាក់ពីបញ្ហាហ្នឹងបានទេ?

[១៥:៤៦:០១]

**ឆ៖** បញ្ហានេះ ខ្ញុំក៏ភាគច្រើន តាមខ្ញុំចាំដូចជាពេលព្រឹក និងថ្ងៃរសៀល។ ភាគច្រើន -- ប៉ុនមិនច្បាស់ដែរ ព្រោះឥឡូវវាភ្លេចយូរឆ្នាំទៅហើយ វាមិនបានចាប់អារម្មណ៍អារឿងអីចឹងផង ដល់ពេលគាត់មកសួរអីចឹងទៅ ខ្ញុំក៏ចងចាំខ្លះ ប៉ុន្តែភាគច្រើននៅព្រឹក។

**ស៖** ចុះមានពេលថ្ងៃត្រង់ដែរឬទេ? ជាពិសេសពេលបាយជាមួយគ្នា តើលោក -- ពេលបាយតើលោកមានបានជូនគាត់ទៅពិសាបាយជាមួយគ្នាដែរឬទេ?

**ឆ៖** អត់ដឹងដែរបាយ ព្រោះខ្ញុំអត់បានចូលទៅដល់ទេ ព្រោះអត់ដឹងគាត់ហូបបាយទេ។ ខ្ញុំអត់ដឹងទេ ព្រោះផ្ទះបាំងរបងជិត ហើយនៅឆ្ងាយ។ អត់ដឹងទេ ខ្ញុំអត់ដឹងផងហ្នឹង។

**ស៖** បាទ ក៏ប៉ុន្តែធ្លាប់ជូនទៅពេលថ្ងៃត្រង់ដែរ ឬក៏អត់ទេ? ពេលថ្ងៃត្រង់?

**ឆ៖** ពេលថ្ងៃត្រង់ ដូចមិនដែល -- ដែលខ្ញុំចាំ អត់ដែរទេ តាមខ្ញុំចាំគ្រាន់ខ្ញុំភ្លេច ប៉ុន្តែដូចជាមិនដែរទេថ្ងៃត្រង់ បើម៉ោងពី ម៉ោងបីអាច ក្រែងលោមានធ្លាប់ជូន អាហ្នឹងឃើញ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងចំណុចនេះ តើនៅពេលដែលលោកជូនលោក ខៀវ សំផន ទៅ លោកមានធ្លាប់ឃើញ ឬក៏ធ្លាប់ដឹងថា មានអ្នកផ្សេងៗទៀត មកពីបណ្តារខេត្ត គាត់មកកន្លែងក-១ ហ្នឹងដែរឬទេ? វាអាចនៅក្នុងឱកាសនៃការប្រជុំអ្វីមួយ?

[១៥:៤៨:00]

**ឆៈ** បាទអត់ដឹងទេ ព្រោះដែលមូលហេតុរបងផ្ទះគេនៅឆ្ងាយ ខ្ញុំអត់ដឹងទេ។ តួនាទីរបស់ខ្ញុំ គឺដូចខ្ញុំជម្រាបកន្លងមកអ៊ីចឹង គឺខ្ញុំនៅឆ្ងាយ ហើយរបងបិទជិត ចូលទៅបិទទ្វារទៅ។ ដល់ពេលអ៊ីចឹង ខ្ញុំដឹងតែចំពោះខ្លួនខ្ញុំ។ បើសិនជាអ្នកនៅជិតៗគ្នា ដូចជាអ្នកជិតៗគ្នានៅហ្នឹងបានស្គាល់គ្នា តែកុងឡាននៅជិតៗ ដូចតែកុងឡាន អៀង សារី, តែកុងឡាន នួន ជា ហ្នឹងបានស្គាល់។ បើក្រៅពីហ្នឹង ខ្ញុំអត់សូវស្គាល់ទេ។ អត់មានស្គាល់ទាំងពីណាមកទេ ព្រោះ -- ប៉ុន្តែអ្នកឆ្ងាយដូចមិនដែលឃើញមក។

**សៈ** បាទ អរគុណលោកដែលឆ្លើយនឹងសំណួររបស់ខ្ញុំ។ ខ្ញុំមិនមានសំណួរច្រើនទៀតទេ ក៏ប៉ុន្តែខ្ញុំចង់បញ្ជាក់ទាក់ទងទៅនឹងលោកស្រី សូ សុជាតិ ប្រពន្ធរបស់លោក ខៀវ សំផន ថាតើដែលគាត់ជាអ្នកដាំបាយនោះ ថាតើគាត់មានតួនាទីអីកន្លែងដាំបាយហ្នឹងដែរឬទេ? ថាតើមានអ្នកណាគេគ្រប់គ្រងពីលើគាត់នៅកន្លែងដាំបាយហ្នឹងដែរឬទេ?

**ឆៈ** ខ្ញុំអត់ដឹងដែរ ព្រោះសំណួរនេះខ្ញុំអត់ដឹងទេ។ ព្រោះកាលខ្ញុំនៅ ទី១ខ្ញុំនៅតូចៗ ប៉ុន្តែម្យ៉ាង គឺថាអត់ដឹង គេមិនឲ្យយើងដឹងអ្វីផង។ គ្រាន់តែប្រកាសដឹងថា អ្នកណាគ្រប់គ្រងមន្ទីរហ្នឹង បើថាអារឿងគ្រប់គ្រងដល់លម្អិត អត់ឲ្យដឹងទេកូនក្មេង។ ទី១ យើងក្មេង។

[១៥:៤៩:៤៥]

**សៈ** បាទ សំណួរចុងក្រោយរបស់ខ្ញុំ លោកអាចបញ្ជាក់បានទេ ថាតើលោកស្រី សូ សុជាតិ ហើយនិងលោក ខៀវ សំផន គាត់នៅផ្ទះជាមួយគ្នារាល់ថ្ងៃដែរឬទេ? នៅជាមួយគ្នារហូត ឬក៏ថាលោកស្រី សុជាតិ គាត់មានផ្ទះដាច់ដោយឡែក?

**ឆៈ** កាលខ្ញុំទៅរស់នៅជាមួយនោះ គាត់មានផ្ទះដាច់ដោយឡែក គាត់ដាច់ដោយឡែកពីគ្នា។

**សៈ** លោកអាចបញ្ជាក់បានទេ នៅកន្លែងណា?

**ឆៈ** នៅមន្ទីរក-៣ ហ្នឹង ផ្ទះគាត់ដាច់ដោយឡែកពីគ្នា អត់មានរស់នៅជាមួយគ្នាទេ។

**លោក ពេជ អង្គៈ**

បាទ អរគុណលោកសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។

លោកប្រធានខ្ញុំអស់សំណួរ ហើយៗសូមអរគុណលោកប្រធានដែលផ្តល់ឱកាសឲ្យខ្ញុំឆ្លើយសំណួរ អ៎! សួរសំណួរទៅសាក្សីនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយចុះមេធាវីការពារក្ដី នួន ជា មានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

**លោក សុន អរុណ៖**

ចំពោះក្រុមមេធាវីរបស់ នួន ជា ពុំមានសំណួរអ្វីសួរទៅសាក្សីនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

លោក ឡេង ឈឿង ការស្ដាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេល១ថ្ងៃកន្លងមកនេះដោយមានភាពអត់ធ្មត់ និងខិតខំអត់ពីសមត្ថភាព លទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ហើយជូនពរលោក ឡេង ឈឿង ឲ្យមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខសេចក្ដីចម្រើន ហើយវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៥:៥១:៤៦]

ហើយសវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធទី១៩ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ នៅថ្ងៃពុធខាងស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសនវការស្ដាប់សក្ខីកម្ម សាក្សីដែលមានរហស្សនាម TCW-801 សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះសាលាដំបូង ហើយនិងសាធារណជនជ្រាប។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថានៅថ្ងៃស្អែកនេះគឺជាទិវាបុណ្យជាតិជាថ្ងៃឈប់សម្រាក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឡេង ឈឿង ត្រឡប់ទៅកាន់គោលដៅណាដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។ ហើយលោកមេធាវី មឿង សុវណ្ណ មេធាវីប្រឹក្សាសាក្សីគឺអាចវិលត្រឡប់ទៅលំនៅដ្ឋានវិញបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺលោក ខៀវ សំផន និង

លោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃខានស្អែកថ្ងៃពុធ ទី១៩ ខែមិថុនា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៣នាទី)*